# របាយការណ៍ស្តីពីសិទ្ធិមនុស្ស៖ បុព្វកថា

## ការិយាល័យទទួលបន្ទុកលទ្ធិប្រជាធិបតេយ្យ សិទ្ធិមនុស្ស និងការងារ

## របាយការណ៍ប្រចាំប្រទេសស្តីពីការអនុវត្តសិទ្ធិមនុស្ស ឆ្នាំ២០១០

**ថ្ងៃទី ៨ ខែមេសា ឆ្នាំ២០១១**

ថ្ងៃនេះ ភ្នែកនៃពិភពលោកកំពុងផ្តោតលើតំបន់មជ្ឈឹមបូព៌ា និងអាហ្វ្រិកខាងជើង ដែលនៅទីនោះប្រជាជនកំពុងតែទាមទារអោយរដ្ឋាភិបាលរបស់គេគោរពតាមគោលការណ៍តំរង់ផ្លូវនៃសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស ដែលមានន័យថា "មនុស្សទាំងអស់កើតមកមានសេរីភាព ហើយមានកិត្តិយស និងសិទ្ធិស្មើគ្នា"។ ក្តីសង្ឃឹមលើគោលការណ៍នេះគឺជាកំលាំងជំរុញនៅពីក្រោយគ្រប់ចលនាទាំងអស់ដើម្បីសេរីភាព គ្រប់យុទ្ធនាការដើម្បីលទ្ធិប្រជាធិបតេយ្យ និងគ្រប់ការខិតខំដើម្បីរក្សាអោយមានការអភិវឌ្ឍន៍ ហើយនិងគ្រប់ការតស៊ូប្រឆាំងនឹងការគាបសង្កត់។ យើងមានការលើកទឹកចិត្តដោយភាពក្លាហាន និងការប្តេជ្ញាចិត្តរបស់សកម្មជនទាំងនេះ ហើយយើងមើលឃើញនៅក្នុងការតស៊ូរបស់គេនូវ សក្ខីភាពិតប្រាកដនៃការចង់បានជាសាកលនូវសេចក្តីថ្លៃថ្នូរ និងការគោរព។ យើងឈរជាមួយពួកគេ និងជាមួយពលរដ្ឋ សកម្មជន និងរដ្ឋាភិបាលទាំងអស់នៅជុំវិញពិភពលោក ដែលធ្វើការដោយសន្តិវិធី ដើម្បីជំរុញបុព្វហេតុនៃលទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស។

សមដូចលោកប្រធានាធិបតីអូបាម៉ាបានមានប្រសាសន៍ថា យើងដើរតាមគំនិតដ៏សាមញ្ញមួយ គឺ "... សេរីភាព យុត្តិធម៍ និងសន្តិភាពសំរាប់ពិភពលោកត្រូវតែចាប់ផ្តើមជាមួយសេរីភាព យុត្តិធម និងសន្តិភាពនៅក្នុងជីវិតរបស់មនុស្សម្នាក់ៗ"។ គំនិតនេះបង្ហាញនូវគុណតំលៃដែលយើងអោយតំលៃជាខ្ពស់ នៅសហរដ្ឋអាមេរិក តែវាមិនមែនជារបស់យើងតែឯងទេ។ ជំនឿរបស់យើងលើគោលការណ៍ជាសាកលនៃសេរីភាព យុត្តិធម៍ និងសន្តិភាពតំរង់ផ្លូវដល់យើងជារៀងរាល់ថ្ងៃ នៅពេលយើងធ្វើការដើម្បីប្រែក្លាយសិទ្ធិមនុស្សអោយទៅជាភាពពិតសំរាប់មនុស្ស។ ពិភពលោកមើលឃើញថា បើមិនមានជំហានប្រកបដោយអត្ថន័យឆ្ពោះទៅរកអភិបាលកិច្ចប្រកបដោយ តំលាភាព គណនេយ្យភាព និងតំណាងប្រជាជនត្រឹមត្រូវ នោះគំលាតគ្នារវាងប្រជាជន និងមេដឹកនាំរបស់គេនឹងកាន់តែឆ្ងាយ។ យើងនឹងបន្តជំរុញ គាំទ្រ និងការពារលទ្ធិប្រជាធិបតេយ្យក្នុងរូបភាពជាច្រើនរបស់វា ដោយដឹងថា វាគឺជាប្រព័ន្ធនយោបាយដ៏ល្អបំផុត ដែលអនុញ្ញាតអោយមនុស្សម្នាក់ៗទទួលបាននូវសិទ្ធិមនុស្សរបស់គេ។

របាយការណ៍ស្តីពីការអនុវត្តផ្នែកសិទ្ធិមនុស្ស ឆ្នាំ ២០១០ ស្តីពីប្រទេសមួយៗគឺជាកំណត់ត្រានៃស្ថានភាពសិទ្ធិមនុស្សក្នុងពិភពលោក ហើយលើកកំពស់ការយល់ដឹងទៅលើដំណើរជឿនលឿនដែលសំរេចបានក្នុងឆ្នាំ ២០១០ ការមិនសំរេចបាន និងការងារដែលត្រូវធ្វើនៅឡើយ។ ឆ្នាំនេះគឺជាឆ្នាំ ទី៣៥ ដែលយើងបានធ្វើសេចក្តីរាយការណ៍ទៅសភា ស្តីពីសិទ្ធិមនុស្ស នៅជុំវិញពិភពលោក។ របាយការណ៍ទាំងនេះ ដើមឡើយត្រូវបានចាត់ទុកថាជាមធ្យោបាយមួយសំរាប់ជួយតំរង់ផ្លូវដល់សហរដ្ឋអាមេរិកក្នុងគោលនយោបាយការបរទេសរបស់ខ្លួន តែវាបានបែរទៅបំរើបំណងច្រើនជាងនេះទៅទៀត។ រដ្ឋាភិបាល បុគ្គល និងអង្គការនានាដទៃទៀត នៅពេលនេះ ប្រើរបាយការណ៍សិទ្ធិមនុស្សទាំងនេះធ្វើជាប្រភពព័ត៌មានសំខាន់ស្តីពីស្ថានភាពនៅតាមប្រទេសនានានៅជុំវិញពិភពលោក។ សំរាប់សកម្មជន ដែលមានច្រើនគ្នា កំពុងតែមានលទ្ធភាពកាន់តែរួញតូចសំរាប់បំពេញភារកិច្ច ដែលជាការងារប្រកបដោយគ្រោះថ្នាក់សំរាប់រូបគេផ្ទាល់ខ្លួន របាយការណ៍ទាំងនេះក៏ផ្តល់ផងដែរនូវភស្តុតាងថា ពិភពលោកកំពុងតែត្រូវបានគេធ្វើអោយដឹងពីការតស៊ូរបស់ពួកគេ។

ក្នុងពេលខ្ញុំធ្វើដំណើរក្នុងពិភពលោក ខ្ញុំយកចិត្តទុកដាក់ជួបជាមួយអ្នកទាំងនោះ ដែលកំពុងធ្វើការដើម្បីជំរុញបុព្វហេតុសិទ្ធិមនុស្សក្នុងប្រទេសរបស់គេ។ ខ្ញុំមានការចាប់អារម្មណ៍ខ្លាំងចំពោះអំណាចនៃស្មារតីរបស់មនុស្ស និងការប្តេជ្ញាចិត្តដោយមិនងាករេនៃអ្នកក្លាហានទាំងនេះ។ ការងាររបស់គេលើកទឹកចិត្តយើង ហើយបញ្ជាក់ពីសារៈសំខាន់នៃការចាប់អោយរដ្ឋាភិបាល រួមទាំងរដ្ឋាភិបាលរបស់យើងផង អោយទទួលខុសត្រូវចំពោះការប្រព្រឹត្តទៅលើប្រជាជនរបស់ខ្លួន។

យើងផ្ញើរបាយការណ៍ស្តីពីការអនុវត្តសិទ្ធិមនុស្សនៅតាមប្រទេសនិមួយៗទៅសភាជារៀងរាល់ឆ្នាំ ហើយការលើកកំពស់សេរីភាពនិងសិទ្ធិមនុស្សគឺជាអាទិភាពប្រចាំថ្ងៃសំរាប់មនុស្សប្រុសស្រីក្នុងក្រសួងការបរទេសសហរដ្ឋអាមេរិក ទាំងនៅទីក្រុងវ៉ាស៊ីនតោន ទាំងនៅតាមស្ថានទូតរបស់យើងនៅបរទេស។ តាមរយៈរបាយការណ៍ទាំងនេះ តាមរយៈកិច្ចការទូតរបស់យើង និងតាមរយៈ គំរូរបស់យើង យើងនឹងបន្តជំរុញដល់សិទ្ធិមនុស្សជាសាកល សំរាប់មនុស្សគ្រប់រូប។ ពេលនេះគឺជាឱកាសសំរាប់យើងគាំទ្រមនុស្សទាំងអស់ដែលមានឆន្ទៈងើបឡើងដើម្បីសិទ្ធិដែលយើងស្រឡាញ់។

ក្នុងស្មារតីនេះ ខ្ញុំសូមផ្ញើជូនដល់សភាសហរដ្ឋអាមេរិកនូវរបាយការណ៍របស់ក្រសួងការបរទេសសហរដ្ឋអាមេរិកស្តីពីការអនុវត្តសិទ្ធិមនុស្ស ឆ្នាំ ២០១០ នៅតាមប្រទេសនិមួយៗ។

Hillary Rodham Clinton

រដ្ឋមន្ត្រីក្រសួងការបរទេសសហរដ្ឋអាមេរិក

# របាយការណ៍ស្តីពីសិទ្ធិមនុស្ស នៅកម្ពុជា ឆ្នាំ២០១០

## ការិយាល័យទទួលបន្ទុកលទ្ធិប្រជាធិបតេយ្យ សិទ្ធិមនុស្ស និងការងារ

## របាយការណ៍ប្រចាំប្រទេសស្តីពីការអនុវត្តសិទ្ធិមនុស្ស ឆ្នាំ២០១០

**ថ្ងៃទី ៨ ខែមេសា ឆ្នាំ២០១១**

ប្រទេសកម្ពុជាជាប្រទេសប្រកាន់របបរាជានិយមអាស្រ័យធម្មនុញ្ញ ដែលមានរដ្ឋាភិបាលមួយកើតចេញតាមរយៈ ការបោះឆ្នោត និងមានប្រជាជនប្រមាណជា ១៤លាននាក់ ។ នៅក្នុងការបោះឆ្នោតកាលពីពេលថ្មីៗនេះ ដែលរៀប ចំធ្វើឡើងនៅ ឆ្នាំ២០០៨ គណបក្សប្រជាជនកម្ពុជា (CPP) ដឹកនាំដោយលោកនាយករដ្ឋមន្រ្តី ហ៊ុន សែន បានឈ្នះចំនួន ៩០អាសនៈ ក្នុង ចំណោមអាសនៈរដ្ឋសភាចំនួន១២៣ អាសនៈ ។ អ្នកសង្កេតការណ៍ភាគច្រើនបានវាយតម្លៃថា ដំណើរការបោះឆ្នោតនេះ មានភាពប្រសើរជាងការបោះឆ្នោតកាលពីពេលកន្លងទៅ ប៉ុន្តែមិនទាន់បំពេញតាមបទដ្ឋានអន្តរជាតិទាំងស្រុងនៅឡើយទេ ។ គណបក្សប្រជាជនកម្ពុជាបានប្រមូលការគ្រប់គ្រងលើផ្នែកទាំងបីនៃរដ្ឋាភិបាល និងស្ថាប័នជាតិដទៃទៀត ដែលអំណាចភាគច្រើនត្រូវបានប្រមូលផ្តុំនៅក្នុងកណ្តាប់ដៃរបស់នាយករដ្ឋមន្រ្តី ។ ទោះបីជាអាជ្ញាធរស៊ីវិលមានឈ្មោះថាគ្រប់គ្រងកងកម្លាំងសន្តិសុខក៏ដោយ ក៏ក្នុងករណីជាច្រើន កម្លាំងសន្តិសុខធ្វើសកម្មភាពក្រោម ការបញ្ជារបស់ថ្នាក់ដឹកនាំរបស់គណបក្សប្រជាជនកម្ពុជា ។

កម្លាំងសន្តិសុខធ្វើឃាតមនុស្ស តាមចិត្តក្រៅប្រព័ន្ធតុលាការ ហើយបានធ្វើសកម្មភាពប្រកបដោយនិទ្ទណ្ឌភាព ។ ជនជាប់ឃុំទទួលរងការរំលោភបំពានជារឿយៗ ដើម្បីគាបសង្កត់អោយសារភាព។ ចំណែកស្ថានភាពពន្ធនាគារមានលក្ខណៈយ៉ាប់ខ្លាំង ។ អ្នកតាមដានស្ថានភាពសិទ្ធិមនុស្សបានរាយការណ៍ អំពីការចាប់ខ្លួនមនុស្សតាមចិត្តនឹកឃើញ និងការឃុំខ្លួនមុនពេលជំនុំជម្រះក្តីមានរយៈពេលយូរដែលជាការបង្ហាញអោយឃើញប្រព័ន្ធតុលាការទន់ខ្សោយ និងការបដិសេធសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ។ វិវាទដីធ្លី និង ការបណ្តេញចេញពីលំនៅដ្ឋានដោយបង្ខំ ដែលពេលខ្លះប្រកបដោយហឹង្សា នៅតែមានជាបន្ត។ រដ្ឋាភិបាលបានរឹតត្បិតសេរីភាពបញ្ចេញមតិ និងសេរីភាពសារព័ត៌មានតាមរយៈបណ្តឹងបរិហារកេរ្តិ៍ និងផ្សព្វផ្សាយព័ត៌មានមិនពិត ហើយជួនកាល រំខានដល់សេរីភាពក្នុងការជួបប្រជុំទៀតផង ។ អំពើពុករលួយមានលក្ខណៈរីករាលដាល ។ សង្គមស៊ីវិលបានសំដែងកង្វល់ខ្លាំងចំពោះពង្រាងច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាលថាអាចបង្ករឧបសគ្គដល់លទ្ធភាពបំពេញការងាររបស់អង្គការមិនមែនរដ្ឋាភិបាល។ អំពើហឹង្សាក្នុងគ្រួសារ និងការរំលោភបំពានកុមារបានកើតមានឡើង ការអប់រំកុមារមិនគ្រប់គ្រាន់ និងការជួញដូរស្ត្រី និងកុមារ នៅតែបន្តកើតមាន។ រដ្ឋាភិបាលបានផ្តល់ជំនួយឧបត្ថម្ភបន្តិចបន្តួចប៉ុណ្ណោះដល់ជនពិការ។ ការ

ប្រឆាំងនឹងសកម្មភាពសហជីពកម្មករដោយនិយោជក និងការអនុវត្តច្បាប់ការងារដែលនៅតែមានលក្ខណៈទន់ខ្សោយ នៅតែបន្តមានចំណែកឯពលកម្មកុមារនៅក្នុងវិស័យក្រៅផ្លូវការនៅតែបន្តជាបញ្ហា ដដែល ។

# ការគោរពសិទ្ធិមនុស្ស

## ផ្នែកទី១ ៖ ការគោរពភាពថ្លៃថ្នូររបស់បុគ្គល រួមទាំងសេរីភាពរួចផុតពី ៖

### ក. ការដកហូតជីវិតតាមអំពើចិត្ត ឬដោយខុសច្បាប់

ពុំមានរបាយការណ៍បញ្ជាក់ថា រដ្ឋាភិបាល និងភ្នាក់ងាររដ្ឋាភិបាលបានធ្វើឃាតដោយមូលហេតុនយោបាយឡើយ ។ ទោះជាយ៉ាងនេះក្តី មានការរាយការណ៍ថាកងកម្លាំងសន្តិសុខបានធ្វើឃាតតាមអំពើចិត្ត ទោះបីជាមានចំនួន តិចជាងឆ្នាំកន្លងទៅយ៉ាងណាក៏ដោយ ។

សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍កម្ពុជា (ADHOC) ដែលជាអង្គការមិនមែនរដ្ឋាភិបាលខ្មែរបានរាយការណ៍អំពីការធ្វើឃាតតាមអំពើចិត្តចំនួន ១២ ករណី ក្នុងនោះតាមការចោទប្រកាន់មាន ចំនួន ៤ ករណីធ្វើឡើងដោយក្រុមនគរបាល ៣ ករណីដោយមន្ត្រីកងរាជអាវុធហត្ថ និង ៥ ដោយទាហាន។ នគរបាលបានចាប់ខ្លួនជនសង្ស័យក្នុង ៣ ករណី។

នៅថ្ងៃទី ១០ ខែមករា អង្គការសិទ្ធិមនុស្សក្នុងស្រុកមួយបានរាយការណ៍ថា នរគបាលឃុំ ២ នាក់នៅខេត្តកណ្តាល ឈ្មោះ Chil Sarath និង Sun Vutha បានវាយធ្វើបាបឈ្មោះ Lon Chhun Leng។ ក្រោយមក ជនរងគ្រោះបានស្លាប់។ តាមរបាយការណ៍មកគឺថា ជនល្មើសមានជំលោះជាមួយជនរងគ្រោះនៅល្ងាចនោះ ក្នុងពិធីមង្គលការមួយ។ គ្រួសាររបស់ជនរងគ្រោះបានដាក់ពាក្យប្តឹងមកតុលាការខេត្ត។ នៅដំណាច់ឆ្នាំ បណ្តឹងនោះនៅតែមិនទាន់ត្រូវបានចាត់ការនៅឡើយ ថ្ងៃខែមិនទាន់បានកំណត់សំរាប់សវនាការទេ ហើយនរគបាលឃុំទាំង ២ នាក់នោះនៅតែមានសេរីភាពនៅឡើយ។

នៅថ្ងៃទី ២២ មិនា នរគបាលមួយក្រុមដឹកនាំដោយឈ្មោះ Nov Hach ដែលជាមេនរគបាលស្រុកមេសាង ខេត្តព្រៃវែង ត្រូវបានរាយការណ៍មកថា បានបាញ់សំលាប់ឈ្មោះ ឈឿន ឈាង នៅក្នុងការប៉ុនប៉ងចាប់ខ្លួនមួយ។ ក្នុងឆ្នាំ ២០០៥ តុលាការខេត្តបានកាត់ទោសអោយឈ្មោះឈឿន ដោយកំបាំងមុខក្រោមការចោទប្រកាន់ថាបានប្លន់ ហើយបានចេញដីការចាប់ខ្លួនគាត់។ បើយោងតាមអង្គការសិទ្ធិមនុស្សខ្មែរមួយ នរគបាលអនុវត្តដីការ នៅពេលជនរងគ្រោះត្រូវបានបាញ់ ហើយបន្ទាប់មក ត្រូវបានបោះបង់ចោល។ នៅ

ពេលក្រោយមក ជនរងគ្រោះបានស្លាប់។ តាមសេចក្តីរាយការណ៍មកថា គ្មានការស៊ើបអង្កេតទៅលើការបាញ់ប្រហារនោះទេ។

នៅថ្ងៃទី ១៦ ខែមេសា សុខ រី អនុប្រធាននគរបាលឃុំត្រពាំងថ្លុង ក្នុងខេត្តកំពង់ចាម បានបាញ់ជនសង្ស័យជាចោរប្លន់ឈ្មោះ ហម វណ្ណដា ក្នុងការប៉ុនប៉ងចាប់ខ្លួនមួយ។ គ្រួសាររបស់ជនរងគ្រោះបានដាក់ពាក្យប្តឹងទៅតុលាការខេត្ត។ នៅដំណាច់ឆ្នាំ ករណីនោះនៅមិនទាន់បានត្រូវគេចាត់ការទៅលើនៅឡើយ ហើយអនុប្រធាននគរបាលនោះនៅតែមានសេរីភាពនៅឡើយ។

នៅថ្ងៃទី ២៦ ខែមេសា សកម្មជនក្នុងឃុំ ឈ្មោះ ពេជ្រ សោភ័ណ្ឌ ត្រូវបានបាញ់សំលាប់នៅមុខផ្ទះរបស់គាត់ នៅស្រុកសំឡូត ខេត្តបាត់ដំបង ដោយមនុស្សមួយក្រុមដែលគេមិនស្គាល់។ យោងទៅតាមអង្គការសិទ្ធិមនុស្សក្នុងស្រុកមួយ ជនរងគ្រោះគឺជាអ្នកដឹកនាំដ៏សកម្មមួយ ក្នុងជំលោះដីធ្លីក្នុងឃុំរបស់គាត់ជាមួយអាជ្ញាធរមូលដ្ឋាន យោធា និងក្រុមហ៊ុនឯកជនមួយ។ នគរបាលបានស្រាវជ្រាវការសំលាប់នោះតែមិនបានបញ្ចេញព័ត៌មានស្តីពីការស៊ើបអង្កេតនោះទេ។

នៅថ្ងៃទី ២០ ខែកក្កដា សាលាឧទ្ធរណ៍បានដំកល់សាលក្រមរបស់តុលាការខេត្តតាកែវ ដែលបានច្រានចោលបណ្តឹងរបស់គ្រួសារអ្នកទោសឈ្មោះ ម៉ៅ សុខ ដែលបានស្លាប់នៅខែមិនា ឆ្នាំ ២០០៩ នៅពេលកំពុងត្រូវបានឃុំខ្លួនក្នុងមន្ទីរជលផលខេត្តតាកែវ។

គ្មានការវិវឌ្ឍនៅក្នុងករណីដូចតទៅនេះទេ៖ ការស្លាប់របស់ឈ្មោះ គង់ ឡានៅខែមេសាឆ្នាំ ២០០៩ នៅពេលជាប់ឃុំឃាំងរបស់នគរបាលស្រុកមោង ឫស្សី នៃខេត្តបាត់ដំបង។ ការស្លាប់នៅខែមិថុនា ឆ្នាំ ២០០៩ នៃឈ្មោះ លឿង សារឿន ដែលត្រូវបានវាយដោយទាហានម្នាក់ក្នុងកងពលតូចអន្តរាគមលេខ ១៤ ក្នុងខេត្តពោធិសាត់ និងការស្លាប់របស់ឈ្មោះ សយ សុខខន នៅខែកក្កដា ឆ្នាំ ២០០៩ ដែលត្រូវបានបាញ់សំលាប់ដោយទាហានមន្ត្រីកងរាជអាវុធហត្ថម្នាក់ នៅភ្នំពេញ។

គ្មានការវិវឌ្ឍនៅក្នុងករណីដូចតទៅនេះ៖ ការស្លាប់របស់ឈ្មោះ ហឿន សុខសីណា នៅខេត្តព្រះវិហារ បណ្តាលមកពីការវាយដោយកំលាំងសន្តិសុខរបស់អ្នកភូមិម្នាក់ នៅខេត្តព្រះវិហារ។ ការស្លាប់របស់អ្នកឈរមើលម្នាក់ នៅភ្នំពេញ ដោយការបាញ់របស់មន្ត្រីកងរាជអាវុធហត្ថម្នាក់ ការស្លាប់របស់អតីតសកម្មជនគណបក្សប្រជាជន ឈ្មោះ ជាង សំ (Cheang Sorm) និងអនុប្រធាន ម្នាក់របស់ គណបក្សនរោត្តមរណឫទ្ធិ ឈ្មោះ សុខ រុន ឬការសំលាប់អ្នកកាសែតឈ្មោះ ឃឹម សំបូរ និងកូនប្រុសរបស់លោក។

គ្រាប់មីនពីសម័យជម្លោះឥណ្ឌូចិន និងសម័យខ្មែរក្រហមនៅតែបង្កគ្រោះថ្នាក់ ។ យោងតាមប្រព័ន្ធព័ត៌មានស្តីពីជនរងគ្រោះដោយសារគ្រាប់មីន/យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះកាលពីខែមករា ដល់ខែវិច្ឆិកា គ្រាប់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ បង្កអោយមនុស្សស្លាប់ចំនួន ៧០នាក់ ពិការចំនួន ៥១ នាក់ និងរបួសផ្សេងៗចំនួន ១៤៩ ករណី ។ អាជ្ញាធរទទួលបន្ទុកផ្នែកជំនួយដល់ជនរងគ្រោះ និងសកម្មភាពមីនកម្ពុជារបស់រដ្ឋាភិបាលបានបន្តចាត់វិធានការការពារគ្រោះថ្នាក់ដល់ជនស៊ីវិលដោយសារគ្រាប់មីន និងយុទ្ធភណ្ឌមិនទាន់ផ្ទុះ ដោយរួមមានកម្មវិធីបោសសំអាតគ្រាប់មីន និងចែកចាយឯកសារស្តីពីការការពារ ដូចជាខិតប័ណ្ណ សៀវភៅ និងស្លាកសញ្ញា។ ព័ត៌មានស្តីពីគ្រោះថ្នាក់គ្រាប់មីន និងយុទ្ធភណ្ឌមិនទាន់ផ្ទុះគឺជាផ្នែកចាំបាច់នៃកម្មវិធីសិក្សារបស់សិស្ស នៅសាលារដ្ឋ ហើយអង្គភាពសកម្មភាពមីននៅតាមខេត្តបានធ្វើការប្រជុំទៀងទាត់ជាមួយអ្នកភូមិនៅតាមថ្នាក់ឃុំ និងភូមិ ដើម្បីចែករំលែកព័ត៌មាន។

នៅថ្ងៃទី ២៥ ខែមិនា ហ្វូងមនុស្សចោមវាយប្រហារលើបុរស ៣ នាក់ ក្រោយពីគេនិយាយថាបុរសទាំង ៣ នាក់បានវាយនារី ២ នាក់ ដើម្បីប្លន់ម៉ូតូ នៅភ្នំពេញ។ បើតាមរបាយការណ៍របស់អ្នកសារព័ត៌មានដំបូងនគរបាលដេញ ហើយចាប់បានបុរសសង្ស័យទាំង ៣ នាក់នោះ តែបន្ទាប់មក មនុស្សជាង ៤០០ នាក់បានយកពួកគេចេញពីកន្លែងឃុំឃាំងរបស់នគរបាល ហើយវាយពួកគេដោយប្រើដំបង ដែកបំពង់ទីប ហើយនិងថ្ម ដោយបានសំលាប់ ២ នាក់។ នៅពេលនោះ នគរបាលឈរមើល។ បុរសទី ៣ ឈ្មោះ សុខ សៀក ដែលហ្វូងមនុស្សចោមវាយបានចាកចេញដោយគិតថាឈ្មោះនេះបានស្លាប់ហើយនោះ បានដឹងខ្លួនឡើងវិញ ហើយនគរបាលបានចាប់ខ្លួនគាត់ ដោយចោទប្រកាន់ថា បានប្លន់។ នគរបាលបានប្រកាសថា គេមិនអាចស៊ើបអង្កេតហឹង្សារបស់ហ្វូងមនុស្សនោះទេ ពីព្រោះមានមនុស្សចូលរួមច្រើនពេក ហើយមិនអាចកំណត់បានថាតើនរណាជាអ្នកទទួលខុសត្រូវ ទោះបីជាមានរូបថតនៃការវាយប្រហារក្តី។

ក្នុងឆ្នាំនេះ អង្គការក្នុងស្រុកបានរាយការណ៍ពីករណីហ្វូងមនុស្សចោមវាយសំលាប់ដទៃទៀតយ៉ាងហោច ណាស់ចំនួន ២។

គ្មានការវិវឌ្ឍន៍ទេក្នុងករណីសំលាប់កាលពីខែកុម្ភៈ ឆ្នាំ ២០០៩ លើឈ្មោះ ហង្ស ហឿន (Hang Heoun) ដែលត្រូវបានចោទប្រកាន់ថា ចេះធ្វើធ្មប់ នៅស្រុកសណ្តាន់ ខេត្តកំពង់ធំ។ ជនទាំង ៧ នាក់ដែលរងការចោទប្រកាន់ថាបានប្រព្រឹត្តការកាប់សំលាប់ នៅស្ថិតក្នុងការឃុំខ្លួនដោយមិនទាន់បាន ទទួលការជំនុំជំរះនៅឡើយទេ ហើយថ្ងៃខែបើកសវនាការក៏មិនទាន់ត្រូវបានកំណត់ដែរ។

គ្មានការវិវឌ្ឍក្នុងករណីហ្វូងមនុស្សចោមវាយសំលាប់មនុស្សក្នុងករណីពីរ ដែលត្រូវបានរាយការណ៍ នៅឆ្នាំ ២០០៩ ឬករណី ២ ទៀតនៅឆ្នាំ ២០០៨ ទេ។

**ខ. ការបាត់ខ្លួន**

គ្មានរបាយការណ៍អំពីការបាត់ខ្លួនដោយមូលហេតុនយោបាយនោះទេ ។

**គ. ទារុណកម្ម ការប្រព្រឹត្ត ឬទណ្ឌកម្មឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាបដទៃទៀត**

រដ្ឋធម្មនុញ្ញហាមឃាត់ចំពោះទង្វើដូចពោលទាំងនេះ ។ ទោះជាយ៉ាងណាក៏ដោយ ការវាយដំ និងការប្រព្រឹត្តមិនគប្បី លើរូបរាងកាយក្នុងទម្រង់ដទៃទៀតចំពោះជនដែលត្រូវឃាត់ខ្លួនដោយនគរបាល និងអ្នកជាប់ពន្ធនាគារ នៅតែ មានជាបន្តទោះបីចំនួនឧប្បត្តិហេតុបានថយចុះយ៉ាងច្រើនពីឆ្នាំ ២០០៩ ក្តី ។

មានរបាយការណ៍ដែលអាចទុកចិត្តបានជាច្រើនថា មន្ត្រីកងរាជអាវុធហត្ថ និងនគរបាលស៊ីវិលបាន ប្រើទារុណកម្មលើរាងកាយ និងផ្លូវចិត្ត ហើយមានពេលខ្លះវាយដំយ៉ាងធ្ងន់ធ្ងរទៅលើជនដែលត្រូវ ឃុំខ្លួន ដោយសារបទព្រហ្មទណ្ឌទៀតផង ជាពិសេសនៅអំឡុងពេលសួរចម្លើយ ។ នៅអំឡុងឆ្នាំនេះ អង្គការមិន មែនរដ្ឋាភិបាលបានរាយការណ៍ថា អាជ្ញាធរត្រូវបានចោទ ប្រកាន់ថាបានធ្វើទារុណកម្មយ៉ាងហោចណាស់ ទៅលើអ្នកជាប់ពន្ធនាគារចំនួន ១១១នាក់ ៖ ៩៣ នាក់នៅក្រោមការឃុំខ្លួនរបស់នគរបាល និង១៨ នាក់ទៀត នៅក្នុងពន្ធនាគារ ។ ការទាត់ធាក់ ការដាល់ និងការវាយវាត់ដោយកាំភ្លើងខ្លីគឺជាវិធីរំលោភបំពាន លើរូបរាង កាយដែលកើតមានឡើងច្រើនបំផុត ប៉ុន្តែបច្ចេកទេសធ្វើទារុណកម្មនេះក៏មានបញ្ចូលការឆក់ខ្សែភ្លើង ការធ្វើ អោយថប់ដង្ហើម និងការវាយនឹងខ្សែភ្លើងផងដែរ ។ អង្គការ NGO នានា រាយការណ៍ថាជារឿងធម្មតា ដែល នគរបាលធ្វើទារុណកម្មលើជនសង្ស័យ ដែលត្រូវឃុំខ្លួនរហូតទាល់តែអ្នកទាំងនេះសារភាពថាបានប្រព្រឹត្ត កំហុសណាមួយ ។ តុលាការប្រើប្រាស់ការសារភាពដោយបង្ខំធ្វើជាភស្តុតាងស្របច្បាប់នៅអំឡុងពេលជំនុំ ជម្រះក្តី ទោះបីជាបានសារភាពថា ការធ្វើបែបនេះមិនត្រូវបានអនុញ្ញាតអោយប្រើប្រាស់ តាមច្បាប់ក៏ដោយ ។

នៅថ្ងៃទី ៥ ខែកុម្ភៈ មនុស្ស ២ នាក់បាននិយាយថា នគរបាលស្រុកស្វាយជ្រុំបានវាយពួកគេ នៅ ពេលពួកគេស្ថិតក្រោមការឃុំខ្លួនរបស់នគរបាល ដើម្បីអោយឆ្លើយសារភាពថាបានប្លន់ ដែលជាការដែល ពួកគេមិនបានធ្វើទេ។ បន្ទាប់មកនគរបាលបានដោះលែងពួកគេវិញ ដោយមិនធ្វើការចោទប្រកាន់។ គ្មានការ ស៊ើបអង្កេតទៅលើការអះអាងរបស់ពួកគេទេ។

នៅថ្ងៃទី ១៥ ខែឧសភា នគរបាលឃុំត្នោតជ្រុំ ៣ នាក់ត្រូវបានគេនិយាយថា បានវាយ និងឆក់ខ្សែភ្លើងដល់មនុស្សម្នាក់ ដើម្បីអោយឆ្លើយសារភាពពីការវាយតប់គ្នានៅតាមផ្លូវ។ ជនរងគ្រោះដែលបានរងរបួសយ៉ាងធ្ងន់ ហើយសន្លប់ បានអះអាងថាខ្លួនមិនបានជាប់ពាក់ព័ន្ធក្នុងការវាយតប់គ្នានោះទេ។ គាត់បានដាក់ពាក្យបណ្តឹងទៅតុលាការខេត្ត ដែលបានធ្វើការចោទប្រកាន់លើនគរបាលឃុំម្នាក់។ នៅដំណាច់ឆ្នាំ ករណីនោះមិនទាន់ត្រូវបានចាត់ការនៅឡើយ ហើយថ្ងៃខែសវនាការក៏មិនត្រូវបានកំណត់។ នគរបាលម្នាក់នោះនៅមានសេរីភាពនៅឡើយ។

មនុស្សប្រាំនាក់មកពីភូមិទំនប់ទឹក ដែលបានរាយការណ៍ នៅឆ្នាំ ២០០៩ ថា មានកងរាជអាវុធហត្ថមកពីស្រុកបាវិល ខេត្តបាត់ដំបង បានវាយដំ ទាត់ធាក់ និងឆក់ខ្សែភ្លើងលើពួកគេ ដើម្បីបង្ខំអោយសារភាពចំពោះបទប្លន់មួយ ដែលសាម៉ីខ្លួនបានអះអាងថាមិនបានប្រព្រឹត្ត បានស្ថិតនៅក្នុងពន្ធនាគារនៅឡើយ ទោះបីជាត្រូវបានលើកលែងការចោទប្រកាន់ពីបទប្លន់ ដោយតុលាការខេត្តបាត់ដំបងក្តី។ ព្រះរាជអាជ្ញាបានប្តឹងឧទ្ធរណ៍ចំពោះការលើកលែងការចោទប្រកាន់នោះ ហើយនៅដំណាច់ឆ្នាំថ្ងៃខែសំរាប់បើកសវនាការមិនទាន់ត្រូវបានកំណត់នៅឡើយ។

អង្គការ ADHOC បាននិយាយថា មានការបង្ករបួសស្នាមចំនួន ៨៩ ករណី ទៅលើជនស៊ីវិលដោយអាជ្ញាធរដែនដី ភ្នាក់ងាររដ្ឋាភិបាល ឬអង្គរក្សឯកជន ដែលធៀបនឹងឆ្នាំ២០០៩ មានចំនួន១០០ករណី ។

មានមជ្ឈមណ្ឌលបន្សាំថ្នាំញៀនរបស់រដ្ឋាភិបាលចំនួន ១១។ អ្នកសង្កេតការភាគច្រើនបានយល់ស្របថា ភាគច្រើននៃអ្នកដែលត្រូវបានយកមកឃុំនៅទីនេះគឺត្រូវបានឃុំដោយបង្ខំ ឬផ្ញើនៅមណ្ឌលដោយសមត្ថកិច្ច ឬសមាជិកគ្រួសារ ហើយយល់ស្របផងដែរថា ប្រហែល ១ ភាគ ៣ នៃអ្នកដែលជាប់នៅក្នុងមណ្ឌលមានអាយុក្រោម ១៨ ឆ្នាំ។ បុគ្គលិកក្នុងមណ្ឌលជាញឹកញាប់ប្រើវិធីបង្ខំ ដើម្បី “គ្រប់គ្រង” ទៅលើអ្នកជាប់ក្នុងនោះ ដូចជាចងពួកគេ ឬអោយហាត់ប្រាណយ៉ាងខ្លាំង ឬប្រើខ្សែភ្លើងឆក់។ ថ្នាក់ដឹកនាំរដ្ឋាភិបាលទទួលស្គាល់សារៈសំខាន់នៃការព្យាបាលការញៀនថ្នាំដែលត្រូវបានចាត់ទុកថា ជារឿងសុខភាព ជាជាងរឿងព្រហ្មទណ្ឌ តែត្រូវបានគេនិយាយថា មិនមានចាត់វិធាការច្រើនដូចការនិយាយនោះទេ។

ផ្ទុយនឹងឆ្នាំ ២០០៩ គ្មានសេចក្តីរាយការណ៍ថាអាជ្ញាធរបានបង្ខំអោយអ្នកញៀនគ្រឿងញៀន ទទួលយកការព្យាបាលជាមួយនឹងឱសថបូរាណដែលគេហៅថាបង់សែន ដោយគ្មានការយល់ព្រមត្រឹមត្រូវទេ។

គ្មានការវិវត្តន៍ថ្មីក្នុងករណីដែលត្រូវបានរាយការណ៍នៅឆ្នាំ ២០០៨ ស្តីពីការរំលោភលើអ្នកជាប់ក្នុងមណ្ឌលដោយមន្ត្រីរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (MOSAVY) ឡើយ។

នៅដំណាច់ឆ្នាំនេះ មជ្ឈមណ្ឌលមួយនៅបិទទ្វារនៅឡើយ ចំណែកឯមជ្ឈមណ្ឌលមួយទៀតកំពុងតែត្រូវបានប្រើប្រាស់សំរាប់អ្នកគ្មានផ្ទះសម្បែង អ្នកញៀនថ្នាំ និងស្ត្រីបំរើផ្លូវភេទ។

## ស្ថានភាពពន្ធនាគារ និងមជ្ឈមណ្ឌលឃុំខ្លួន

ស្ថានភាពពន្ធនាគារមិនសមស្របតាមបទដ្ឋានអន្តរជាតិឡើយ ។ ស្ថានភាពជាច្រើននៅតែមានលក្ខណៈយ៉ាប់ និងគម្រាមកំហែងដល់អាយុជីវិតទៀតផង ។ កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលដើម្បីកែលម្អស្ថានភាពពន្ធនាគារ តែនៅពេលខ្លះបន្តជួបឧសគ្គដោយសារកង្វះថវិកា និងការពង្រឹងច្បាប់ដែលនៅមានភាពទន់ខ្សោយ ។ អង្គការសិទ្ធិមនុស្សនានាបានលើកឡើងអំពី បញ្ហាធ្ងន់ធ្ងរមួយចំនួន រួមមានដូចជាស្ថានភាពចង្អៀតណែនខ្លាំងពេក បញ្ហាសុខភាព ព្រមទាំងអនាម័យបរិស្ថាន កង្វះចំណីអាហារ និងទឹក កង្វះអាហារូបត្ថម្ភនិងសន្តិសុខមិនល្អ ។

យោងតាមនាយកដ្ឋានពន្ធនាគារនៃក្រសួងមហាផ្ទៃ (MOI) មានអ្នកទោស និងអ្នកជាប់ ពន្ធនាគារចំនួន ១៤ ០៤៣ នាក់ ដែលក្នុងនោះមានស្ត្រីចំនួន ៩១៥ នាក់ និងកុមារចំនួន ៧៧២ នាក់ ។ មានពន្ធនាគារចំនួន ២៥ នៅទូទាំងប្រទេសដែលបានបង្កើតឡើងដើម្បីដាក់អ្នកជាប់ពន្ធនាគារ និងអ្នកជាប់ឃុំពី ៨.០០០នាក់ទៅ ១១.០០០នាក់ ។ មានរបាយការណ៍ដែលលើកឡើងថា នៅក្នុងពន្ធនាគារមួយចំនួន បន្ទប់ ដែលមានទំហំ ៤០ គុណនឹង ២០ហ្វីត បានដាក់អ្នកជាប់ពន្ធនាគាររហូតដល់ទៅ ១១០ នាក់ ។ នៅមជ្ឈមណ្ឌលអប់រំកែប្រែទី ១ បន្ទប់ពន្ធនាគារដែលមានទំហំ ២៦ គុណនឹង២៦ ហ្វីត ដាក់អ្នកជាប់ពន្ធនាគារជាមធ្យមចំនួន ៥០នាក់ ។ នៅពន្ធនាគារខ្លះ អាជ្ញាធរបានប្រើប្រាស់ ខ្នោះជើង និងដាក់អ្នកជាប់ពន្ធនាគារនៅក្នុងបន្ទប់តូចងងឹតធ្វើជាទម្រង់ទណ្ឌកម្ម ។

នាយកដ្ឋានពន្ធនាគារបានរាយការណ៍ថា យ៉ាងហោចណាស់មានអ្នកជាប់ពន្ធនាគារចំនួន ៨៣ នាក់បានស្លាប់ក្នុងពន្ធនាគារ។ នគរបាលបានអះអាងថា គេបានធ្វើការស៊ើបអង្កេត ហើយបានរកឃើញថា ការស្លាប់គឺបណ្តាលមកពីការមានជំងឺពីមុនមក ឬជំងឺដទៃទៀត។

នៅថ្ងៃទី ២១ ខែមករា តុលាការក្រុងភ្នំពេញបានបដិសេធបណ្តឹងស្តីពីការស្លាប់ដោយមិនត្រឹមត្រូវរបស់គ្រួសារអ្នកទោសឈ្មោះ ហេង ទូច ដែលបានស្លាប់ នៅឆ្នាំ ២០០៨ ក្រោយពីទទួលរងរបួសនៅក្នុងពន្ធនាគារក្នុងស្ថានភាពគួរអោយសង្ស័យ ។គ្រួសារពុំបានប្តឹងឧទ្ធរណ៍ទេ។

ពុំមានការវិវត្តន៍ក្នុងការស្លាប់របស់អ្នកទោសឈ្មោះ យ៉ាន់ សុខគា និង ប៊ុន វណ្ណារិទ្ធ ដែលបានស្លាប់ នៅកន្លែងឃាត់ខ្លួនរបស់នគរបាល ឬមរណភាពរបស់ស្ត្រីជរាម្នាក់ ដែលត្រូវបានបង្ខាំងនៅក្នុងមជ្ឈមណ្ឌល ស្តារនីតិសម្បទារបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។

រដ្ឋាភិបាលបានបង្កើនរបបអាហារសម្រាប់អ្នកជាប់ពន្ធនាគារ និងរបស់ចាំបាច់ផ្សេងៗទៀត តែនៅ តែមិនគ្រប់គ្រាន់នៅឡើយ។ អ្នកសង្កេតការណ៍បានបន្តរាយការណ៍ថា របបសំរាប់ទិញអាហារសំរាប់អ្នក ទោស ពេលខ្លះត្រូវបានកិបកេងយក ដែលជាធ្វើអោយកង្វះអាហារូបត្ថម្ភ និងជំងឺអ្នកទោសមានកាន់តែ ច្រើន។

ក្នុងពន្ធនាគារភាគច្រើន គ្មានការដាក់នៅអោយដាច់ពីគ្នារវាងអ្នកទោសជាមនុស្សធំ និងអ្នកទោស ជាកុមារ អ្នកទោសជាបុរស និងអ្នកទោសជានារី ឬអ្នកទោសកំរិតធ្ងន់ និងអ្នកទោសកំរិតស្រាល អ្នកជាប់ ឃុំមុនឡើងសវនការ ជាធម្មតា ត្រូវបានដាក់អោយនៅជាមួយអ្នកទោសដែលត្រូវបានតុលាការកាត់ទោស ហើយ។ យោងតាមស្ថិតិរបស់រដ្ឋាភិបាល អ្នកទោសប្រមាណ ៣៤% នៅតាមពន្ធនាគារខេត្ត ក្រុងគឺជាអ្នក ជាប់ទោសដែលមិនទាន់ចូលសវនាការ។

អ្នកទោស និងអ្នកជាប់ឃុំត្រូវបានអនុញ្ញាតជាធម្មតាអោយជួបអ្នកទៅជួប តែអង្គការសិទ្ធិមនុស្ស បានអះអាងថាពេលខ្លះ គ្រួសារត្រូវផ្តល់សំណូកដល់មន្ត្រី ពន្ធនាគារដើម្បីសួរសុខទុក្ខអ្នកជាប់ពន្ធនាគារ ឬផ្តល់ស្បៀងអាហារ និងរបស់របរចាំបាច់ដទៃ ទៀត ។ អង្គការមិនមែនរដ្ឋាភិបាលនានា ក៏បានអះអាងពី ដំណើររឿងថាអ្នកជាប់ពន្ធនាគារដែល គ្រួសាររបស់ខ្លួនបានផ្តល់ សំណូកដល់អាជ្ញាធរពន្ធនាគារបានទទួល ការអនុគ្រោះ រួមមានដូចជាអាចជួបអ្នកមកសួរសុខទុក្ខការផ្ទេរទៅក្នុងបន្ទប់ប្រសើរជាងមុន និងឱកាសចាក ចេញពីក្នុងបន្ទប់នៅពេលថ្ងៃជាដើម ។

មានរបាយការណ៍គួរអោយជឿទុកចិត្តបានថា ជាញឹកញាប់ មន្ត្រីបានទាមទារប្រាក់សំណូកមុននឹង អនុញ្ញាតអោយ អ្នកជាប់ពន្ធនាគារចូលរួមការជំនុំជម្រះក្តី ឬសវនការឧទ្ធរណ៍ និងមុនពេលដោះលែងអ្នកជាប់ ពន្ធនាគារដែលបាន បញ្ចប់អាណត្តិជាប់ពន្ធនាគាររបស់ខ្លួនពេញលេញហើយនោះ ។

អ្នកទោស និងអ្នកជាប់ឃុំត្រូវបានអនុញ្ញាតអោយគោរពសាសនារបស់គេ។

បណ្តឹងស្តីពីការរំលោភបំពានអាចបញ្ជូនទៅតុលាការ តាមរយៈមេធាវី ដោយមិនមានការត្រួតពិនិត្យ កែប្រែឡើយ។ តែអ្នកទោសមួយចំនួនធំគ្មានលទ្ធភាពរកមេធាវីតំណាងឡើយ។ រដ្ឋាភិបាលស៊ើបអង្កេតលើ

ពាក្យបណ្តឹងបែបនេះ ហើយតាមមើលស្ថានភាពពន្ធនាគារ និងមជ្ឈមណ្ឌលឃុំឃាំង តាមរយៈអគ្គនាយកដ្ឋានពន្ធនាគាររបស់ក្រសួងមហាផ្ទៃ ដែលធ្វើរបាយការណ៍ប្រចាំឆមាសស្តីពីការគ្រប់គ្រងនិងការកែលំអពន្ធនាគារនៅក្នុងប្រទេស។ របាយការណ៍ទាំងនេះ និងរបាយការណ៍ស៊ើបអង្កេតដទៃទៀតត្រូវបានគេនិយាយថាសាធារណជនអាចមើលបាន បើគេស្នើសុំ។

ជាទូទៅរដ្ឋាភិបាលនៅបន្តអនុញ្ញាតអោយក្រុមសិទ្ធិមនុស្សអន្តរជាតិ និងក្នុងស្រុក ដូចជាគណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ និងការិយាល័យឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (UNHCHR) ចូលមើលពន្ធនាគារ និងផ្តល់ការបណ្តុះបណ្តាលសិទ្ធិមនុស្សដល់ឆ្មាំពន្ធនាគារ។ អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនបានរាយការណ៍ថា ជួនកាលកិច្ចសហការពីអាជ្ញាធរដែនដីនៅមានកម្រិតដែលជាការធ្វើអោយមានការលំបាកសម្រាប់ទាក់ទងអ្នកជាប់ឃុំមុនពេលជំនុំជម្រះក្តី។ ក្រសួងមហាផ្ទៃនៅតែបន្ត តម្រូវអោយមេធាវី អ្នកត្រួតពិនិត្យសិទ្ធិមនុស្ស និងអ្នកសួរសុខទុក្ខដទៃទៀតសុំការអនុញ្ញាតមុននឹងទៅសួរសុខទុក្ខអ្នកជាប់ពន្ធនាគារ ។ ក្រសួងមិនព្រមផ្តល់ការអនុញ្ញាតនេះទេនៅក្នុងករណីរសើបផ្នែកនយោបាយខ្លះ ។ ក្នុងករណីខ្លះ មន្ត្រីនៅតែបន្តអនុញ្ញាតអោយអង្គការមិនមែនរដ្ឋាភិបាលធ្វើការសម្ភាសន៍អ្នកជាប់ពន្ធនាគារ ជាលក្ខណៈឯកជន ។ ចំណែកតំណាងអង្គការ UNHCHR វិញបានរាយការណ៍មកថាជាធម្មតាខ្លួនមានលទ្ធភាពជួបជាលក្ខណៈឯកជននៅពេលសម្ភាសន៍អ្នកជាប់ពន្ធនាគារណាម្នាក់ដែលគួរអោយចាប់អារម្មណ៍ ។

## ឃ. ការចាប់ខ្លួន ឬការឃុំខ្លួនដោយបំពាន

ច្បាប់ហាមឃាត់ការចាប់ខ្លួន និងការឃុំខ្លួនដោយបំពាន ទោះជាយ៉ាងណាក៏ដោយ មានពេលខ្លះរដ្ឋាភិបាលមិនគោរពបម្រាមទាំងនេះឡើយ ។ ក្រមនីតិវិធីព្រហ្មទណ្ឌអនុញ្ញាតអោយមានការឃុំខ្លួនមុនពេលជំនុំជម្រះក្តីរហូតដល់រយៈពេល ៦ខែសម្រាប់បទមជ្ឈឹម និង ១៨ខែសម្រាប់បទឧក្រិដ្ឋ ។ អ្នកជាប់ឃុំម្នាក់ក្នុងចំណោម ១០នាក់នៅក្នុងការឃុំខ្លួនមុនពេលជំនុំជម្រះក្តី ត្រូវជាប់ឃុំលើសពីអាជ្ញាយុកាលជួនកាលដោយគ្មាន តំណាងផ្នែកច្បាប់ (មេធាវី) ឬការជំនុំជម្រះក្តីឡើយ ។ ក្រសួងមហាផ្ទៃបានរាយការណ៍ថាមានមនុស្សចំនួន ២១០ នាក់ស្ថិតនៅក្នុងការឃុំខ្លួនមុនពេលជំនុំជម្រះក្តី ដែលលើសពីអាជ្ញាយុកាលអនុញ្ញាតចំពោះបទល្មើសដែលត្រូវបាន ចោទប្រកាន់ ។ លើសពីនេះទៀត តុលាការខ្លះបានបាត់សំណុំឯកសារ ក្នុងអំឡុងពេលនៃការឃុំខ្លួនមុនសវនាការ ដែលជាការពន្យារនីតិវិធីតុលាការ។

អង្គការ ADHOC បានរាយការណ៍អំពីការចាប់ខ្លួន ឬការឃុំខ្លួនខុសច្បាប់យ៉ាងហោច ៧៥ ករណី នៅអំឡុងឆ្នាំ នេះ ។ អង្គការ ADHOC បានថ្លែងថាជនរងគ្រោះនៅក្នុងករណីឃុំខ្លួនខុសច្បាប់ចំនួន ២១ ករណីក្រោយមកត្រូវបាន ដោះលែងអោយមានសេរីភាពបន្ទាប់ពីមានការប្តឹងតវ៉ារបស់ជនជាប់ឃុំ អន្តរាគមពីអង្គការមិនមែនរដ្ឋាភិបាល ផ្នែកសិទ្ធិមនុស្ស ឬការបង់ប្រាក់សំណូក ។ អង្គការ ADHOC មានជំនឿថា ចំនួនជាក់ស្តែងនៃការចាប់ខ្លួន និង ការឃុំខ្លួនដោយបំពានមានច្រើនជាងនេះ ដោយសារជនរងគ្រោះមួយចំនួននៅតំបន់ជនបទមិនបានដាក់បណ្តឹងតវ៉ា ដោយសារមានការលំបាកក្នុងការធ្វើដំណើរទៅកាន់ការិយាល័យអង្គការមិនរដ្ឋាភិបាល ឬដោយសារភ័យខ្លាចចំពោះសន្តិសុខគ្រួសារ ។ ដោយយោងតាមអង្គការ ADHOC អាជ្ញាធរ មិនបានចាត់វិធានការតាមផ្លូវច្បាប់ ឬ វិន័យចំពោះជនដែលទទួលខុសត្រូវចំពោះការឃុំខ្លួនខុស ច្បាប់នេះឡើយ ។

នៅអំឡុងឆ្នាំនេះ អាជ្ញាធរសាលាក្រុងភ្នំពេញបានចាប់ខ្លួនមនុស្សរាប់សិបនាក់ ដែលអ្នកទាំងនោះជាធម្មតាជាអ្នក គ្មានផ្ទះសម្បែង អ្នកមានជំងឺផ្លូវចិត្ត អ្នកប្រើប្រាស់គ្រឿងញៀន ឬអ្នកបម្រើសេវាផ្លូវភេទនៅអំឡុងពេលបោសសម្អាតដងវិថីជាលក្ខណៈប្រព័ន្ធរបស់ខ្លួន ។ អ្នកជាប់ឃុំតែងតែបាត់បង់ប្រាក់កាស និងរបស់របរទាំងអស់នៅពេល បោសសម្អាតនោះ ។ អាជ្ញាធរចាត់ទុកថាការបោសសម្អាតដងវិថីគឺជាផ្នែកមួយនៃការខិតខំដើម្បីធ្វើអោយ "សង្គមមានរបៀប" ហើយពេលខ្លះ បាននាំយកអ្នកជាប់ឃុំទាំងអស់នៅក្នុងកន្លែងស្តារនីតិសម្បទា ដែលដំណើរការដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដែលមានចម្ងាយ១៥ម៉ៃល៍ពីក្រុងភ្នំពេញ ។ អ្នកជាប់ឃុំទាំងនោះត្រូវបានគេប្រាប់ថាខ្លួនមានសេរីភាពអាចចាក ចេញបាន ប្រសិនបើខ្លួនចង់ចាកចេញ ប៉ុន្តែមិនទទួលបានមធ្យោបាយធ្វើដំណើរឡើយ ។

## តួនាទីរបស់នគរបាល និងយន្តការសន្តិសុខ

អគ្គស្នងការនគរបាលជាតិ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងមហាផ្ទៃ គ្រប់គ្រងអង្គភាពនគរបាលស៊ីវិលទាំងអស់ ។ កម្លាំងនគរបាលត្រូវបែងចែកជាកម្លាំងដែលមានអំណាចដើម្បីធ្វើការចាប់ខ្លួន កម្លាំងដែលគ្មានអំណាចចាប់ខ្លួន និងនគរបាលយុត្តិធម៌ ។ កងរាជអាវុធហត្ថទទួលបានការអនុញ្ញាតអោយចាប់ខ្លួនជនស៊ីវិល ប្រសិនបើមន្ត្រីទាំង នោះបំពេញលក្ខខ័ណ្ឌការបណ្តុះបណ្តាល និងបទពិសោធន៍ដើម្បីបំពេញការងារជានគរបាលយុត្តិធម៌ ប្រសិនបើ ជនស៊ីវិលស្ថិតនៅកន្លែងរបស់យោធា ឬក្នុងករណីទទួលបានការអនុញ្ញាតពីអាជ្ញាធរមូលដ្ឋាន ។ តែតាមភាពជាក់ស្តែង កងរាជអាវុធហត្ថធ្វើសកម្មភាព លើជនស៊ីវិលជាធម្មតា ក្រោមការអនុញ្ញាតនិងចង្អុលរបស់អាជ្ញាធរខេត្ត និងមូលដ្ឋាន។

មន្ត្រីនគរបាលបានធ្វើឃាតប្រជាពលរដ្ឋ និងប្រព្រឹត្តអំពើរំលោភបំពានផ្សេងៗដោយមាននិទណ្ឌភាព (ភាពគ្មានទោស) ហើយក្នុងករណីភាគច្រើន អាជ្ញាធរបានចាត់វិធានការបន្តិចបន្តួច ឬពុំមានចាត់វិធានការអ្វីឡើយ ។

ច្បាប់តម្រូវអោយនគរបាល ព្រះរាជអាជ្ញា និងចៅក្រមធ្វើការស៊ើបអង្កេតរាល់ពាក្យបណ្តឹងទាំងអស់ រួមទាំង បណ្តឹងអំពីការរំលោភបំពានរបស់នគរបាលផងដែរ ។ ទោះជាយ៉ាងនេះក្តី ក្នុងការអនុវត្តជាក់ស្តែង ចៅក្រម និង ព្រះរាជអាជ្ញាកម្រធ្វើការស៊ើបសួរដោយឯករាជ្យដែលជាផ្នែកមួយនៃដំណើរការជំនុំជម្រះក្តីជាសាធារណៈណាស់ ។ ចៅក្រមជំនុំជម្រះ ជាធម្មតា ចេញសាលក្រមផ្អែកតាមតែរបាយការណ៍ ជាលាយលក្ខណ៍អក្សរ ដែលទទួលបានមកពីនគរបាល និងសក្ខីកម្មរបស់សាក្សីតែប៉ុណ្ណោះ ។ ជាទូទៅ នគរបាលបានទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈបន្តិចបន្តួចតែប៉ុណ្ណោះ ។ នគរបាលដែលមិនបានទប់ស្កាត់ ឬឆ្លើយតបចំពោះអំពើហឹង្សានៅក្នុងសង្គម កម្រនឹងទទួលទណ្ឌកម្មណាស់ ។

នៅថ្ងៃទី ៧ ខែមិនា មន្ត្រីរុក្ខាប្រមាញ់ខេត្តបន្ទាយមានជ័យបានអះអាងថា មនុស្សក្នុងក្រុមគ្រួសារយោធាចំនួន ២០០ គ្រួសារបានបាញ់ទៅលើពួកគេ នៅពេលពួកគេប៉ុនប៉ងបណ្តេញគ្រួសារទាំងនោះពីតំបន់ការពារព្រៃឈើ។ ផ្នែករដ្ឋបាលព្រៃឈើបានប្រកាសកាលពីសប្តាហ៍មុននោះថា ខ្លួននឹងចាប់ខ្លួនប្រធានភូមិ និងមន្ត្រីយោធាម្នាក់ ដែលគេបានអះអាងថា បាននាំគ្រួសារទាំងនោះមករស់នៅក្នុងតំបន់ការពារ។

នៅថ្ងៃទី ៨ ខែមិនា អ្នកភូមិដែលត្រូវបានបណ្តេញកាលពីឆ្នាំ ២០០៩ ពីដីមានជំលោះ នៅឃុំក្រយ៉ា ខេត្តកំពង់ធំ បានប៉ុនប៉ងត្រឡប់មកដីស្រែចំការរបស់គេវិញ ដែលត្រូវបានបង្វែរទៅជាដីចំការកៅស៊ូដោយក្រុមហ៊ុនវៀតណាមមួយ។ នគរបាលដែលយាមចំការនោះ បានបាញ់ទៅលើអ្នកភូមិ ដោយបានធ្វើអោយរបួស ៣ នាក់ បន្ទាប់ពីអ្នកភូមិប្រើកាំបិតវាយប្រហារលើពួកគេ ដូចដែលត្រូវបានចោទប្រកាន់មក។ អាជ្ញាធរខេត្តបានអោយពួកគេទៅនៅកន្លែងថ្មី តែអ្នកភូមិបានអះអាងថា គេមិនបានទទួលដីដែលសមស្របសំរាប់ការដាំដុះឡើយ។

នៅថ្ងៃទី ២០ ខែសីហា តុលាការខេត្តសៀមរាប បានដាក់ទោសលើអ្នកភូមិចំនួន ៩ នាក់ នៅឃុំជីក្រែងពីបទបង្កើតកំលាំងប្រដាប់អាវុធដោយខុសច្បាប់ ហើយអោយពួកគេជាប់ពន្ធនាគារចំនួន ៣ ឆ្នាំ។ តុលាការបានដាក់ទោសអ្នកភូមិ ៣ នាក់ទៀត ដែលមកពីឃុំដដែលនោះ ពីបទប៉ុនប៉ងចាប់ឃុំមន្ត្រីតុលាការ ហើយបានដាក់ទោសអោយពួកគេជាប់ពន្ធនាគារចំនួន ៣ ឆ្នាំ។ អ្នកភូមិទាំងនោះត្រូវបានចាប់ខ្លួននៅខែមិនា ឆ្នាំ ២០០៩ នៅក្នុងជំលោះដីធ្លីមួយ ដែលក្នុងនោះនគរបាលបានបាញ់ទៅលើហ្វូងអ្នកតវ៉ា ដោយបានធ្វើអោយ

របួស ៣ នាក់។ តុលាការបានកែប្រែសាលក្រមដាក់ទោសទៅលើអ្នកភូមិទាំង ១២ នាក់មកត្រឹម ១៧ ខែវិញ ដែលស្មើនឹងរយៈពេលដែលបានជាប់ហើយ តែអ្នកភូមិស្ថិតនៅក្នុងពន្ធនាគារនៅឡើយ ដោយនៅរង់ចាំលទ្ធភាពនៃការប្ដឹងឧទ្ធរណ៍ដោយព្រះរាជអាជ្ញា ឬត្រូវប្រឈមនឹងការចោទប្រកាន់បន្ថែម។ ទោះបីមានការអំពាវនាវរបស់ក្រសួងយុត្តិធម៌អោយអាជ្ញាធរខេត្តចាត់វិធានការប្រឆាំងនឹងអ្នកដែលបានបាញ់នៅក្នុង ករណីនោះក្ដី តែរហូតមកដល់ដំណាច់ឆ្នាំ គេមិនឃើញមានការចាត់វិធានការអ្វីឡើយ។

ពុំមានការវិវឌ្ឍក្នុងករណីកាលពីខែមិថុនា ឆ្នាំ ២០០៩ ដែលក្នុងនោះ នគរបាលខេត្តរតនៈគីរីម្នាក់បានបាញ់អោយរបួសអ្នកភូមិម្នាក់ ក្នុងការតវ៉ាមួយលើសម្បទានដីសេដ្ឋកិច្ច។

ពុំមានការវិវឌ្ឍនៅក្នុងករណីរបស់លោកវរសេនីយត្រី មឿ បូរ៉ា នៃកងពលតូចលេខ៧០ នៅឆ្នាំ ២០០៨ ដែលតាម របាយការណ៍មកថា បាន វាយដំបុរសពីរនាក់ក្រោយពីមានគ្រោះថ្នាក់ចរាចរណ៍ បន្តិចបន្តួច ឬនៅក្នុងករណីកាលពី ឆ្នាំ២០០៨ អំពីអង្គរក្សរដ្ឋាភិបាលដែលរងការចោទប្រកាន់ថា បានបាញ់សម្លាប់ស្ត្រីម្នាក់នៅក្នុងវង្គសាលមួយនោះ ។

## **នីតិវិធីចាប់ខ្លួន និងការប្រព្រឹត្តនៅពេលឃុំខ្លួន**

ច្បាប់តម្រូវអោយនគរបាលសុំដីកាពីចៅក្រមស៊ើបអង្កេតមុនពេលធ្វើការចាប់ខ្លួន ប៉ុន្តែនគរបាលអាចចាប់ខ្លួនដោយគ្មាន ដីកាចំពោះជនណាដែលត្រូវបានប្រទះឃើញកំពុងប្រព្រឹត្តបទល្មើស ។ ច្បាប់អនុញ្ញាតអោយនគរឃាត់ខ្លួនបុគ្គលណាម្នាក់ រួចធ្វើការស៊ើបសួរក្នុងរយៈពេល២៤ម៉ោងដោយមិនរាប់បញ្ចូលរយៈពេលចុងសប្ដាហ៍ និងថ្ងៃឈប់សម្រាក ផ្លូវការ មុននឹងធ្វើការចោទប្រកាន់ ។ ក្នុងករណីបទឧក្រិដ្ឋក្នុងស្ថានភាពពិសេសដែលចែងដោយច្បាប់ នគរបាល អាចឃុំខ្លួនជនសង្ស័យរយៈពេល ២៤ម៉ោងបន្ថែមដោយមានការឯកភាពពីព្រះរាជអាជ្ញា ។ ទោះជាយ៉ាងនេះក្ដី ជាទម្លាប់អាជ្ញាធរតែងតែឃុំខ្លួនមនុស្សហួសរយៈពេលកំណត់មុននឹងធ្វើការចោទប្រកាន់ ។ មានវិធីនៃការធានាអោយនៅក្រៅឃុំ តែអ្នកជាប់ពន្ធនាគារ ជាច្រើន ជាពិសេសអ្នកដែលគ្មានតំណាងផ្នែកច្បាប់ ឬមេធាវី គ្មានឱកាសស្វែងរកការដោះលែងដោយការធានា អោយនៅក្រៅឃុំឡើយ ។ តាមក្រមនីតិវិធីព្រហ្មទណ្ឌ ជនជាប់ចោទ អាចត្រូវបានចាប់ខ្លួន និងឃុំខ្លួនរហូតដល់រយៈពេល ២៤ម៉ោង មុននឹងទទួលបានលទ្ធភាពទទួលបានប្រឹក្សាច្បាប់ ប៉ុន្តែអ្នកជាប់ពន្ធនាគារជាធម្មតាត្រូវជាប់ឃុំជាច្រើន ថ្ងៃមុននឹងទទួលបានមេធាវី ឬជួបសមាជិកគ្រួសារ ។ យោងតាមមន្ត្រីរដ្ឋាភិបាល ការឃុំខ្លួនយូរបែបនេះ ភាគច្រើនបណ្ដាលមកពីសមត្ថភាពមានកម្រិតរបស់ប្រព័ន្ធតុលាការ ។

នៅថ្ងៃទី ២៩ ខែឧសភា នគរបាលនៅក្រុងភ្នំពេញបានចាប់ខ្លួនឈ្មោះ លាង សុខឿន ហើយតាមរាយការណ៍មកថា បានឃុំគាត់អោយនៅដាច់តែឯងអស់រយៈពេល ៣៣ ម៉ោង ដែលក្នុងអំឡុងពេលនោះ រូបគាត់ត្រូវបានគេដឹកទៅខេត្តតាកែវ។ គ្រួសារ និងមេធាវីរបស់គាត់ត្រូវបានរាយការណ៍មកថា បានធ្វើ សំណើជាច្រើនដងសុំនិយាយជាមួយគាត់ បន្ទាប់ពីការផុតកំណត់នៃរយៈពេលឃុំខ្លួនចំនួន ២៤ ម៉ោង ដូចដែលត្រូវបានអនុញ្ញាតដោយច្បាប់ តែនគរបាលបដិសេធសំណើសុំទាំងអស់ (សូមមើលត្រង់ចំណុច ២.ក)។

គ្មានការវិវឌ្ឍក្នុងករណីមន្ត្រីនគរបាលឈ្មោះ ព្រាប ពៅ ដែលនៅកំពុងលាក់ខ្លួននៅឡើយ បន្ទាប់ពីគាត់ត្រូវបានកាត់ទោសកំបាំងមុខអោយជាប់ពន្ធនាគារចំនួន ១ ឆ្នាំ នៅខែមេសា ឆ្នាំ ២០០៩។

**ការលើកលែងទោស**

ព្រះមហាក្សត្រអាចប្រទានការលើកលែងទោសក្នុងករណីមួយចំនួន ដែលជារឿយៗ ព្រះអង្គធ្វើឡើងនៅអំឡុងពិធីបុណ្យព្រះពុទ្ធសាសនាសំខាន់ៗ និងថ្ងៃបុណ្យជាតិ។ ក្រសួងមហាផ្ទៃបានរាយការណ៍ថា ព្រះបាទនរោត្តម សីហមុនី បានប្រទានការលើកលែងទោសដល់អ្នកទោសចំនួន ១៥៤ នាក់ នៅអំឡុងឆ្នាំនេះ។

**ខ. ការបដិសេធមិនអោយទទួលបានការជំនុំជម្រះក្តីជាសាធារណៈដោយយុត្តិធម៌**

រដ្ឋធម្មនុញ្ញបានចែងថាតុលាការមានភាពឯករាជ្យ ប៉ុន្តែក្នុងការអនុវត្តជាក់ស្តែង រដ្ឋាភិបាល ជាទូទៅមិនគោរពឯករាជ្យភាពរបស់តុលាការឡើយ ។ តុលាការស្ថិតក្រោមឥទ្ធិពល និងអន្តរាគមន៍ របស់អង្គនីតិប្រតិបត្តិហើយកើតមានអំពើពុករលួយយ៉ាងរីករាលដាលក្នុងចំណោមចៅក្រម ព្រះរាជអាជ្ញា និងមន្ត្រីតុលាការ ។

កង្វះធនធាន ប្រាក់ខែទាប និងការបណ្តុះបណ្តាលមិនបានល្អនាំអោយមានកំរិតនៃអំពើពុករលួយខ្ពស់ និងអសមត្ថភាពក្នុងសាខាតុលាការ ហើយរដ្ឋាភិបាលមិនបានចែងពីដំណើរការច្បាប់ត្រឹមត្រូវទេ។

អ្នកសង្កេតការណ៍បាននិយាយថា ករណីជាច្រើនមិនទាន់បានចាត់ការ ដោយសារខ្វះចៅក្រម និងបន្ទប់តុលាការ។ អ្នកសង្កេតការណ៍ក៏បានធ្វើការកាត់ស្មានថា មន្ត្រីតុលាការប្រហែលផ្តោតការយកចិត្តទុកដាក់ច្រើនទៅលើករណីដែលគេអាចទទួលលុយបាន។

មានកង្វះជាខ្លាំងនូវមេធាវីដែលមានជំនាញ ជាពិសេសនៅក្រៅក្រុងភ្នំពេញ។ អ្នកដែលមិនអាចទទួលបានប្រឹក្សាផ្នែកច្បាប់ ច្រើនតែមិនសូវទទួលបាននូវការកាត់ក្តីដោយយុត្តិធម៌ទេ។ យោងតាមសមាគមមេធាវីប្រហែល ៣០% នៃមេធាវីចំនួន ៧៥១ នៅក្នុងប្រទេសផ្តល់ប្រឹក្សាច្បាប់ដោយមិនយកកំរៃដល់អ្នកក្រ។ចំនួននេះគឺមិនគ្រប់គ្រាន់ទេសំរាប់ធានាដល់សិទ្ធិស្របច្បាប់របស់អ្នកក្រទាំងអស់នៅក្នុងប្រទេស។

សេចក្តីស្បថជាលាយលក្ខណ៍អក្សររបស់សាក្សី និងចុងចោទ តាមធម្មតា ច្រើនតែត្រូវបានយកធ្វើជាភស្តុតាងតែម្យ៉ាងក្នុងសវនាការ។ ចំលើយរបស់ចុងចោទ ពេលខ្លះត្រូវបានបង្ខំតាមរយៈការវាយដំ និងការគំរាម ហើយចុងចោទដែលមិនចេះអក្សរ ជាញឹកញាប់ មិនត្រូវបានគេប្រាប់ពីខ្លឹមសារនៃសេចក្តីសារភាពដែលខ្លួនត្រូវបានបង្ខំអោយចុះហត្ថលេខានោះទេ។ ក្នុងករណីដែលទាក់ទងនឹងទាហាន មន្ត្រីយោធាច្រើនតែដាក់ការគាបសង្កត់លើចៅក្រមតុលាការព្រហ្មទណ្ឌស៊ីវិល ដើម្បីអោយចុងចោទបានរួចខ្លួន ដោយមិនឆ្លងកាត់សវនាការ។

ការពន្យារពេលរបស់តុលាការ ឬអំពើពុករលួយរបស់តុលាការច្រើនតែធ្វើអោយជនរងការចោទប្រកាន់រួចផុតពីការកាត់ទោស។ ភាគច្រើនមន្ត្រីរដ្ឋាភិបាល និងសមាជិករបស់គេដែលប្រព្រឹត្តបទល្មើសមិនត្រូវបានទទួលទោសពៃឡើយ (និទណ្ឌភាព)។

ក្នុងករណីព្រហ្មទណ្ឌជាច្រើន ចុងចោទដែលមានទ្រព្យឬមានអំណាច រួមទាំងសមាជិកនៃកងកំលាំងសន្តិសុខផង តាមធម្មតា បង់លុយអោយជនរងគ្រោះ និងអាជ្ញាធរដើម្បីអោយទំលាក់ការចោទប្រកាន់ព្រហ្មទណ្ឌ។ អាជ្ញាធរត្រូវបានគេដឹងថា បានតឿនអោយជនរងគ្រោះ ឬគ្រួសាររបស់គេទទួលយកនូវសំណងប៉ះ ប៉ូវជាលុយកាក់ ជាថ្នូរនឹងការទំលាក់ចោលការចោទប្រកាន់ព្រហ្មទណ្ឌ ឬខកខានមិនបានបង្ហាញមុខជាសាក្សី។

## នីតិវិធីជំនុំជម្រះក្តី

សវនាការត្រូវបានធ្វើជាសាធារណៈ។ មិនមានប្រើគណវិនិច្ឆ័យទេ។ ចៅក្រមជំនុំជំរះមានសិទ្ធិចេញសាលក្រម។ ចុងចោទមានសិទ្ធិបង្ហាញវត្តមាន ហើយពិគ្រោះយោបល់ជាមួយមេធាវី ប្រឈមនិងចោទសួរសាក្សីប្រឆាំងនឹងខ្លួន ហើយបង្ហាញសាក្សី និងភស្តុតាងដោយខ្លួនគេ។ ក្នុងករណី ព្រហ្មទណ្ឌ ប្រសិនបើចុងចោទមិនអាចរកមេធាវីម្នាក់បាន តុលាការត្រូវផ្តល់តំណាងផ្នែកច្បាប់ដោយឥតគិតថ្លៃដល់ ចុងចោទ ។

ទោះជាយ៉ាងណាក៏ដោយជារឿយៗ តុលាការតែងតែខ្វះធនធានដើម្បីផ្តល់ប្រឹក្សាផ្នែកច្បាប់ ហើយចុងចោទភាគច្រើនស្វះស្វែងរកជំនួយពីអង្គការមិនមែនរដ្ឋាភិបាល ឬត្រូវឡើងតុលាការដោយគ្មានតំណាងផ្នែកច្បាប់ ។ ការជំនុំជម្រះក្តីផ្នែកតាមប្រព័ន្ធក្រមស៊ីវិល ជាតួយ៉ាង ធ្វើឡើងគ្រាន់តែបង្គ្រប់កិច្ច ចំណែកការពិនិត្យផ្ទៀងផ្ទាត់អោយបានគ្រប់ជ្រុងជ្រោយ ជាធម្មតា មិនបានកើតមានឡើយ។ ចុងចោទនិងមេធាវីរបស់ខ្លួនមានសិទ្ធិពិនិត្យមើលភស្តុតាងដែលរដ្ឋាភិបាលរក្សាទុក ទាក់ទងនឹងរឿងក្តីរបស់ខ្លួន។ ទោះជាយ៉ាងណាក៏ដោយ ក្នុងកាលៈទេសៈដ៏កម្រ មានការពិបាកនឹងទទួលបានលទ្ធភាពដូចពោលនេះណាស់ ជាពិសេស ប្រសិនបើសំណុំរឿងនោះ ពាក់ព័ន្ធនឹងរឿងនយោបាយ ឬពាក់ព័ន្ធនឹងមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់ ឬសមាជិក ឥស្សរជនដែលមានខ្សែរយៈរឹងមាំ ។

តាមច្បាប់ ចុងចោទទទួលបានសិទ្ធិសន្មតថាជាជនស្លូតត្រង់ និងមានសិទ្ធិប្តឹងឧទ្ធរណ៍ ប៉ុន្តែដោយសារអំពើពុករលួយរីករាលដាល ជារឿយៗចុងចោទត្រូវសូកចៅក្រម ដើម្បីទទួលបានសាលក្រមដែលមានលក្ខណៈអនុគ្រោះ ។ សិទ្ធិឧទ្ធរណ៍របស់ប្រជាពលរដ្ឋ ជួនកាលជួបឧបសគ្គ ដោយសារមានការលំបាកក្នុងការផ្ទេរអ្នកជាប់ពន្ធនាគារពីពន្ធនាគារខេត្តទៅកាន់សាលាឧទ្ធរណ៍នៅភ្នំពេញ ។ ជាលទ្ធផល ជាងពាក់កណ្តាលនៃបណ្តឹងឧទ្ធរណ៍ទាំងអស់ ត្រូវបានបើកសវនការដោយកំបាំងមុខចុងចោទ ។

គ្មានការវិវឌ្ឍក្នុងករណីឈ្មោះថាច់ សាវ៉េត។ ក្នុងឆ្នាំ ២០០៩ សាលាឧទ្ធរណ៍បានដំកល់ការកាត់ទោសនៅឆ្នាំ ២០០៥ ទៅលើរូបគាត់ពីបទធ្វើឃាតមេដឹកនាំសហជីពកម្មករឈ្មោះ រស់ សុវណ្ណារ៉េត ។ មេធាវីរបស់ឈ្មោះថាច់ សាវ៉េត បានប្តឹងទៅតុលាការកំពូល តែមកដល់ដំណាច់ឆ្នាំ មិនទាន់មានការកំណត់ថ្ងៃខែសវនាការនៅឡើយទេ។ អ្នកសង្កេតការជាច្រើន រួមទាំងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអង្គការពលកម្មអន្តរជាតិ (ILO) បានរាយការណ៍អំពីភាពមិនប្រក្រតីនៃនីតិវិធីជំនុំជម្រះក្នុងរឿងក្តីនេះនិងកង្វះភស្តុតាងដែលភ្ជាប់ ឈ្មោះ ថាច់ សាវ៉េត ទៅនឹងបទឧក្រិដ្ឋនេះ ។

គ្មានការវិវឌ្ឍក្នុងករណីឈ្មោះប៊ន សំណាង និង សុខ សំអឿន ដែលត្រូវបានដាក់អោយស្ថិត នៅក្រៅឃុំ បន្ទាប់ពីតុលាការកំពូលបានរកឃើញថារឿងក្តីនេះគួររក្សាទុកនៅសាលាឧទ្ធរណ៍ ដើម្បីធ្វើការស៊ើបអង្កេត ឡើងវិញ នៅឆ្នាំ ២០០៨។ បុរសទាំងពីរត្រូវបានចោទប្រកាន់នៅឆ្នាំ ២០០៤ ពីបទធ្វើឃាតលើប្រធានសហជីពកម្មករ ឈ្មោះ ជា វិជ្ជា។ ករណីនេះនៅតែស្ថិតនៅលើដៃរបស់សាលាឧទ្ធរណ៍នៅឡើយ ដើម្បីធ្វើការស៊ើបអង្កេត និងកាត់ក្តីជាថ្មី។

**អ្នកជាប់ពន្ធនាគារ និងអ្នកជាប់ឃុំដោយសារមូលហេតុនយោបាយ**

ពុំមានរបាយការណ៍អំពីអ្នកជាប់ពន្ធនាគារ និងអ្នកជាប់ឃុំដោយសារមូលហេតុនយោបាយឡើយ ។

## នីតិវិធីតុលាការស៊ីវិល និងដំណោះស្រាយ

ប្រទេសកម្ពុជាមានអង្គតុលាការមួយសម្រាប់បណ្តឹងរដ្ឋប្បវេណី ហើយប្រជាពលរដ្ឋមានសិទ្ធិដាក់ពាក្យបណ្តឹងស្វែងរកសំណងការខូចខាតសម្រាប់ការរំលោភសិទ្ធិមនុស្ស ។ ជាទូទៅ មានទាំងដំណោះស្រាយផ្នែករដ្ឋបាល ទាំង ដំណោះស្រាយផ្នែកតុលាការ ។ ការអនុវត្តសាលដីកាតុលាការសម្រាប់រឿងក្តីរដ្ឋប្បវេណី និងព្រហ្មទណ្ឌ ជារឿយៗតែងតែមានបញ្ហា ។ ជារឿយៗបុគ្គលមួយចំនួនបានដោះស្រាយបញ្ហាតាមរបៀបយុត្តិធម៌របស់ខ្លួន (Vigilante Justice) ទៅវិញ ។

## ច. ការជ្រៀតជ្រែកក្នុងភាពឯកជន គ្រួសារគេហដ្ឋាន ឬការទំនាក់ទំនង

ច្បាប់មានចែងអំពីភាពឯកជននៃការរស់នៅ និងការទំនាក់ទំនង ព្រមទាំងហាមឃាត់ការឆែកឆេរខុសច្បាប់ ។ ទោះជាយ៉ាងណាក៏ដោយ អ្នកសង្កេតការណ៍បានរាយការណ៍ថា ជាទម្លាប់នគរបាលធ្វើការឆែកឆេរនិងរឹបអូស ដោយគ្មានដីកាពីតុលា ។

របាយការណ៍យ៉ាងច្រើននៅតែបន្តមានស្តីអំពីអាជ្ញាធរចូលក្នុងលំនៅដ្ឋានឯកជន ដោយគ្មានការអនុញ្ញាតពីតុលាការ ។ ដោយសារមានការប្រមូលផ្តុំដោយបង្ខំនៅអំឡុងសម័យខ្មែរក្រហម និងការវិលត្រឡប់នៃជនភៀស ខ្លួនរាប់សែននាក់កម្មសិទ្ធិដីធ្លី ជារឿយៗមានលក្ខណៈមិនច្បាស់លាស់ ។ ច្បាប់ភូមិបាលឆ្នាំ២០០១ ចែងថាបុគ្គល ណាដែលបានកាន់កាប់ដីធ្លី ឯកជន ឬដីធ្លីឯកជនរបស់រដ្ឋ (មិនមែនដីធ្លីសាធារណៈរបស់រដ្ឋ) ដោយគ្មានការជំទាស់ រយៈពេល៥ឆ្នាំ មុនពេលប្រកាសអោយប្រើច្បាប់ ភូមិបាល ឆ្នាំ២០០១ មានសិទ្ធិសុំកម្មសិទ្ធិផ្តាច់មុខលើដីធ្លីនោះ ។ ប្រជាជនក្រីក្រភាគច្រើនក្នុងប្រទេសនៅតែបន្តខ្វះខាតឯកសារផ្លូវការទាក់ទងនឹងកម្មសិទ្ធិដីធ្លីនៅឡើយ ។

ការិយាល័សុរិយោដីខេត្ត និងស្រុក នៅតែបន្តអនុវត្តតាមនីតិវិធីចុះបញ្ជីដីធ្លីមុនឆ្នាំ២០០១ ដែលពុំមានការវាស់វែងដីត្រឹមត្រូវ និងឱកាសសម្រាប់ការផ្តល់យោបល់ពីសាធារណជនទេ ។ គណៈកម្មការសុរិយោដីមិន បានអនុវត្តការកំណត់អត្តសញ្ញាណ និងកំណត់ព្រំដីរបស់រដ្ឋដែលនាំអោយមានទំនាស់ដីធ្លីជាច្រើនការបណ្តេញដោយបំពាន និងការ អភិវឌ្ឍរបស់រដ្ឋដោយគ្មានការត្រួតពិនិត្យ ការកំណត់ច្បាស់លាស់ ។ ការកេងចំណេញពីដីធ្លី ជារឿយៗ ជាទម្រង់ដីសម្បទាន នៅតែបន្តជំរុញអោយមានទំនាស់នៅគ្រប់ខេត្ត

ហើយនាំអោយមានភាពតានតឹងកាន់តែខ្លាំងរវាងសហគមន៍ជនបទ និងឈ្មួញដីធ្លី ។ សហគមន៍តាមទីក្រុងប្រឈមមុខ នឹងការបណ្តេញចេញដោយបង្ខំដើម្បី បើកផ្លូវអោយគម្រោងអភិវឌ្ឍន៍របស់ក្រុមហ៊ុន។

គណៈកម្មការសុរិយោដីនៅតែបន្តបំពេញមុខងាររបស់ខ្លួនយ៉ាងយឺតយ៉ាវដដែល ។ តុលាការនៅតែជាអ្នកទទួលខុសត្រូវដោះស្រាយវិវាទក្នុងករណីដីត្រូវបានចុះបញ្ជី ឬអ្នកជំទាស់មានប័ណ្ណកម្មសិទ្ធិដីធ្លី ។ អាជ្ញាធរជាតិដោះ ស្រាយវិវាទដីធ្លី គ្មានប្រសិទ្ធភាព ហើយមានការច្រឡំគ្នាកើតមាន ឡើងអំពីយុត្តាធិការរបស់អាជ្ញាធរនេះ ដែល ជាន់ការងារគ្នាជាមួយគណៈកម្មការសុរិយោដីជាតិ និងខេត្ត ។ ការអនុវត្តដីសម្បទានសង្គមកិច្ច សម្រាប់ប្រជាពលរដ្ឋដែលនៅមានកម្រិត ។

ករណីអ្នកស្រុកត្រូវបានបណ្តេញអោយផ្លាស់ប្តូរទីលំនៅ នៅតែបន្តកើតមាន នៅពេលមន្ត្រី ឬអាជីវករឃុបឃិតគ្នា ជាមួយអាជ្ញាធរ ។ ចំនួនករណីមានការកើនឡើងពីឆ្នាំ ២០០៩ មក។ មានបុគ្គលមួយចំនួនបានប្រើប្រាស់ប្រព័ន្ធតុលាការដើម្បីបំភិតបំភ័យប្រជាជនក្រីក្រ និងជនងាយរងគ្រោះ អោយដោះដូរដីធ្លីរបស់ខ្លួន យកសំណងដែលទាបជាងតម្លៃទីផ្សារដែរ ។ អង្គការ ADHOC បានរាយការណ៍ថា ខ្លួនបានទទួលករណី ទាក់ទងនឹងដីធ្លីចំនួន ២០២ ករណី ។ នៅអំឡុងពេលនេះដែរ អង្គការ មិនមែនរដ្ឋាភិបាលមួយផ្សេងទៀតបានទទួលបណ្តឹងទាក់ទងនឹងបញ្ហាដីធ្លីចំនួន ៧៥ ករណីនៅភ្នំពេញ និង ១៣ ករណីនៅខេត្ត ដែលប៉ះពាល់ដល់ប្រជាជន ចំនួន ៧០៤០ គ្រួសារ ។ ជារឿយៗ ប្រជាជនក្រីក្រគ្មានឯកសារស្របច្បាប់ដើម្បីបញ្ជាក់លើការទាមទារដីធ្លី របស់ខ្លួនឡើយ ហើយខ្វះជំនឿទៅលើប្រព័ន្ធយុត្តិធម៌ ។ ប្រជាជនមួយចំនួន ដែលត្រូវបណ្តេញចេញ បានតវ៉ាដោយជោគជ័យប្រឆាំងនឹងវិធានការទាំងនេះនៅក្នុងតុលាការ ប៉ុន្តែករណីភាគច្រើននៅក្នុងតុលាការកំពុងស្ថិតក្នុង ដំណើរការពិនិត្យសំណុំឯកសារនៅឡើយ ។

នៅថ្ងៃទី ១៩ ខែមិនា អំពើហឹង្សាបានផ្ទុះឡើង នៅពេលអាជ្ញាធរព្យាយាមអនុវត្តដីការរបស់តុលាការកំពូល ដែលបណ្តេញមនុស្សចេញពីដីទំហំ ១៦២ អេឃើ នៅស្រុកឧត្តុង្គ ខេត្តកំពង់ស្ពឺ។ Kuo Sheng ដែលជាថៅកែជនជាតិតៃវ៉ាន់នៃក្រុមហ៊ុន Meng Keth បានអះអាងថា គាត់បានទិញដីទំហំ ៥៥១ អេឃើ ពីឆ្នាំ ១៩៩៧ ដល់ឆ្នាំ ២០០០ ដើម្បីដាំដើមឈើ និងធ្វើរោងចក្រមួយ។ តំណាងរបស់ក្រុមហ៊ុនបាននិយាយថា ក្រុមហ៊ុននឹងបង់លុយជូនអ្នកភូមិ ដែលមានក្រដាសស្តីពីដីរបស់គេ។ តំណាងរបស់អ្នកភូមិបានទទួចថា គ្មានអ្នកភូមិណាម្នាក់លក់ដីទៅអោយក្រុមហ៊ុនទេ។ នគរបាល និងអ្នកភូមិបានវាយគ្នា នៅពេលនគរបាលប៉ុនប៉ងប្រើកំលាំងបណ្តេញអ្នកភូមិចេញ។

នៅថ្ងៃទី ២៥ ខែឧសភា កងរាជអាវុធហត្ថមួយក្រុម នគរបាលខេត្ត និងទាហានបានដុតផ្ទះរបស់អ្នកភូមិជិត ១០០ នាក់នៅភូមិអំពិល ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ អាជ្ញាធរបានអះអាងថា ដីនោះគឺជាផ្នែកមួយនៃតំបន់ជំរកសត្វព្រៃគូលែនព្រំទេព ហើយថា តុលាការបានបញ្ជាអោយធ្វើការដេញចេញ។ យោធានិងនគរបាលបានដុតផ្ទះបន្ទាប់ពីអ្នកភូមិដែលមិនព្រមចាកចេញ។ អ្នកភូមិបានអះអាងថា គេបានទិញដីនោះពីក្រសួងបរិស្ថាននៅឆ្នាំ ២០០០ ហើយថា ការបញ្ជាអោយដេញពួកគេចេញមិនគួរមានឡើយ ពីព្រោះមានករណីដែលមិនទាន់ត្រូវបានចាត់ការនៅតុលាការនៅឡើយ។

នៅខែកក្កដា គ្រួសាររងគ្រោះដោយសារមេរោគអេដស៍/ជំងឺអេដស៍ ៤២ គ្រួសារដែលត្រូវបានបង្ខំអោយចេញពីសហាគមន៍បុរីកីឡា នៅក្រុងភ្នំពេញទៅកាន់តំបន់តាំងទីលំនៅថ្មី នៅទួលសំបូរ កាលពីខែ មិថុនា ឆ្នាំ ២០០៩ បានទទួលផ្ទះថ្មថ្មី ដែលត្រូវបានកសាងដោយអង្គការមិនមែនរដ្ឋាភិបាល Caritas Cambodia ។ អង្គការមិនមែនរដ្ឋាភិបាលបាននិយាយថា គ្រួសារចំនួន ៦ ដែលមានសិទ្ធិទទួលផ្ទះនៅបុរីកីឡា មិនទាន់បានទទួលនៅឡើយទេ។

នៅខែមិនា លោក សុន ឆ័យ សមាជិកសភាមកពីគណបក្សសម រង្ស៊ី បានទទួលដីការពីតុលាការខេត្តសៀមរាប ដោយអោយគាត់ចាកចេញពីដីរបស់គាត់។ តុលាការកំពូលបានតំកល់ការសម្រេចរបស់តុលាការជាន់ក្រោម ឆ្នាំ ២០០៩ ដែលបញ្ជាអោយគាត់លក់ដីរបស់គាត់ទំហំ ៧,៨អេឃើ ទៅអោយទីភ្នាក់ងាររដ្ឋាភិបាល ដែលតាមរបាយការណ ក្នុងតម្លៃមួយទាបជាងតម្លៃទីផ្សារ ។

គ្មានការវិវឌ្ឍក្នុងករណីឈ្មោះ ជា សំអាត ដែលតាមការចោទប្រកាន់បានតាំងខ្លួនជាមេភូមិ ហើយបញ្ជាអោយទាហានបាញ់ប្រហារលើអ្នកភូមិដែលកំពុងតែតវ៉ានឹងការបណ្តេញចេញនៅស្រុកម៉ាល័យ ខេត្តបន្ទាយមានជ័យនៅ ឆ្នាំ២០០៨ ។ ការស៊ើបអង្កេតនៅបន្តធ្វើ ។ ជា សំអាតបានប្តូរមករស់នៅខេត្តឧត្តរមានជ័យវិញ។

នៅខែឧសភា តុលាការខេត្តរតនៈគិរីបានប្រកាសថា នឹងតែងតាំងចៅក្រមថ្មីមួយ ជាលើកទី ៣ ក្នុងជំលោះដ៏យូរវរវាងអ្នកភូមិជនជាតិភាគតិចចារ៉ាយមកពីភូមិកុងយូ និងកុងធំ និងឈ្មោះគាត កុលណើ ។ អ្នកភូមិបានដាក់បណ្តឹងរដ្ឋប្បវេណីប្រឆាំងនឹងចៅកែស្រីឈ្មោះ គាត កុលណើ ដោយចោទប្រកាន់ឈ្មោះ គាត កុលណើ ពីបទប្រើល្បិច អោយអ្នកទាំងនោះផ្តិតមេដៃលើឯកសារផ្ទេរដីទំហំ ១.១១២ អេឃើ នៅឃុំប៉ាតស្រុកអូរយ៉ាដាវ ខេត្តរតនៈគិរី នៅឆ្នាំ២០០៤ ។ មកដល់ដំណាច់ឆ្នាំ នេះ បណ្តឹងរដ្ឋប្បវេណីរបស់សហាគមន៍ប្រឆាំងនឹងឈ្មោះ គាត កុលណើ នៅមិនទាន់ជំនុំជម្រះក្តីនៅឡើយទេ ។

## ផ្នែកទី២ ៖ ការគោរពសេរីភាពពលរដ្ឋ ដែលរួមមាន

### ក. សេរីភាពបញ្ចេញមត និងសារព័ត៌មាន

រដ្ឋធម្មនុញ្ញមានចែងអំពីសេរីភាពបញ្ចេញមតិ និងសេរីភាពផ្នែកសារព័ត៌មាន។ ទោះជាយ៉ាងណាក៏ដោយនៅក្នុងការអនុវត្តជាក់ស្តែង សិទ្ធិទាំងនេះមិនត្រូវបានគោរពជានិច្ចកាលឡើយ ។

រដ្ឋធម្មនុញ្ញកំណត់ថា ការបញ្ចេញមតិដោយសេរី មិនត្រូវប៉ះពាល់ដល់សន្តិសុខសាធារណៈឡើយ ។ រដ្ឋធម្មនុញ្ញ ក៏ប្រកាសផងដែរថា ព្រះមហាក្សត្រ “មិនអាចត្រូវគេរំលោភបាន” ហើយសេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃ ដែលអនុលោមតាមច្បាប់បរិហាកេរ្តិ៍ បញ្ជាក់ជាថ្មីនូវដែនកំណត់ទាំងនេះ ហើយហាមប្រាមមិនអោយអ្នកបោះពុម្ព និងនិពន្ធនាយកផ្សព្វផ្សាយរឿងណា ដែលប្រមាថ និងបរិហាកេរ្តិ៍ថ្នាក់ដឹកនាំនិងស្ថាប័នរដ្ឋាភិបាលឡើយ ។

ច្បាប់ស្តីពីសារព័ត៌មានឆ្នាំ១៩៩៥ ហាមប្រាមមិនអោយមានការត្រួតពិនិត្យចាប់ពិរុទ្ធមុនពេលបោះពុម្ពផ្សាយ ឬការដាក់ទោសជាប់ពន្ធនាគារ ដោយសារការសម្តែងមតិឡើយ ។ ទោះជាយ៉ាងណាក៏ដោយរដ្ឋាភិបាល នៅតែបន្តប្រើប្រាស់ច្បាប់ចាស់កាលពីសម័យអាជ្ញាធរអន្តរកាលរបស់អង្គការសហប្រជាជាតិ (UNTAC) នៅកម្ពុជាដើម្បីរករឿងអ្នកសារព័ត៌មាន និងអ្នកដទៃទៀត ពីបទបរិហារកេរ្តិ៍ ផ្សាយព័ត៌មានមិនពិត និងញុះញង់។ វិសោធនកម្មឆ្នាំ២០០៦ ចំពោះច្បាប់អន្តរកាលនេះ បានលុបទោស ជាប់ពន្ធនាគារចំពោះករណីបរិហារកេរ្តិ៍ ប៉ុន្តែនៅរក្សាទុកបទញុះញង់ និងផ្សព្វផ្សាយព័ត៌មានមិនពិត ដែលត្រូវមានទោសជាប់ពន្ធនាគាររហូតដល់បីឆ្នាំ ។ ចៅក្រមអាចកាត់សេចក្តីជាការផាកពិន័យ ដែលអាចនាំទៅរកការជាប់ពន្ធនាគារប្រសិនមិនបង់ប្រាក់ពិន័យនោះទេ ។

នៅថ្ងៃទី ១២ ខែមិនា តុលាការក្រុងភ្នំពេញបានចោទប្រកាន់មេដឹកនាំគណបក្សប្រឆាំង សម រង្ស៊ី ពីបទផ្សាយព័ត៌មានមិនពិត និងក្លែងឯកសារសាធារណៈក្រោមមាត្រាទី ៦២ និង ៤៩ នៃច្បាប់អ៊ុនតាក់។ រដ្ឋាភិបាលបានចោទប្រកាន់ថា ផែនទីដែលលើកឡើងដោយលោក សម រង្ស៊ី កាលពីខែកុម្ភៈក្នុងអំឡុងនៃការធ្វើសេចក្តីអធិប្បាយមួយជាសាធារណៈរបស់លោក ស្តីពីការកំណត់ព្រំដែនជាមួយប្រទេសវៀតណាមគឺក្លែងក្លាយ។ ថ្វីបើលោក សម រង្ស៊ី ធ្វើនិរទេសខ្លួនឯងនៅប្រទេសបារាំងក្តី ក៏កាលពីថ្ងៃទី ២៣ ខែកញ្ញា តុលាការបានកាត់ទោសលោកដោយកំបាំងមុខ អោយជាប់ពន្ធនាគាររយៈពេល ១០ ឆ្នាំ និងពិន័យជាប្រាក់

ចំនួន ៥ លានរៀល (ប្រហែល ១ ១៨៩ ដុល្លាអាមេរិក) និងការសងបន្ថែមចំនួន ៦០ លានរៀល (ត្រូវជា ១៤ ១៥០ ដុល្លាអាមេរិក)។

នៅខែមិនា លោក កៅ គឹមហួន រដ្ឋលេខាធិការក្រសួងការបរទេស និងជានាយកសាកលវិទ្យាល័យនៃកម្ពុជា បានប្ដឹងលោកប៊ុន ថា និពន្ធនាយកនៃកាសែតខ្មែរអមតៈ ពីបទបរិហារកេរ្តិ៍ ចំពោះការចេញផ្សាយអត្ថបទទិទៀនពីការទារលុយពីអ្នកដាក់ពាក្យសុំអាហារូបករណ៍ នៅសាកលវិទ្យាល័យ។ អត្ថបទទាំងនោះបានអះអាងថា ការទារថ្លៃនោះមិនមានភាពយុត្តិធម៌ទេ ហើយអាចមានការពាក់ព័ន្ធនឹងអំពើពុករលួយ។ លោក កៅ គឹមហួនបាននិយាយក្នុងពាក្យបណ្ដឹងរបស់លោកថា និពន្ធនាយកនោះមិនបានសុំមតិពីសាកលវិទ្យាល័យទេ មុននឹងចេញផ្សាយអត្ថបទ ហើយថាការទារថ្លៃនោះគឺសំរាប់ការប្រើប្រាស់ត្រឹមត្រូវសំរាប់សង់កន្លែងស្នាក់នៅរបស់អ្នកទទួលអាហារូបករណ៍ និងបង់ថ្លៃប្រាក់ខែគ្រូ។ ករណីបណ្ដឹងនោះត្រូវបានដកវិញបន្ទាប់ពីនិពន្ធនាយកនោះបានសរសេរសុំទោសដល់លោក កៅ គឹមហួន។

នៅថ្ងៃទី ២៩ ខែឧសភា នគរបាលកណ្ដាលសន្តិសុខរបស់ក្រសួងមហាផ្ទៃបានចាប់ខ្លួនឈ្មោះ លាង សុខឿន ដែលធ្វើការក្នុងអង្គការមិនមែនរដ្ឋាភិបាលខ្មែរផ្នែកសិទ្ធិមនុស្ស ពីបទផ្សាយព័ត៌មានមិនពិតទាក់ទងនឹងការចែកខិតប័ណ្ណ នៅខេត្តតាកែវ។ តាមការរាយការណ៍មកខិតប័ណ្ណនោះរិះគន់ទំនាក់ទំនង រវាងរដ្ឋាភិបាលនិងប្រទេសវៀតណាម។ ព្រះរាជអាជ្ញាបានអះអាងថា ខ្លឹមសារនោះមានលក្ខណប្រមាថ ដល់រដ្ឋាភិបាលនិងអតីតព្រះមហាក្សត្រ នរោត្តម សីហនុ។ ឈ្មោះ លាង បានអះអាងពីការគ្មានកំហុសរបស់ខ្លួន ហើយបាននិយាយថា ខ្លួនមានការទាក់ទងតិចតួចតែប៉ុណ្ណោះជាមួយអ្នកដទៃដែលត្រូវបានរាយការណ៍មកថាមានការពាក់ព័ន្ធនឹងរឿងនោះ។ នៅថ្ងៃទី ៣០ ខែសីហា តុលាការខេត្តតាកែវបានដាក់ទោសឈ្មោះលាង និង មនុស្ស ៣ នាក់ទៀតពីបទផ្សាយព័ត៌មានមិនពិត ហើយបានដាក់ទោសឈ្មោះលាងអោយជាប់ពន្ធនាគារ ចំនួន ២ ឆ្នាំ។ គ្រួសាររបស់ឈ្មោះលាងបានប្ដឹងឧទ្ធរណ៍ចំពោះការដាក់ទោសនោះ ហើយរហូតដល់ដំណាច់ ឆ្នាំ មិនទាន់មានការកំណត់ថ្ងៃខែនៃការកាត់ក្ដីនៅសាលាឧទ្ធរណ៍នៅឡើយ។

នៅថ្ងៃទី ១៩ ខែធ្នូ តុលាការក្រុងភ្នំពេញបានដាក់ទោសឈ្មោះ សេង គុណការ ដែលធ្វើការក្នុងអង្គការស្បៀងអាហារពិភពលោក នៅក្រុងភ្នំពេញ ហើយដាក់ទោសឈ្មោះ គុណការអោយជាប់ពន្ធនាគារ ចំនួន ៦ ខែ។ គាត់ត្រូវបានចោទពីបទញុះញង់ ក្រោមមាត្រាទី ៤៩៥ នៃក្រមព្រហ្មទណ្ឌថ្មីទាក់ទងនឹងការបោះពុម្ព និងចែកចាយអត្ថបទគេហទំព័រដែលរិះគន់មន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់។ នៅដំណាច់ឆ្នាំ គាត់បានចូលពន្ធនាគារ។

មានព្រឹត្តិការណ៍ក្នុងករណីឆ្នាំ ២០០៩ មួយចំនួនក្នុងឆ្នាំរបាយការណ៍នេះ។ នៅថ្ងៃទី ២៧ ខែមករា តុលាការខេត្តស្វាយរៀងបានកាត់ទោសលោក សម រង្ស៊ីដោយកំបាំងមុខ ពីបទញុះញង់អោយមានការស្អប់ខ្ពើមជាតិសាសន៍ និងការបំផ្លាញទ្រព្យសម្បត្តិសាធារណៈ ទាក់ទងនឹងហេតុការណ៍កាលពីខែតុលា ឆ្នាំ ២០០៩ ដែលក្នុងនោះ អ្នកភូមិមួយក្រុមបានដកបង្គោលព្រំដែនជាមួយប្រទេសវៀតណាម។ តុលាការបានដាក់ទោសលោក សម រង្ស៊ីអោយជាប់ពន្ធនាគារចំនួន ២ ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៨ លានរៀល (១៨៩០ ដុល្លាអាមេរិក)។ តុលាការក៏បានកាត់ទោសអោយអ្នកភូមិ ២ នាក់ដែលបានចូលរួមដកបង្គោលព្រំដែននោះ ដោយម្នាក់ៗជាប់ពន្ធនាគារចំនួន ១ ឆ្នាំ។ លោក សម រង្ស៊ី និងអ្នកភូមិបានប្តឹងឧទ្ធរណ៍។ នៅថ្ងៃទី ៥ ខែតុលា សាលាឧទ្ធរណ៍បានរក្សាសាលក្រមរបស់តុលាការជាន់ក្រោម ហើយបានដាក់ទោសលើលោក សម រង្ស៊ី។ សាលក្រមប្រឆាំងនឹងអ្នកភូមិក៏ត្រូវបានដំកល់ផងដែរ តែរយៈពេលនៅសល់ពីទោសជាប់ពន្ធនាគាររយៈពេលមួយឆ្នាំរបស់គេត្រូវបានព្យួរ ហើយអ្នកភូមិក៏ត្រូវបានដោះលែង បន្ទាប់ពីបានជាប់ពន្ធនាគារអស់រយៈពេលជិត ១០ ខែមក។ សម រង្ស៊ីបានប្តឹងបន្តទៅតុលាការកំពូល មកដល់ដំណាច់ឆ្នាំ មិនទាន់មានការកំណត់ថ្ងៃខែសវនាការនៅឡើយទេ។

នៅខែមករា រដ្ឋាភិបាលបានអនុញ្ញាតអោយកាសែតលំអៀងខាងគណបក្សប្រឆាំង គឺកាសែតមនសិការខ្មែរដំណើរការឡើងវិញ បន្ទាប់ពីការអាក់ខានរយៈពេល ៦ ខែ។ រដ្ឋាភិបាលបានចោទប្រកាន់និពន្ធនាយក នៃកាសែតនេះ គឺលោក ដាំ សិទ្ធិ ពីបទបរិហារកេរ្តិ៍ ផ្សាយព័ត៌មានមិនពិត និងការញុះញង់ តែបានដកការចោទប្រកាន់វិញ បន្ទាប់ពីលោក ដាំ សិទ្ធិ បានធ្វើការសុំទោស ហើយបិទកាសែត នៅខែមិថុនា ឆ្នាំ ២០០៩ ។

នៅថ្ងៃទី ១៣ ខែមេសា រដ្ឋាភិបាលបានយល់ព្រមតាមការលើកលែងទោសដល់លោក ហង្ស ចក្រា និពន្ធនាយកនៃកាសែតខ្មែរម្ចាស់ស្រុក ដែលលំអៀងទៅរកគណបក្សប្រឆាំង។ បន្ទាប់ពីបានជាប់ពន្ធនាគារអស់រយៈពេល ៩ ខែនៃទោសជាប់ពន្ធនាគាររយៈពេល ១២ ខែ ពីបទផ្សព្វផ្សាយព័ត៌មានមិនពិត ទាក់ទងនឹងអត្ថបទមួយចំនួនស្តីពីអំពើពុករលួយក្នុងចំណោមទីប្រឹក្សា និងបុគ្គលិករបស់ឧបនាយករដ្ឋមន្ត្រី សុខ អាន។

នៅថ្ងៃទី ២ ខែមិថុនា តុលាការកំពូលបានដំកល់សាលក្រមទាក់ទងនឹងការបរិហារកេរ្តិ៍ របស់តុលាការថ្នាក់ក្រោម ប្រឆាំងនឹងលោកស្រី មូ សុខហួ ដែលជាសមាជិកសភាមកពីគណបក្សប្រឆាំង។ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែនបានប្តឹងលោកស្រីនៅខែមេសា ឆ្នាំ ២០០៩ ដោយនិយាយថា ការនិយាយរបស់

លោកស្រីក្នុងសន្និសីទកាសែត និងការខិតខំជាបន្តមក ដើម្បីទាក់ទាញការគាំទ្រជាអន្តរជាតិ បានធ្វើអោយលោកខូចកេរ្តិ៍ឈ្មោះ។ តុលាការបានបញ្ជាអោយលោកស្រី សុខហួបង់ប្រាក់ពិន័យចំនួន ៨ លានរៀល (១ ៨៩០ ដុល្លាអាមេរិក) បូកនឹងប្រាក់សំណងដល់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ចំនួន ៨,៥ លានរៀល (២ ០០០ ដុល្លាអាមេរិក) តែលោកស្រីមិនព្រមបង់។ នៅថ្ងៃទី ១៥ ខែកក្កដា តុលាការក្រុងភ្នំពេញ បានស្នើអោយសភាជាតិកាត់ប្រាក់ខែជាសមាជិកសភារបស់លោកស្រី ដើម្បីបង់ទៅលោកនាយករដ្ឋមន្ត្រី។ សភាជាតិបានយល់ព្រមតាមសំណើនេះ នៅថ្ងៃទី ២៩ ខែកក្កដា ហើយបានចាប់ផ្តើមកាត់ប្រាក់ចំនួន ៤ លានរៀលក្នុងមួយខែពីប្រាក់ខែរបស់លោកស្រី សុខហួ។ នៅថ្ងៃទី ៩ ខែសីហា តុលាការបានចេញសំណើដូចគ្នានេះដើម្បីកាត់ប្រាក់ខែរបស់លោកស្រី សុខហួរដើម្បីបង់ប្រាក់ពិន័យក្នុងករណីនេះ ហើយសំណើនេះក៏ទទួលបានការយល់ព្រមផងដែរ។

ជាការបន្តរឿងក្តីស្តីពីការបរិហារកេរ្តិ៍ ឆ្នាំ ២០០៨ ដែលលោករដ្ឋមន្ត្រីការបរទេស ហោ ណាំហុង បានដាក់ពាក្យប្តឹងនៅប្រទេសបារាំង ប្រឆាំងនឹងលោក សម រង្ស៊ី ។ នៅថ្ងៃទី ២០ ខែឧសភា សាលាឧទ្ធរណ៍នៅប្រទេសបារាំងបានដំកល់សាលក្រម ដែលចេញនៅខែមករា ឆ្នាំ ២០០៩ ប្រឆាំងលោក សម រង្ស៊ី ហើយបានបញ្ជាអោយលោក សម រង្ស៊ី បង់លុយចំនួន ២០០០ អឺរ៉ូ (២ ៦៥០ ដុល្លាអាមេរិក) ទៅលោករដ្ឋមន្ត្រីការបរទេស។

គណបក្សនយោបាយធំៗទាំងអស់មានលទ្ធភាពសមរម្យ និងទៀងទាត់ផ្នែកកាសែត ។ សារព័ត៌មានជាភាសាខ្មែរធំៗទាំងអស់សុទ្ធតែបានទទួលការគាំទ្រផ្នែកថវិកាពីគណបក្សនយោបាយ ហើយជាប់ពាក់ព័ន្ធនឹងនយោបាយ ។ តាមការប៉ាន់ស្មាន មានសារព័ត៌មានជាភាសាខ្មែរប្រមាណជាង ២០ ចេញផ្សាយជាទៀងទាត់ ។ នៅបណ្តាឆ្នាំកន្លងទៅ យ៉ាងហោចណាស់មានសារព័ត៌មានសំខាន់ៗបួនគាំទ្រគណបក្សប្រឆាំង ។ ក្នុងឆ្នាំនៃរបាយការណ៍នេះ ម្យ៉ាងដោយសារមានវិបត្តិថវិកា មានកាសែតគាំទ្រគណបក្សប្រឆាំងតែមួយទេដែលបានចេញផ្សាយទៀងទាត់។ កាសែតគាំទ្រគណបក្សប្រឆាំងមួយទៀតនៅមានគេហទំព័រ តែចេញកាសែតមិនទៀងទាត់ទេ។ ទោះបីជាសារព័ត៌មានដែលចរាចរច្រើនជាងគេទាំងបី ត្រូវចាត់ទុកថាជាសារព័ត៌មាន គាំទ្រគណបក្សប្រជាជនកម្ពុជាក្តី តែមានសារព័ត៌មានភាគច្រើនរិះគន់រដ្ឋាភិបាល ជាពិសេសទាក់ទងនឹងអំពើពុករលួយ និងការដណ្តើមដីធ្លី ដែរ ។ នាយករដ្ឋមន្ត្រី មេដឹកនាំគណបក្សរាជានិយម និងមេដឹកនាំគណបក្សប្រឆាំងជារឿយៗ បានទទួលរងការរិះគន់ ។

រដ្ឋាភិបាល កម្លាំងយោធា គណបក្សនយោបាយកាន់អំណាច បានបន្តកាន់កាប់លើសលុបលើប្រព័ន្ធផ្សព្វផ្សាយ និងមានឥទ្ធិពលលើខ្លឹមសារនៃការផ្សព្វផ្សាយ ។ ស្ថានីយ៍ទូរទស្សន៍មានចំនួន ៩ និងស្ថានីយ៍វិទ្យុមានចំនួនប្រមាណជា ៥០ ។ ស្ថានីយ៍ទូរទស្សន៍ និងស្ថានីយ៍វិទ្យុទាំងអស់ត្រូវបានគ្រប់គ្រង ឬទទួលរងឥទ្ធិពលយ៉ាងខ្លាំងពីគណបក្សប្រជាជនកម្ពុជា ទោះជាយ៉ាងណាក៏ដោយក៏មានវិទ្យុមួយចំនួនតូច មានឯករាជ្យ ឬកាន់ខាងគណបក្ស ដទៃទៀតដែរ ។ នៅថ្ងៃទី ៨ ខែកក្កដា ក្រុមផ្សាយដើមអំពិល ដែលមានកាសែតចេញប្រចាំថ្ងៃ គេហទំព័រនិងស្ថានីយវិទ្យុ បានបិទដោយសារមានជំលោះរវាងអគ្គនាយក គឺលោក សយ សុភាព និងអ្នកគាំទ្រធំផ្នែកថវិកា។ ប៉ុន្មានថ្ងៃក្រោយមក អ្នកគាំទ្រផ្នែកថវិកានោះ ដែលជាថៅកែក្រុមហ៊ុនអភិវឌ្ឍន៍ដ៏ធំមួយបានបើកប្រព័ន្ធផ្សាយព័ត៍មានរបស់ខ្លួនផ្ទាល់ ដែលគាំទ្ររដ្ឋាភិបាល ដោយដាក់ឈ្មោះថា មជ្ឈមណ្ឌលព័ត៌មាននគរវត្ត។

អ្នកសារព័ត៌មាន ចាងហ្វាងបោះពុម្ពផ្សាយ និងអ្នកចែកចាយ ក៏ត្រូវស្ថិតក្រោមការបៀតបៀន និងការបំភិតបំភ័យក្នុងរូបភាពផ្សេងៗផងដែរ ដែលរួមមានដូចជាការអះអាងពីការ ឃុំខ្លួនបណ្តោះអាសន្ន ដោយខុសច្បាប់ ហើយអ្នកយកព័ត៌មាន និងចាងហ្វាងសារព័ត៌ បានសារភាពដោយស្ងាត់ៗពីការពិនិត្យចាប់ពិរុទ្ធលើខ្លួនឯងដោយសារភ័យខ្លាចការវាយបកពីរដ្ឋាភិបាល ។

នៅខែមិនា ឈ្មោះ រិន បូរ៉ា ដែលជាទាហានមកពីកងវរសេនាតូចលេខ ៥០៣ បានវាយដំយ៉ាងធ្ងន់ធ្ងរមកលើ អ្នកយកព័ត៌មានអោយកាសែតរស្មីកម្ពុជា ឈ្មោះ វង្ស ធូ ដោយសារបានថតវង្សល្បែងស៊ីសងមួយកន្លែងនៅតំបន់ប៉ោយប៉ែត។ បន្ទាប់ពីអ្នកសារព័ត៌មាននោះបានប្តឹងទៅនគរបាល ជនល្មើសបានសារភាពកំហុស។ អ្នកសារព័ត៌មាននោះបានដកពាក្យបណ្តឹង បន្ទាប់ពីរិន បូរ៉ាបានសុំទោស ហើយបង់លុយ។ រដ្ឋាភិបាលមិនបានចាត់ការផ្នែកព្រហ្មទណ្ឌឡើយ បន្ទាប់ពីការដកបណ្តឹងរដ្ឋប្បវេណី។

ស្ថានីយ៍ទូរទស្សន៍ និងស្ថានីយ៍វិទ្យុដែលគ្រប់គ្រងដោយរដ្ឋាភិបាល បានផ្សាយផ្ទាល់នូវការជំនុំជម្រះទាំង ៥ វគ្គ ក្នុងសវនាការដំបូងរបស់សាលាក្តីខ្មែរក្រហម (សូមមើលផ្នែក៥) និងបានចាក់ផ្សាយឡើងវិញនូវកិច្ចប្រជុំរបស់សភាជាតិ។ ទោះជាយ៉ាងណាក៏ដោយ ក្នុងករណីមួយចំនួន ការផ្សាយអំពីកិច្ចប្រជុំរបស់រដ្ឋសភាជាតិ មានការពិនិត្យកាត់ចេញយ៉ាងច្រើន ។ ស្ថានីយ៍វិទ្យុ និងទូរទស្សន៍ជាតិមានផ្សាយពីកម្មវិធីសិទ្ធិមនុស្ស សកម្មភាពសង្គម សុខភាពសាធារណៈ ការអប់រំ និងកម្មវិធីសង្គមស៊ីវិលខ្លះៗ ដែលផលិតដោយអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ។

## សេរីភាពអ៊ីនធ័រណែត

គ្មានរបាយការណ៍និយាយអំពីការតាមដានរបស់រដ្ឋាភិបាលលើអ៊ីម៉ែល ឬការឆ្លើយឆ្លងផ្ទាល់តាមអ៊ីនធ័រណែត ។ មនុស្សម្នាក់ៗ ឬក្រុមមនុស្សអាចសំដែងមតិដោយស្រួលតាមអ៊ីនធ័រណែត រួមទាំងអ៊ីម៉ែលផងដែរ។

តាមព័ត៌មានពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ មានអ្នកជាវប្រព័ន្ធអ៊ីនធ័រណែត ចំនួន ១៧៣ ៦៧៥នាក់ ដែលត្រូវជា ១% នៃប្រជាជនទាំងមូល។ អ្នកជាវភាគច្រើនគឺនៅភ្នំពេញ និងសៀមរាប។ នៅទីប្រជុំជន អ៊ីនធ័រណែតច្រើនមាននៅតាមហាងកាហ្វេអ៊ីនធ័រណែត។

## សេរីភាពខាងការសិក្សាអប់រំ និងពិធីវប្បធម៌

ជាទូទៅ ពុំមានឧបសគ្គផ្នែកច្បាប់ចំពោះសេរីភាពសិក្សាអប់រំឡើយ ។ ទោះជាយ៉ាងណាក៏ដោយ អ្នកធ្វើការក្នុងផ្នែកសិក្សាអប់រំច្រើនមានការប្រុងប្រយ័ត្ន នៅពេលបង្រៀនមុខវិជ្ជាពាក់ព័ន្ធនឹងនយោបាយ ដោយសារភ័យខ្លាចប៉ះពាល់អ្នកនយោបាយ ។

នៅខែកក្កដា ក្រសួងអប់រំបានហាមលើសៀវភៅអានចំណេះទូទៅចំនួន ២ ដែលសរសេរដោយលោក ប៉ែន ពុទ្ធសភា។ សៀវភៅទាំងពីរនេះមានសំណួរចំលើយទាក់ទងនឹងអំពើពុករលួយក្នុងជួររដ្ឋាភិបាល ដោយចាត់ទុកថាវាជាឧបសគ្គដល់ការអភិវឌ្ឍប្រទេស ហើយចោទថា រដ្ឋាភិបាលមិនគោរពសិទ្ធិមនុស្ស។ សមត្ថកិច្ចបានប្រមូលសៀវភៅទាំងនោះមិនអោយលក់តាមកន្លែងលក់សៀវភៅ ហើយបានព្រមានអ្នកលក់មិនអោយលក់ ឬដាក់តាំងសៀវភៅទាំងនោះទៀត។ លោក ពុទ្ធសភាបាននិយាយថា លោកបានទទួលការគំរាមតាមទូរស័ព្ទពីជនអនាមិក។

ផ្ទុយទៅនឹងឆ្នាំ ២០០៩ មិនមានសេចក្តីរាយការណ៍ការពីការរឹតត្បិតដោយរដ្ឋាភិបាលលើពិធីវប្បធម៌ឡើយ។

## ខ. សេរីភាពប្រមូលផ្តុំគ្នា និងសេរីភាពបង្កើតអង្គការ/សមាគម

រដ្ឋធម្មនុញ្ញមានចែងអំពីសេរីភាពប្រមូលផ្តុំគ្នា ដោយសន្តិវិធី ប៉ុន្តែមានពេលខ្លះ រដ្ឋាភិបាលមិនបានគោរពសិទ្ធិនេះទេនៅក្នុងការអនុវត្តជាក់ស្តែង ។

នៅថ្ងៃទី ១៣ ខែមករា ក្រសួងអប់រំបានហាមប្រាមការប្រមូលផ្តុំគ្នារបស់គ្រូ មន្ត្រីអប់រំ និងថ្នាក់គ្រប់គ្រងសាលា នៅក្នុងទីធ្លាសាលា ដើម្បីពិភាក្សាពីស្ថានភាពសង្គម ឬរឿងនយោបាយ។ បទបញ្ជានោះនិយាយថា ការប្រមូលផ្តុំគ្នាដើម្បីបំណងបែបនោះគឺជាការរំលោភលើច្បាប់ជាតិស្តីពីការសិក្សាអប់រំ។

ច្បាប់តំរូវអោយមានការសុំការអនុញ្ញាតជាមុន មុននឹងធ្វើការដង្ហែរក្បួនតវ៉ា ឬបាតុកម្ម។ ខមួយចែងពីការជំរាបប្រាប់ចំនួន ៥ ថ្ងៃមុន សំរាប់ការធ្វើបាតុកម្មដោយសន្តិវិធី ចំណែកខមួយទៀតចែងពីការតំរូវអោយជូនដំណឹងចំនួន ១២ ម៉ោងមុន សំរាប់ការប្រមូលផ្តុំគ្នាដោយមិនមានការគ្រោងទុក នៅលើទីកន្លែងឯកជន ឬនៅទីកន្លែងតវ៉ាដោយសន្តិវិធី ក្នុងខេត្តនិមួយៗ ហើយកំរិតចំនួនអ្នកចូលរួមត្រឹម ២០០ នាក់។ តាមច្បាប់ អាជ្ញាធរខេត្ត និងអាជ្ញាធរក្រុងមានការទទួលខុសត្រូវក្នុងការសំរេចចេញការអនុញ្ញាតអោយធ្វើបាតុកម្ម។ តាមភាពជាក់ស្តែង ពិសេសនៅភ្នំពេញ មន្ត្រីអាជ្ញាធរថ្នាក់ក្រោមជឿថា អាជ្ញាធរថ្នាក់ជាតិគឺជាអ្នកមានសិទ្ធិសំរេច ហើយធ្វើការបដិសេធសំណើសុំ បើអាជ្ញាធរថ្នាក់ជាតិមិនផ្តល់ការអនុញ្ញាតច្បាស់អោយធ្វើការប្រមូលផ្តុំគ្នានោះទេ។ តាមធម្មតា អាជ្ញាធរមិនផ្តល់ការអនុញ្ញាតដល់ក្រុមដែលរិះគន់គណបក្សដឹកនាំប្រទេសទេ ឬរិះគន់ប្រទេសដែលមានភាពជិតស្និទ្ធនឹងរដ្ឋាភិបាល។ អាជ្ញាធរលើកហេតុផលតំរូវអោយមានស្ថេរភាព និងសន្តិសុខសាធារណៈចំពោះការមិនផ្តល់ការអនុញ្ញាតិ។ តែច្បាប់មិនកំណត់ច្បាស់នូវន័យនៃពាក្យ ថាស្ថេរភាព និងសន្តិសុខសាធារណៈ សំរាប់ជួយអាជ្ញាធរក្នុងការអនុវត្តច្បាប់ទេ។ នគរបាលបំបែកហ្វូងមនុស្សដែលប្រមូលផ្តុំគ្នាដោយគ្មានការអនុញ្ញាតិ ដោយក្នុងករណីខ្លះបណ្តាលអោយមានរបួសតិចតួចដល់បាតុករខ្លះ។

នៅថ្ងៃទី ១ ខែមិនា នគរបាលខ័ណ្ឌដង្កោរបានរាំងក្រុមអ្នកភូមិចំនួនជាង ១០០ នាក់មិនអោយនាំគ្នាដើរមកកាន់ផ្ទះរបស់លោកនាយករដ្ឋមន្ត្រីនៅតាខ្មៅ ដើម្បីទាញការចាប់អារម្មណ៍លើជំលោះដីធ្លីរបស់គេដែលកំពុងមានជាមួយមន្ត្រីក្រសួងមហាផ្ទៃ ឈ្មោះ អ៊ុន សាម៉ន។ នគរបាលចាប់ខ្លួនអ្នកភូមិចំនួន ៨ នាក់ ដោយឃុំពួកគេរាប់ម៉ោង ហើយគំរាមចាប់ដាក់គុក របហូតទាល់តែអ្នកភូមិសុខចិត្តផ្តិតមេដៃឈប់តវ៉ារឿងដីធ្លី។ អ្នកសង្កេតការណ៍មកពីអង្គការសិទ្ធិមនុស្សមួយចំនួនក៏បាយរាយការណ៍ផងដែរថា នគរបាលបានរឹបអូសយកជាបណ្តោះអាសន្ននូវម៉ាស៊ីនថតរបស់គេ ហើយលុបរូបទាំងអស់ដែលត្រូវបានថតក្នុងព្រឹត្តិការណ៍ថ្ងៃនោះមុនពេលប្រគល់ម៉ាស៊ីនថតអោយវិញ។

នៅថ្ងៃទី ៨ ខែសីហា សមត្ថកិច្ចបានបំបែកហ្វូងមនុស្សប្រមាណជាង ៥០ នាក់ ដែលជាអ្នកភូមិមកពីខេត្តបាត់ដំបង ដែលបានមកប្រមូលផ្តុំគ្នានៅពីមុខផ្ទះនាយករដ្ឋមន្ត្រី ក្នុងក្រុងភ្នំពេញ ដើម្បីតវ៉ារឿងជំលោះដីធ្លីរវាងគ្រួសារចំនួន ៤០០ និងក្រុមទាហាន។ សមត្ថកិច្ចក្នុងសំលៀកបំពាក់ស៊ីវិលដែលគេមិនស្គាល់ បានអូសអ្នកភូមិពីក្នុងសួន ហើយបានបង្ខំអោយគេឡើងជិះឡានដែលរដ្ឋាភិបាលបានជួល ដើម្បីនាំពួកគេត្រឡប់ទៅខេត្តបាត់ ដំបងវិញ។ ក្នុងករណីខ្លះ សមត្ថកិច្ចរុញអ្នកភូមិចូលទៅក្នុងឡានក្រុង ដោយមិនគិតពីសុវត្ថិភាពឡើយ។ បន្ទាប់មក ឡាននោះបានទំលាក់អ្នកភូមិនៅចំងាយជិត ២០ ម៉ែល៍ពីសហាគមន៍របស់គេ។

ក្នុងឆ្នាំនៃរបាយការណ៍នេះ អង្គការ ADHOC បានរាយការណ៍ថា មានការតវ៉ាចំនួន ១៨៣ ដែលភាគច្រើនទាក់ទងនឹងជំលោះដីធ្លី ឬជំលោះការងារ។

**សេរីភាពបង្កើតអង្គការ/សមាគម**

រដ្ឋធម្មនុញ្ញមានចែងអំពីសេរីភាពបង្កើតអង្គការ/សមាគម ហើយរដ្ឋាភិបាលជាទូទៅបានគោរពសិទ្ធិនេះនៅក្នុងការអនុវត្តជាក់ស្តែង ទោះបីជារដ្ឋាភិបាលមិនបានអនុវត្តប្រកបដោយប្រសិទ្ធភាពនូវបទបប្បញ្ញត្តិស្តីពីអង្គការ/សមាគមក៏ដោយ (សូមមើលត្រង់ផ្នែក ៧.ក) ។

សមាជិកភាពក្នុងក្រុមខ្មែរក្រហម ដែលបានដឹកនាំប្រទេសពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ហើយដែលបន្ទាប់ពីការដួលរលំ នៃរបបនេះ បានធ្វើការបះបោរប្រដាប់អាវុធប្រឆាំងនឹងរដ្ឋាភិបាល មានលក្ខណៈខុសច្បាប់ ចំណែកឯសមាជិកភាពក្នុងក្រុមប្រដាប់អាវុធណាមួយក៏ខុសច្បាប់ដែរ ។

**គ. សេរីភាពសាសនា**

ចំពោះសេចក្តីរៀបរាប់លំអិតស្តីពីសេរីភាពសាសនា សូមមើល*របាយការណ៍ស្តីពីសេរីភាពសាសនាអន្តរជាតិ ឆ្នាំ ២០១០* តាមគេហទំព័រ www.state.gov/g/drl/irf/rpt ។

**ឃ. សេរីភាពដើរហើរ ជនផ្លាស់ទីកន្លែងក្នុងស្រុក ការការពារជនភៀសខ្លួន និងជនគ្មានប្រទេស**

ច្បាប់មានចែងអំពីសេរីភាពដើរហើរនៅក្នុងប្រទេស ការធ្វើដំណើរនៅបរទេស និរប្រវេសន៍ និងមាតុភូមិនិវត្តន៍ ហើយជាទូទៅ ក្នុងការអនុវត្តជាក់ស្តែង រដ្ឋាភិបាលបានគោរពសិទ្ធិទាំងនេះ ។ នៅក្នុងការអនុវត្តជាក់ស្តែងជាទូទៅរដ្ឋាភិបាល មិនបានផ្តល់កិច្ចការពារ ឬជំនួយដល់ជនផ្លាស់ទីលំនៅក្នុងស្រុក ជនភៀសខ្លួន

ជនភៀសខ្លួនមាតុភូមិនិវត្តន៍ អ្នកស្វែងរកសិទ្ធិជ្រកកោន ជនគ្មានប្រទេសឬបុគ្គលដែលធ្វើអោយមានក្តីបារម្ភដទៃទៀតឡើយ ប៉ុន្តែជាទូទៅ រដ្ឋាភិបាលអនុញ្ញាតអោយអង្គការមនុស្សធម៌ផ្តល់កិច្ចការពារ និងជំនួយដូចពោលមកនេះ ។ រដ្ឋាភិបាលបានសហការជាមួយការិយាល័យឧត្តមស្នងការសហប្រជាជាតិ ទទួលបន្ទុកជនភៀសខ្លួន (UNHCR) ដើម្បីផ្តល់កិច្ចការ និងជំនួយដល់អ្នកស្វែងរកសិទ្ធិជ្រកកោនជនជាតិម៉ុងតាញ៉ា ។

រដ្ឋធម្មនុញ្ញហាមឃាត់មិនអោយមានការនិរទេសដោយបង្ខំ ហើយរដ្ឋាភិបាលមិនបានប្រើប្រាស់មធ្យោបាយនេះឡើយ ។

**ការការពារជនភៀសខ្លួន**

ច្បាប់ប្រទេសកម្ពុជាមានចែងអំពីការផ្តល់សិទ្ធិជ្រកកោន និងឋានៈជាជនភៀសខ្លួន ហើយរដ្ឋាភិបាលបានរៀបចំប្រព័ន្ធមួយសម្រាប់ផ្តល់កិច្ចការពារដល់ជនភៀសខ្លួន ។ នៅថ្ងៃខែធ្នូ ឆ្នាំ ២០០៩ រដ្ឋាភិបាលបានចេញអនុក្រឹត្យមួយ ដោយផ្តល់ធរមានភាពដល់ការទទួលខុសត្រូវទាំងស្រុងរបស់ខ្លួនចំពោះដំណើរការកំណត់ឋានៈជាជនភៀសខ្លួន ដោយត្រួតពិនិត្យជាចុងក្រោយលើដំណើរការ ដែលពីមុនត្រូវបានគ្រប់គ្រងរួមគ្នាជាមួយអង្គការ UNHCR ចាប់តាំងពីឆ្នាំ ២០០៨ មក ។ អង្គការ UNHCR បានបន្តផ្តល់ការបណ្តុះបណ្តាល និងជំនួយបច្ចេកទេសដទៃទៀត ហើយបានចូលរួមក្នុងការសំភាសន៍ និងចេញអនុសាសន៍ដល់រដ្ឋាភិបាលស្តីពីករណីសុំសិទ្ធិជ្រកកោន ។

អនុស្សរណៈនៃការយោគយល់ឆ្នាំ២០០៥ ជាមួយអង្គការ UNHCR និងរដ្ឋាភិបាលវៀតណាម ដើម្បីដោះស្រាយ ស្ថានភាពជនជាតិម៉ុងតាញ៉ា ក្រោមកិច្ចការពាររបស់អង្គការ UNHCR ស្ថិតនៅជាធរមាននៅឡើយ ។ អ្នកសុំ សិទ្ធិជ្រកកោនដែលបានមកដល់ការិយាល័យអង្គការ UNHCR នៅភ្នំពេញត្រូវបានត្រួតពិនិត្យដោយមានកិច្ចសហការរបស់រដ្ឋាភិបាល ។ នៅអំឡុងឆ្នាំនេះ ជនជាតិម៉ុងតាញ៉ាចំនួន ២ នាក់ និងអ្នកមកដល់ថ្មីដទៃទៀតចំនួន ៤៧ នាក់បានសុំសិទ្ធិជ្រកកោន ។ លើសពីនេះទៀត អ្នកសុំសិទ្ធិជ្រកកោនបានឆ្លងទន្លេបានកូន២ នាក់នៅក្នុងប្រទេស ដែលមានម្នាក់ជាជនជាតិម៉ុងតាញ៉ា និងម្នាក់ទៀតមិនមែនជាជនជាតិម៉ុងតាញ៉ា។ បើយោងតាមអង្គការ UNHCR ជនជាតិម៉ុងតាញ៉ាចំនួន ១២ នាក់ និង ជនភៀសខ្លួន ២ នាក់ផ្សេងទៀតបានចាកចេញទៅកាន់ប្រទេសទីបី ខណៈពេលដែលអាជ្ញាធរបានបញ្ជូនជនជាតិម៉ុងតាញ៉ាស្វែងរកសិទ្ធិជ្រកកោនដែលត្រូវបានបដិសេធអោយត្រឡប់ទៅប្រទេសវៀតណាមវិញ។ នៅសល់ជនជាតិម៉ុងតាញ៉ា

ចំនួន ៦៥ នាក់នៅក្នុងទីតាំងការពាររបស់អង្គការ UNHCR នៅភ្នំពេញ ដែលជាទីតាំងគេចេញចូលបាន ដោយមានកំរិតព្រំដែន។ ជនស្វែងរកសិទ្ធិជ្រកកោន និងជនភៀសខ្លួនម៉ុងតាញ៉ា នៅទីនោះដែលស្ថិតនៅក្រោម ការការពាររបស់អង្គការ UNHCR អាចចាកចេញបានតែនៅក្រោមអនុញ្ញាត និងការហែរហមជាមួយដោយ អង្គការ UNHCR ។ បើយោងតាមអង្គការ UNHCR ក្នុងឆ្នាំនៃរបាយការណ៍នេះ គ្មានជនភៀសខ្លួនណាមួយ ស្នើសុំការធ្វើសមាហរណកម្មនៅក្នុងស្រុកទេ។

ជាទូទៅរដ្ឋាភិបាលបានផ្តល់កិច្ចការពារប្រឆាំងនឹងការបណ្តេញចេញ និងការបញ្ជូនត្រឡប់ជន ភៀសខ្លួនទៅកាន់ប្រទេសដែលក្នុងនោះជីវិត ឬសេរីភាពរបស់ពួកគេស្ថិតក្រោមការគម្រាមកំហែង ដោយ សារពូជសាសន៍ សាសនា សញ្ជាតិ សមាជិកភាពរបស់គេនៅក្នុងក្រុមសង្គម ឬដោយសារទស្សនៈនយោបាយ ណាមួយជាដើម ។

គ្មានសេចក្តីរាយការណ៍ពីករណីដែលរដ្ឋាភិបាលបានរំលោភ ឬធ្វើបាបជនភៀសខ្លួន ឬជនសុំសិទ្ធិ ជ្រកកោនឡើយ ហើយការរឹតត្បិតលើការដើរហើរត្រូវបានដាក់តែក្នុងករណីជនជាតិម៉ុងតាញ៉ាដែលស្ថិតនៅ ក្រោមកិច្ចព្រមព្រៀងត្រួតពិនិត្យពិសេសតែប៉ុណ្ណោះ។

គ្មានព្រឹត្តិការណ៍ក្នុងករណីនៃជនស្វែងរកសិទ្ធិជ្រកកោនអ៊ុយហ្គ័រទាំង ២០ នាក់ ដែលត្រូវបានចាប់ បញ្ជូនទៅប្រទេសចិនវិញ នៅខែធ្នូ ឆ្នាំ ២០០៩ ទេ។

**ជនគ្មានប្រទេស** [**ជនគ្មានរដ្ឋ**]

ប្រទេសកម្ពុជាមានអ្នករស់នៅដែលជាជនគ្មានប្រទេស ចំណែកឯរដ្ឋាភិបាលមិនបានអនុវត្តច្បាប់ឬ គោលនយោបាយ ប្រកបដោយប្រសិទ្ធភាព ដើម្បីផ្តល់ឱកាសដល់ជនទាំងនោះអោយទទួលបានសញ្ជាតិឡើយ ។ តាមច្បាប់សញ្ជាតិ ឋានៈជាពលរដ្ឋអាចទទួលបានពីកំណើតដោយសារម្តាយ និងឪពុកដែលមិនមែនជាតិ ខ្មែរប្រសិនបើអ្នកទាំងពីរបានកើត និងកំពុងរស់នៅដោយស្របច្បាប់នៅប្រទេសកម្ពុជា ឬប្រសិនបើឪពុក ឬម្តាយបានទទួលឋានៈជាពលរដ្ឋកម្ពុជា ។

ការសិក្សាមួយនៅឆ្នាំ២០០៧ ដោយអង្គការ UNHCR ប៉ាន់ប្រមាណថាអ្នកដែលអាចគ្មានប្រទេស ជាច្រើនពាន់នាក់បានរស់នៅក្នុងប្រទេសកម្ពុជា ។ ទោះជាយ៉ាងណាក៏ដោយ ការប៉ាន់ស្មាននៃការសិក្សានេះ បាន មកពីភស្តុតាងមិនអាចជឿទុកចិត្តពីអង្គការ NGO នានា ហើយតំណាងរបស់អង្គការ UNHCR នៅ

ក្នុងស្រុក មិនបានចាត់ទុកថាតួលេខទាំងនេះមានលក្ខណៈប្រាកដប្រជាឡើយ ។ ហេតុផលដែលច្រើនមានជាងគេចំពោះភាពគ្មានប្រទេសគឺកង្វះឯកសារត្រឹមត្រូវពីប្រទេសកំណើត។

អង្គការ UNHCR បានថ្លែងថា ប្រជាជនដែលគ្មានប្រទេសនៅកម្ពុជា ភាគច្រើនគឺក្រុមអាណិកជនវៀតណាម។ បើយោងតាមអង្គការមិនមែនរដ្ឋាភិបាលមួយ បុគ្គលដែលគ្មានភស្តុតាងសញ្ជាតិ ច្រើនមិនសូវបានទទួលបានការងារដែលមានលក្ខណៈផ្លូវការ ការសិក្សា ការចុះបញ្ជីអាពាហ៍ពិពាហ៍ លទ្ធភាពតាមផ្លូវតុលាការនិងកម្មសិទ្ធិដីធ្លីទេ។

## ផ្នែកទី៣ ៖ ការគោរពសិទ្ធិនយោបាយ ៖ សិទ្ធិពលរដ្ឋដើម្បីផ្លាស់ប្ដូររដ្ឋាភិបាលរបស់ខ្លួន

រដ្ឋធម្មនុញ្ញផ្ដល់សិទ្ធិដល់ប្រជាពលរដ្ឋក្នុងការផ្លាស់ប្ដូររដ្ឋាភិបាលរបស់ខ្លួនដោយសន្តិវិធី ហើយជាទូទៅប្រជាពលរដ្ឋប្រើប្រាស់សិទ្ធិនេះនៅក្នុងការអនុវត្តជាក់ស្ដែង តាមរយៈការបោះឆ្នោតតាមពេលវេលាជាទៀងទាត់ ផ្អែកតាមការបោះឆ្នោតជាសាកល ។ ការបោះឆ្នោតធ្វើឡើងដោយស្ម័គ្រចិត្ត សម្រាប់ប្រជាពលរដ្ឋដែលមានអាយុចាប់ពី១៨ ឆ្នាំឡើងទៅ ។

## ការបោះឆ្នោត និងការចូលរួមផ្នែកនយោបាយ

ការបោះឆ្នោតថ្នាក់ជាតិថ្មីៗបំផុតដែលត្រូវបានធ្វើឡើងនៅខែ ឆ្នាំ២០០៨ សម្រាប់សភាជាតិ ជារួមមានលក្ខណៈសន្តិភាព ដោយមានដំណើរការមួយ ដែលជាទូទៅ ត្រូវបានចាត់ទុកថាមានភាពប្រសើរជាងពេលបោះឆ្នោតកន្លងទៅ ។ ទោះជាយ៉ាងណាក៏ដោយ អ្នកសង្កេតការណ៍បានកត់សម្គាល់ថា ការបោះឆ្នោតនេះមិនត្រូវតាមស្តង់ដារអន្តរជាតិ ពេញលេញឡើយ ។ ទោះបីជាមានភាពមិនប្រក្រតីមួយចំនួននៅថ្ងៃបោះឆ្នោតក៏ដោយ ក៏ភាពមិនប្រក្រតីទាំងនោះ មានចំនួនតិច ហើយមិនទំនងជាធ្វើអោយប៉ះពាល់ដល់លទ្ធផល ឬខុសពីឆន្ទៈរបស់អ្នកបោះឆ្នោតឡើយ ។

នៅខែឧសភា ឆ្នាំ ២០០៩ ប្រទេសកម្ពុជាបានរៀបចំការបោះឆ្នោតអសកល ដើម្បីជ្រើសរើសអាសនៈក្រុមប្រឹក្សាខេត្តចំនួន ៣៧៤ និងស្រុកចំនួន ២ ៨៦១ ជាលើកដំបូងក្នុងប្រវត្តិសាស្ត្ររបស់ខ្លួន ជាផ្នែកមួយនៃគំនិតផ្តួចផ្តើមវិមជ្ឈការ វិសហមជ្ឈការរបស់រដ្ឋាភិបាល ។ ការបោះឆ្នោតត្រូវបានកម្រិតតែក្នុងចំណោមសមាជិកក្រុមប្រឹក្សាឃុំចំនួន ១១ ៣៥៣នាក់ដែលបានជាប់ឆ្នោតនៅក្នុងការបោះឆ្នោត ឃុំនៅឆ្នាំ២០០៧ ។ គណបក្សប្រជាជនកម្ពុជា បានទទួលអាសនៈថ្នាក់ខេត្តចំនួន ៣០២ និងអាសនៈថ្នាក់ស្រុកចំនួន

២ ២៤៩ ហើយអាសនៈដែលនៅសល់ត្រូវបែងចែកក្នុងចំណោមគណបក្សរាជានិយម និងគណបក្សប្រឆាំង ។

គណបក្សអាចចុះបញ្ជី ហើយបុគ្គលមានសេរីភាពប្រកាសបេក្ខភាពរបស់ខ្លួនដោយគ្មានការរឹតត្បិត ។

អង្គការមិនមែនរដ្ឋាភិបាល និងគណបក្សនយោបាយមួយចំនួន បានចោទប្រកាន់ថាសមាជិកភាពនៅក្នុងគណបក្សប្រជាជនកម្ពុជាដែលនាំមុខគេ បានផ្តល់អត្ថប្រយោជន៍ ដូចជាអំណោយ ឬជំនួយសង្គ្រោះបន្ទាន់របស់រដ្ឋាភិបាល ។

វប្បធម៌ប្រពៃណីបានកម្រិតតួនាទីរបស់ស្ត្រីនៅក្នុងរដ្ឋាភិបាល ។ ទោះជាយ៉ាងណាក៏ដោយ ស្ត្រីបានចូលរួមនៅក្នុង ការបោះឆ្នោតអសកល ដើម្បីជ្រើសរើសក្រុមប្រឹក្សាខេត្ដ និងស្រុក នៅខែឧសភា ឆ្នាំ ២០០៩ ។ មានស្ត្រីចំនួន ២៨ នាក់ បានកាន់កាប់អាសនៈ សភាដែលមានចំនួន ១២៣អាសនៈ និងស្ត្រីចំនួន ៩ នាក់នៅក្នុង ព្រឹទ្ធសភាដែលមាន ៦១ អាសនៈ ។ មានឧបនាយករដ្ឋមន្ត្រីម្នាក់ជាស្ត្រី និងមានស្ត្រីជារដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ និងមន្ត្រីគណៈកម្មការរៀបចំ ការបោះឆ្នោត សរុបចំនួន ៤៥នាក់ ។ ស្ត្រីក៏បានបំពេញតួនាទីជាទីប្រឹក្សាផងដែរ ហើយមានចៅក្រម និងព្រះរាជអាជ្ញាជាស្ត្រីចំនួន ៣១ នាក់នៅតុលាការរាជធានី តុលាការខេត្ត សាលាឧទ្ធរណ៍ និងតុលាការកំពូល ។ ទោះបីជាគ្មានអភិបាលខេត្តជាស្ត្រីក៏ដោយ ក៏រដ្ឋាភិបាលបានតែងតាំងស្ត្រីជាអភិបាលរងខេត្ត នៅគ្រប់ខេត្ត និងរាជធានីភ្នំពេញលើកលែងតែខេត្តមួយប៉ុណ្ណោះ ។ គណៈកម្មការជាតិរៀបចំការបោះឆ្នោតបានរាយការណ៍ថា ស្ត្រីបានកាន់កាប់ ១៥ ភាគរយនៃអាសនៈក្រុមប្រឹក្សាស្រុក និង ១០ ភាគរយនៃអាសនៈក្រុមប្រឹក្សាខេត្ត ។

មានសមាជិកជាជនជាតិភាគតិចំនួន ៥នាក់ បួននាក់ជាជនជាតិចាម និងម្នាក់ទៀតជាជនជាតិភាគតិចផ្សេងទៀត នៅក្នុងសភាជាតិ ។ មានសមាជិកជនជាតិភាគតិចបីរូបផងដែរនៅក្នុងព្រឹទ្ធសភា ។ យ៉ាងហោចណាស់មាន មន្ត្រីប្រាំបីរូប មកពីក្រុមជនជាតិភាគតិច កាន់មុខតំណែងជាន់ខ្ពស់នៅក្នុងរដ្ឋាភិបាល ។

## ផ្នែកទី៤ ៖ អំពើពុករលួយផ្លូវការ និងតម្លាភាពរបស់រដ្ឋាភិបាល

ច្បាប់មានចែងអំពីទោសព្រហ្មទណ្ឌសម្រាប់អំពើពុករលួយផ្លូវការ ទោះជាយ៉ាងណាក៏ដោយ រដ្ឋាភិបាលមិនបានអនុវត្តច្បាប់នេះប្រកបដោយប្រសិទ្ធភាពឡើយ ហើយមន្ត្រីជាញឹកញាប់តែងតែចូលរួមក្នុងអំពើពុករលួយដោយនិទណ្ឌភាព ។

នៅថ្ងៃទី ២០ ខែមករា រដ្ឋាភិបាលបានប្រកាសអោយប្រើក្រមព្រហ្មទណ្ឌថ្មី ដែលកំណត់ន័យនៃអំពើពុករលួយ ហើយបញ្ជាក់ពីទោសសំរាប់អំពើនិមួយៗ។ ក្រមព្រហ្មទណ្ឌនេះបានចូលជាធរមាននៅថ្ងៃទី ២១ ខែធ្នូ។ នៅថ្ងៃទី ១៧ ខែមេសា រដ្ឋាភិបាលបានប្រកាសអោយប្រើច្បាប់ប្រឆាំងអំពើពុករលួយ ដែលបង្កើតបានជាមូលដ្ឋានច្បាប់សំរាប់ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ និងអង្គភាពប្រឆាំងអំពើពុករលួយ ដើម្បីទទួលនិងស៊ើបអង្កេតបណ្តឹងទាក់ទងនឹងអំពើពុករលួយ។ យោងតាមច្បាប់នេះ រដ្ឋាភិបាលបានតែងតាំងសមាជិក ក្រុមប្រឹក្សាចំនួន ១១ រូប កាលពីខែមិថុនា។ អ្នកស៊ើបអង្កេតចំនួន ១៤ រូបសំរាប់អង្គភាព ប្រឆាំងអំពើពុករលួយត្រូវបានតែងតាំង នៅខែសីហា អង្គភាពនេះបានចាប់ផ្តើមទទួលបណ្តឹងនៅក្នុងខែដដែលនោះ។

អំពើពុករលួយត្រូវចាត់ទុកថាមានលក្ខណៈរាលដាល និងទូលំទូលាយនៅគ្រប់ផ្នែកនៃសង្គម រួមទាំងផ្នែកនីតិ ប្រតិបត្តិ នីតិបញ្ញត្តិ និងតុលាការនៃរដ្ឋាភិបាល ។ មានសេចក្តីរាយការណ៍មកថា នគរបាល ព្រះរាជអាជ្ញា ចៅក្រមស៊ើបអង្កេត និងចៅក្រមជំរះក្តី បានទទួលសំណូកពីអ្នករកស៊ីខុសច្បាប់។ ការប្រឈមនឹងអំពើពុករលួយដោយសាធារណជនត្រូវបានរាយការណ៍មកថា មានលក្ខណៈទូលំទូលាយ ដែលជាការបញ្ជាក់ថាអំពើពុករលួយជាច្រើនពុំមានការលាក់លៀមឡើយ ។ បៀវត្សរ៍មិនគ្រប់គ្រាន់រួមចំណែកអោយមាន "អំពើពុករលួយដើម្បីរស់" ក្នុងចំណោមមន្ត្រីថ្នាក់ទាប ចំណែកវប្បធម៌និទណ្ឌភាពធ្វើអោយអំពើពុករលួយរីកសាយក្នុងចំណោមមន្ត្រីជាន់ខ្ពស់ ។ នៅខែមេសា តុលាការក្រុងភ្នំពេញបានដាក់ទោសមន្ត្រីក្រសួង យុត្តិធម៌ម្នាក់អោយជាប់ពន្ធនាគារចំនួន ៨ ឆ្នាំ ពីបទទទួលសំណូក។

ក្រោមច្បាប់ប្រឆាំងអំពើពុករលួយ មន្ត្រីរាជការត្រូវប្រកាសទ្រព្យសម្បត្តិរបស់គេ។

ច្បាប់ស្តីពីបណ្ណាសារជាតិ (National Archives Law) អនុញ្ញាតអោយគេមើលឯកសារព័ត៌មានគ្មានកំណត់ នៅក្នុងប័ណ្ណសារសាធារណៈ ។ ទោះជាយ៉ាងណាក៏ដោយ ច្បាប់នេះផ្តល់លទ្ធភាពអោយមើលឯកសាររដ្ឋាភិបាលដែលមិនត្រូវបានបញ្ជាក់ច្បាស់ តែក្នុងរយៈ ២០ឆ្នាំក្រោយមកតែប៉ុណ្ណោះ ចំណែកឯកសារប៉ះពាល់ដល់សន្តិសុខជាតិ និងការពារជីវិតផ្ទាល់ខ្លួនអាចបញ្ចេញអោយបានបន្ទាប់ពីរយៈពេល ៤០ឆ្នាំ និង ១២០ឆ្នាំក្រោយមកតែប៉ុណ្ណោះ។ មាន អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនបានរាយការណ៍ថា នៅក្នុងភាពជាក់ស្តែង ខ្លួនមានការលំបាកក្នុងការ ទទួលបានព័ត៌មាន។ រដ្ឋាភិបាលជាញឹកញាប់មិនបាន ឬមិនអាចឆ្លើយតបចំពោះសំណើសុំព័ត៌មានបានឡើយ ។

**ផ្នែកទី៥ ៖ ឥរិយាបថរបស់រដ្ឋាភិបាលចំពោះការអង្កេតរបស់អង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលលើការរំលោភសិទ្ធិមនុស្សដែលត្រូវបានចោទប្រកាន់**

អង្គការសិទ្ធិមនុស្សក្នុងស្រុក និងអន្តរជាតិផ្សេងៗ ជាទូទៅ ធ្វើប្រតិបត្តិការដោយគ្មានការរឹតត្បិតពីរដ្ឋាភិបាល ឡើយ ក្នុងការស៊ើបអង្កេត និងបោះពុម្ពផ្សាយរបកគំហើញអំពីករណីសិទ្ធិមនុស្សរបស់ខ្លួន ។ ជារឿយៗ មន្ត្រីរដ្ឋាភិបាលបានសហការជាមួយបុគ្គលិកសិទ្ធិមនុស្សក្នុងការស៊ើបអង្កេតរបស់ខ្លួន ។ ទោះជាយ៉ាងណាក៏ដោយ មានរបាយការណ៍ជាច្រើនអំពីកង្វះខាតកិច្ចសហការ ហើយនៅក្នុងករណីមួយចំនួន មានការបំភិតបំភ័ដោយមន្ត្រី រដ្ឋាភិបាលមូលដ្ឋាន ។

មានអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការងារផ្នែកសិទ្ធិមនុស្សប្រមាណជា ៤០ នៅក្នុងប្រទេសកម្ពុជា ប៉ុន្តែមានតែអង្គការមួយចំនួនតូចប៉ុណ្ណោះ ដែលចូលរួមយ៉ាងសកម្មក្នុងការរៀបចំកម្មវិធីបណ្តុះបណ្តាលឬស៊ើបអង្កេតការរំលោភសិទ្ធិមនុស្ស ។

អង្គការសិទ្ធិមនុស្សក្នុងស្រុក និងអន្តរជាតិ ជួបប្រទះការគម្រាមកំហែង និងការធ្វើទុក្ខបុកម្នេញពីមន្ត្រីមូលដ្ឋាន ។ អំពើទាំងនេះមានលក្ខណៈជាទម្រង់រឹតត្បិត និងការរំខានដល់ការជួបប្រជុំដែលឧបត្ថម្ភដោយអង្គការមិនមែន រដ្ឋាភិបាលនានា ការបំភិតបំភ័យដោយពាក្យសម្តី ការគម្រាមចាត់វិធានការផ្លូវច្បាប់ និងការរារាំងតាមបែបការិយាធិបតេយ្យ ។ មេធាវីបម្រើផលប្រយោជន៍សាធារណៈរបស់អង្គការមិនមែនរដ្ឋាភិបាលបាននិយាយថាធ្លាប់ត្រូវបានបដិសេធមិនអោយជួបកូនក្តីដែលជាប់ឃុំ ក្នុងករណីរំលោភសិទ្ធិមនុស្សមួយចំនួន ហើយអង្គការមិនមែនរដ្ឋាភិបាលបានរាយការណ៍ថា មន្ត្រីរដ្ឋាភិបាលបានព្រមានថា តំណាងអង្គការមិនមែនរដ្ឋាភិបាល អាចត្រូវចោទប្រកាន់ពីបទផ្សាយព័ត៌មានមិនពិត និង ញុះញង់ ប្រសិនបើខ្លួននិយាយទៅកាន់បណ្តាញសារព័ត៌មានអំពីករណីទាំងនោះ ។

នៅថ្ងៃទី ១ ខែមករា ភ្នាក់ងាររបស់អង្គការ ADHOC បានត្រឡប់មកធ្វើការនៅខេត្តរតនៈគីរីវិញ បន្ទាប់ពីគេបានចាកចេញទៅ នៅខែសីហា ឆ្នាំ ២០០៩ បន្ទាប់ពីចៅក្រមមូលដ្ឋានបាននិយាយថា ការចោទប្រកាន់នឹងត្រូវពន្យារ ប្រសិនបើគេចាកចេញពីខេត្តនោះ។ គ្មានការចោទប្រកាន់បន្ថែម លើភ្នាក់ងារនោះទេ នៅពេលគេត្រឡប់មកវិញ ថ្វីបើមានការស៊ើបអង្កេតជាបន្តលើជំលោះដីធ្លីជាមួយអ្នកភូមិ រួមទាំងការចោទប្រកាន់ពីដើមមកនៅឆ្នាំ ២០០៩ ប្រឆាំងនឹងភ្នាក់ងារទាំងនោះក្តី។

នៅថ្ងៃទី ១៥ ខែធ្នូ រដ្ឋាភិបាលបានបញ្ចេញសេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលដើម្បីទទួលមតិពីសាធារណៈ។ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអង្គការមិនមែនរដ្ឋាភិបាល

អន្តរជាតិបានសំដែងកង្វល់យ៉ាងខ្លាំងចំពោះពង្រាងច្បាប់នេះ ដែលមានភាសាតំរូវអោយមាន ការធ្វើរបាយការណ៍តឹងតែងស្តីពីអង្គការមិនមែនរដ្ឋាភិបាល តំរូវអោយសមាគមមានសមាជិកចាប់ពី ២១ នាក់ឡើងទៅទើបមានឋានៈស្របច្បាប់ បង្កើតអោយមានឧបសគ្គដល់ការចុះបញ្ជីអង្គការមិនមែនរដ្ឋាភិបាលបរទេស តំរូវអោយអង្គការមិនមែនរដ្ឋាភិបាលធ្វើការសហការជាមួយរដ្ឋាភិបាល ហើយដាក់អោយនៅក្រៅច្បាប់នូវអង្គការមិនមែនរដ្ឋាភិបាលដែលមិនបានចុះបញ្ជី ដោយមិនបានគិតគូរអោយបានហ្មត់ចត់ ។ រដ្ឋាភិបាលបរទេសបានសំដែងកង្វល់ថា ពង្រាងច្បាប់នោះនឹងបង្កើនការគ្រប់គ្រងច្រើនរបស់រដ្ឋាភិបាលទៅលើសង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាលបរទេស។

គ្មានការវិវឌ្ឍក្នុងករណីឆ្នាំ ២០០៩ ទាក់ទងនឹងបុគ្គលិក ៣ នាក់នៃអង្គការមិនមែនរដ្ឋាភិបាលខ្មែរ ដែលមានឈ្មោះថា សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងសមាជិកក្រុមប្រឹក្សាឃុំមកពីគណបក្សសម រង្ស៊ីដែលរងការចោទប្រកាន់ពីបទញុះញង់។ អ្នកដែលត្រូវបានចាប់ខ្លួនទាំងនោះនៅមានសេរីភាពនៅឡើយដោយសារបង់ប្រាក់បាននៅក្រៅឃុំ ហើយនៅរង់ចាំសវនាការ ។ មកដល់ពេលដំណាច់ឆ្នាំនៅមិនទាន់មានការកំណត់ថ្ងៃខែនៅឡើយ។

រដ្ឋាភិបាលបានសហការជាមួយអង្គការរដ្ឋាភិបាលអន្តរជាតិហើយបានអនុញ្ញាតអោយតំណាងអង្គការសហប្រជាជាតិមកធ្វើទស្សនកិច្ច ។ នៅខែមករា និងខែមិថុនា អ្នករាយការណ៍ពិសេសនៃអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា លោក Surya Subedi បានមកធ្វើទស្សនកិច្ចនៅកម្ពុជា ។ នាយករដ្ឋមន្ត្រីនិងមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់ដទៃទៀតបានជួបលោក Subedi ។

រដ្ឋាភិបាលមានស្ថាប័នសិទ្ធិមនុស្សចំនួនបី ៖ គណៈកម្មការពីរដាច់ដោយឡែកពីគ្នា ដោយមួយទទួលបន្ទុកការពារសិទ្ធិមនុស្ស និងមួយទៀតទទួលពាក្យបណ្តឹង។ មួយស្ថិតនៅក្រោមព្រឹទ្ធសភា និងមួយទៀតស្ថិតនៅក្រោមសភាជាតិ ហើយនិងគណៈកម្មការសិទ្ធិមនុស្សកម្ពុជាដែលរាយការណ៍ ទៅកាន់ទីស្តីការគណៈរដ្ឋមន្ត្រី ។ គណៈកម្មការទាំងនេះ មិនជួបប្រជុំទៀងទាត់ ឬមានដំណើរការប្រតិបត្តិការដោយតម្លាភាពឡើយ ។ គណៈកម្មការសិទ្ធិមនុស្សកម្ពុជាជាអ្នកដាក់ជូនរបាយការណ៍របស់រដ្ឋាភិបាល សំរាប់ការចូលរួមនៅក្នុងដំណើរការពិនិត្យមើលស្ថានភាពសិទ្ធិមនុស្សជាអន្តរជាតិ ដូចជា ការពិនិត្យជាសកលទៀងទាត់ ហើយចេញការឆ្លើយតបទៅនឹងរបាយការណ៍របស់ស្ថាប័នអន្តរជាតិ ប៉ុន្តែមិនធ្វើការស៊ើបអង្កេតអំពីបញ្ហាសិទ្ធិមនុស្សដោយឯករាជ្យឡើយ ។ អង្គការមិនមែនរដ្ឋាភិបាលផ្នែកសិទ្ធិមនុស្សបានចាត់ទុកគណៈកម្មការរបស់រដ្ឋាភិបាល នេះថាមានប្រសិទ្ធភាពមានកំរិត ។

រដ្ឋាភិបាលបានទទួលធ្វើជាម្ចាស់ផ្ទះអោយតុលាការកូនកាត់ដែលធ្វើការកាត់ទោសមេដឹកនាំខ្មែរក្រហម (ECCC) ដែលត្រូវបានគ្រប់គ្រងរួមគ្នាជាមួយអង្គការសហប្រជាជាតិ ដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហម និងអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះការរំលោភបំពាននៅក្នុងសម័យខ្មែរក្រហម ។ គ្មានការចោទប្រកាន់អំពីអំពើពុករលួយនៅក្នុងរដ្ឋបាលតុលាការនេះឡើយនៅអំឡុងឆ្នាំនៃរបាយការណ៍នេះ ។ អ្នកសង្កេតការណ៍ខ្លះ មានជំនឿថាមតិជាសាធារណៈសំដែងឡើងដោយមេដឹកនាំរដ្ឋាភិបាល លើបញ្ហាទាក់ទងនឹងអាណត្តិគតិយុត្តិរបស់ ECCC គឺជាទម្រង់នៃការជ្រៀតជ្រែកផ្នែកនយោបាយមួយ។ ទោះជាយ៉ាងណាក៏ដោយគ្មានភស្តុតាងបញ្ជាក់ថា ការងាររបស់តុលាការត្រូវបានរារាំងដោយរបៀបណាមួយនោះឡើយ ហើយអាជ្ញាធរ ជាតិបានបំពេញភារកិច្ចរបស់ខ្លួនដោយជោគជ័យក្នុងការចាប់ខ្លួន និងបញ្ជូនខ្លួនជនដែលត្រូវចោទប្រកាន់ដោយ ECCC ទាំងអស់ទៅអោយសាលាក្តី ។

នៅថ្ងៃទី ២៦ ខែកក្កដា ECCC បានកំណត់ទោសលើកាំង ហ្គិចអៀវ ហៅឌុច ដែលជាអតីតមេគុកទួលស្លែង ឬគុក ស ២១ ។ ឌុចត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ និងបទរំលោភយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩ (ឧក្រិដ្ឋកម្មសង្គ្រាម) ការសំលាប់ដោយមានការគិតទុកជាមុន និងការធ្វើទារុណកម្ម។ តុលាការបានកាត់ទោសអោយគាត់ជាប់ពន្ធនាគារចំនួន ៣៥ ឆ្នាំ តែបានដក ៥ ឆ្នាំចេញដើម្បីទូទាត់នឹងរយៈពេលនៃការឃុំខ្លួនដោយខុសច្បាប់លើរូបគាត់នៅកន្លែងឃុំឃាំងយោធា។ ដោយបានបំពេញទោសបានរយៈពេល ១១ ឆ្នាំហើយ ដូច្នេះ ឌុចនៅសល់ពេលត្រូវនៅក្នុងពន្ធនាគារតែចំនួន ១៩ ឆ្នាំតែប៉ុណ្ណោះ។ ខាងមេធាវីរបស់គាត់បានប្រកាសថានឹងប្តឹងឧទ្ធរណ៍ទៅតុលាការកំពូលរបស់តុលាការ ECCC ដោយលើកហេតុផលថា ឌុចមិនស្ថិតក្នុងប្រភេទមនុស្ស ដែលតុលាការនោះមានយុត្តាធិការទៅលើនោះទេ។ ខាងព្រះរាជអាជ្ញាក៏បានប្តឹងឧទ្ធរណ៍ផងដែរ ដោយលើកហេតុផលថា ទោសដែលបានដាក់នោះ គឺមិនគ្រប់គ្រាន់ទេ។ នៅថ្ងៃទី ១៦ ខែកញ្ញា តុលាការបានចេញសាលក្រមចោទប្រកាន់ទៅលើមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់ ៤ នាក់ទៀត ដែលកំពុងស្ថិតក្រោមការឃុំឃាំង ពីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ បទឧក្រិដ្ឋសង្គ្រាម និងអំពើប្រល័យពូជសាសន៍។ តុលាការថែមទាំងបានបន្តការស៊ើបអង្កេតទៅលើមនុស្ស ៥ នាក់ទៀត ដែលគេមិនទាន់បញ្ចេញឈ្មោះ។

## ផ្នែកទី៦ ៖ ការរើសអើង ការរំលោភបំពានក្នុងសង្គម និងការជួញដូរមនុស្ស

រដ្ឋធម្មនុញ្ញហាមប្រាមចំពោះការរើសអើងផ្អែកពូជសាសន៍ ភេទ ពិការភាព ភាសា និងឋានៈសង្គម។ ទោះជាយ៉ាងណាក៏ដោយ ជាទូទៅរដ្ឋាភិបាលមិនបានការពារសិទ្ធិទាំងនេះឡើយ ។

## ស្ត្រី

ច្បាប់ហាមប្រាមការរំលោភសេពសន្ថវៈ និងការបំពានលើរូបរាងកាយ ប៉ុន្តែទោះជាយ៉ាណាក៏ដោយ អង្គការ មិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិ បានរាយការណ៍ថា អំពើហឹង្សាលើស្ត្រី រួមមានដូចជាអំពើហឹង្សាក្នុង គ្រួសារ និងការរំលោភសេពសន្ថវៈជាដើមនៅតែកើតមានយ៉ាងច្រើន ។ ការរំលោភសេពសន្ថវៈ គឺជាបទល្មើសព្រហ្មទណ្ឌ ហើយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារចាប់ពី៥ ទៅ ១០ឆ្នាំ យោងតាមច្បាប់ អន្តរកាលរបស់ UNTAC ។ តាមច្បាប់អន្តរកាលរបស់ UNTAC ករណីរំលោភសេពសន្ថវៈដោយប្តី ឬប្រពន្ធក៏អាចត្រូវកាត់ទោសជាករណី “រំលោភសេពសន្ថវៈ” “បង្ករបួសស្នាម” ឬ “បំពានដោយគ្មានសេចក្តីថ្លៃថ្នូរ” ផងដែរ ។ តាមច្បាប់ប្រឆាំង អំពើហឹង្សាក្នុងគ្រួសារឆ្នាំ២០០៥ ការរំលោភសេពសន្ថវៈដោយប្តី ឬប្រពន្ធ ក៏អាចស្ថិតនៅក្នុងនិយមន័យនៃច្បាប់ ប្រឆាំងនឹងអំពើហឹង្សាក្នុងគ្រួសារដែរ ដែលរួមមានដូចជា “ការបៀតបៀនផ្លូវភេទ ។ ការចោទប្រកាន់អំពី ករណីរំលោភសេពសន្ថវៈដោយប្តី ឬប្រពន្ធ តាមច្បាប់អន្តរកាលរបស់ UNTAC និងច្បាប់ប្រឆាំងនឹងអំពើហឹង្សាក្នុងគ្រួសារកម្រឃើញណាស់ ។ ច្បាប់ប្រឆាំងនឹងអំពើហឹង្សាក្នុងគ្រួសារចាត់ទុកអំពើហឹង្សាក្នុងគ្រួសារជាទោសឧក្រិដ្ឋ ប៉ុន្តែមិនបានចែងពីទោសបញ្ញត្តិច្បាស់លាស់ឡើយ ។ ទោះជាយ៉ាងណាក៏ដោយ ច្បាប់ អន្តរកាលរបស់ UNTAC ស្តីពីការវាយដំ និងការបង្ករបួសស្នាម អាចត្រូវ បានប្រើប្រាស់ ដើម្បីដាក់ទោសលើបទល្មើសហឹង្សាក្នុងគ្រួសារដោយមានទោសជាប់ពន្ធនាគារចាប់ពីពីរខែ ទៅប្រាំឆ្នាំ ។

យោងតាមអង្គការមិនមែនរដ្ឋាភិបាលមួយបានអោយដឹងថា មានករណីរំលោភសេពសន្ថវៈចំនួន ៥០១ ករណី និង ករណីអំពើហឹង្សាក្នុងគ្រួសារចំនួន ៥៤៦ ករណី ត្រូវបានរាយការណ៍ក្នុងឆ្នាំ ហើយតុលាការបានជំនុំជម្រះ ករណីចំនួន ១៨០ ។ មានអង្គការមិនមែនរដ្ឋាភិបាលមួយផ្សេងទៀតបានចងក្រងទុកជាឯកសារ នូវអំពើហឹង្សាក្នុងគ្រួសារចំនួន១៦២ ករណី ដែលប៉ះពាល់ដល់ជនរងគ្រោះចំនួន ១៦៤ នាក់ និងការរំលោភ សេពសន្ថវៈ ចំនួន ៧៤ ទៅលើជនរងគ្រោះចំនួន ៧៦ នៅខេត្តចំនួន ១៣ និងនៅក្រុងភ្នំពេញ គិតមកដល់ដំណាច់ខែវិច្ឆិកា ។ អំពើហឹង្សាក្នុងគ្រួសារចំនួន ៥ ករណី និងការសេពសន្ថវៈចំនួន ៣ ករណីបណ្តាលអោយជនរងគ្រោះ ៨ នាក់ស្លាប់។ នៅអំឡុងឆ្នាំនោះដែរ នាយកដ្ឋានប្រឆាំង នឹងការជួញដូរមនុស្សរបស់ក្រសួងមហាផ្ទៃបានស៊ើបអង្កេតអំពើហឹង្សាលើស្ត្រី និងកុមារចំនួន៤២៨ ករណី នាំដោយមានការចាប់ខ្លួនជនល្មើសចំនួន ៣៧៧ នាក់ និងសង្គ្រោះជនរងគ្រោះបានចំនួន ៤២៣ នាក់ ។ ក្នុងចំណោមករណីទាំង ៤២៨ មាន ៣២៨ ជាករណីរំលោភសេពសន្ថវៈ និងប៉ុនប៉ងរំលោភសេពសន្ថវៈ ។ ក្រសួងមហាផ្ទៃ បានរាយការណ៍ថាមានករណីរំលោភ សេពសន្ថវៈចំនួនបីករណីបណ្តាលអោយជនរងគ្រោះបួននាក់ស្លាប់ ។ ចំនួនករណីទាំង

នេះ អាចនឹងរាយការណ៍មិនអស់អំពីវិសាលភាពនៃបញ្ហានេះឡើយ ដោយសារការអនុវត្តច្បាប់គ្មានប្រសិទ្ធភាព គ្មានរបាយការណ៍ស្ថិតិស្តីពីបទឧក្រិដ្ឋគ្រប់គ្រាន់ និងការដែលស្ត្រីភ័យខ្លាចមិនហ៊ានដាក់ពាក្យបណ្តឹងប្រឆាំងនឹងជនល្មើស ។ អង្គការ មិនមែនរដ្ឋាភិបាលបានរាយការណ៍ថា ការអនុវត្តច្បាប់ប្រឆាំងនឹង អំពើហឹង្សាក្នុងគ្រួសារនៅទន់ខ្សោយ អាជ្ញាធរនៅតែបន្តចៀសវាងមិនចូលពាក់ព័ន្ធនឹងវិវាទគ្រួសារ ហើយជាញឹកញាប់ ជនរងគ្រោះស្ទាក់ស្ទើរក្នុងការដាក់ពាក្យបណ្តឹងផ្លូវការ ។

គ្មានការវិវឌ្ឍស្តីពីករណី ខែវិច្ឆិកា ឆ្នាំ ២០០៩ ទាក់ទងនឹងស្ត្រីអាយុ ១៩ឆ្នាំម្នាក់ ដែលតាមសេចក្តីរាយការណ៍មកថា ត្រូវបានរំលោភសេពសន្ថវៈដោយមន្ត្រីនគរបាលម្នាក់ ចំណែកឯមន្ត្រីនគរបាលម្នាក់ទៀតជាអ្នកចាប់នាង ។ ការកាត់ទោសត្រូវជាប់គាំង ហើយជនប្រព្រឹត្តនៅមានសេរីភាពនៅលើយ នៅដំណាច់ឆ្នាំ។

រដ្ឋាភិបាលបានគាំទ្រដល់អង្គការមិនមែនរដ្ឋាភិបាល ដែលផ្តល់ការបណ្តុះបណ្តាលសម្រាប់ស្ត្រីក្រីក្រដែលងាយរងគ្រោះពីការរំលោភបំពានពីស្វាមី ពេស្យាកម្ម និងការជួញដូរមនុស្ស ។ មជ្ឈមណ្ឌលព័ត៌មានក្នុងស្រុកមួយ ដែលជាអង្គការមិនមែនរដ្ឋាភិបាល និងក្រសួងកិច្ចការនារីបានផលិតកម្មវិធីទាក់ទងនឹងបញ្ហាស្ត្រី ។ អង្គការមិនមែនរដ្ឋាភិបាលមួយចំនួន ក៏បានផ្តល់ទីជម្រកសម្រាប់ស្ត្រីមានវិបត្តិផងដែរ ។

រដ្ឋាភិបាលបានប្រើប្រាស់ច្បាប់ ឆ្នាំ ២០០៨ ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទ ដើម្បីដាក់ទោសអ្នកទេចរផ្លូវភេទ។

ច្បាប់ការងារមានបញ្ញត្តិប្រឆាំងនឹងការបៀតបៀនផ្លូវភេទនៅកន្លែងធ្វើការ តែមិនបញ្ជាក់ច្បាប់ពីទោសឡើយ។ គ្មានព័ត៌មានស្តីពីអត្រានៃករណីកើតមានឡើងឡើយ។

គូស្រករ និងបុគ្គលម្នាក់ៗ អាចសម្រេចអំពីចំនួនកូន ការពន្យាកំណើត និងការកំណត់ពេលវេលាសម្រាប់យកកូន ហើយគេអាចទទួលបានព័ត៌មាន និងមធ្យោបាយសំរាប់ធ្វើដូច្នេះ ដោយគ្មានការរើសអើងឡើយ ។ ស្ត្រីមានលទ្ធភាពប្រើប្រាស់មធ្យោបាយពន្យាកំណើត ព្រមទាំងឆ្មបដែលមានជំនាញនៅពេលសម្រាលកូន និងការថែទាំក្រោយពេលសម្រាលកូន ប៉ុន្តែលទ្ធភាពជារឿយៗមានកម្រិត ដោយសារប្រាក់ចំណូល និងឧបសគ្គផ្នែកភូមិសាស្ត្រ ។ យោងតាមការប៉ាន់ប្រមាណនៅឆ្នាំ ២០០៨ របស់អង្គការសហប្រជាជាតិ អត្រាស្លាប់របស់មាតានៅឆ្នាំ ២០០៨ មាន ២៩០ នាក់ក្នុងចំណោមស្ត្រីសំរាលកូនចំនួន ១០០

០០០ នាក់។ ស្ត្រី មានលទ្ធភាពស្មើគ្នាក្នុងការទទួលសេវាវិនិច្ឆ័យរោគ និងព្យាបាលជំងឺឆ្លងដោយសារការរួមភេទ ដូចជារោគអេដស៍ជាដើម ។

រដ្ឋធម្មនុញ្ញបានចែងអំពីសិទ្ធិស្មើគ្នាសម្រាប់ស្ត្រី ប្រាក់ឈ្នួលស្មើគ្នាសំរាប់ការងារដូចគ្នា និងឋានៈស្មើគ្នានៅក្នុងចំណងអាពាហ៍ពិពាហ៍ ។ ទោះជាយ៉ាងណាក៏ដោយ មានរបាយការណ៍របស់អង្គការសហប្រជាជាតិមួយបានរិះគន់ការបង្រៀន “ច្បាប់ស្រី” ជាបន្តនៅក្នុងកម្មវិធីសិក្សាថ្នាក់បឋមសិក្សា។ របាយការណ៍នោះបានអះអាងថា ការបង្រៀនបែបនោះធ្វើអោយការកំណត់តួនាទីរបស់ស្ត្រីអោយទាបនៅក្នុងសង្គម ។ ភាគច្រើនស្ត្រីមានសិទ្ធិស្មើគ្នាលើទ្រព្យសម្បត្តិ ឋានៈស្របច្បាប់ស្មើគ្នាក្នុងការដាក់បណ្តឹងលែងលះ និងមានលទ្ធភាពស្មើគ្នាក្នុងការទទួលបានការអប់រំ និងការងារមួយចំនួន។ ទោះជាយ៉ាងណាក៏ដោយ ប្រពៃណីវប្បធម៌នៅតែបន្តកម្រិតសមត្ថភាពរបស់ស្ត្រីក្នុងការឈោងចាប់មុខតំណែងខ្ពស់ៗនៅក្នុងអាជីវកម្ម និងវិស័យដទៃទៀត ។ ជារឿយៗ ស្ត្រីផ្តុំគ្នានៅក្នុងការងារដែលទទួលបានប្រាក់ចំណូលទាប ហើយភាគច្រើនត្រូវបានផាត់ចេញពីមុខតំណែងគ្រប់គ្រង ។ បុរសភាគច្រើនបំពេញការងារនៅក្នុងកងយោធានគរបាល និងមន្ត្រីរាជការស៊ីវិល ។

ក្រសួងកិច្ចការនារី ដែលមានអាណត្តិការពារសិទ្ធិស្ត្រី និងលើកកម្ពស់សមភាពយេនឌ័រនៅក្នុងសង្គមនោះ បានបន្តកម្មវិធីនារីរតនៈរបស់ខ្លួនតទៅមុខទៀត ។ កម្មវិធីនេះ មានបំណងកែលម្អមុខមាត់ស្ត្រីតាមរយៈការបញ្ជ្រាបយេនឌ័រ បង្កើនការចូលរួមរបស់ស្ត្រីនៅក្នុងជីវភាពសេដ្ឋកិច្ច និងនយោបាយ និងការការពារសិទ្ធិនារី ។ ស្ថាប័នរដ្ឋាភិបាលចំនួន ១៦ បន្តផែនការអនុវត្តសកម្មភាពបញ្ជ្រាបយេនឌ័រ ដែលមានការគាំទ្រពីកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ និងដោយការសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងកិច្ចការនារី។ រដ្ឋាភិបាលនិយាយថា ស្ត្រីមានចំណែក ៥០% ក្នុងការងារដែលទទួលប្រាក់ឈ្នួល ក្នុងផ្នែកកសិកម្ម និងឧស្សាហកម្ម និង៣៧ភាគរយនៅក្នុងផ្នែកសេវាកម្ម ដែលជាសូចនាករត្រូវបានកំណត់ក្នុងផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ ពីឆ្នាំ២០០៦ ដល់ឆ្នាំ ២០១០ ។ ក្នុងផែនការអភិវឌ្ឍន៍ពីឆ្នាំ ២០០៩ ដល់ឆ្នាំ ២០១៣ រដ្ឋាភិបាល បានកំណត់គោលដៅថ្មីដោយអោយមានចំណែករបស់ស្ត្រីចំនួន ៥០% ក្នុងការងារទទួលប្រាក់ឈ្នួល ក្នុងផ្នែកផ្តល់សេវាកម្ម ហើយប្តេជ្ញាចិត្តរក្សាសមាមាត្រ ៥០% នាពេលបច្ចុប្បន្ន ក្នុងវិស័យកសិកម្ម និងឧស្សាហកម្ម អោយនៅដដែល។

**កុមារ**

តាមច្បាប់ សញ្ជាតិអាចទទួលបានពីកំណើតពីម្ដាយ និងឪពុកដែលមិនមែនជាជនជាតិខ្មែរ ប្រសិនបើ ឪពុកម្ដាយ ទាំងពីរបានកើត និងកំពុងរស់នៅកម្ពុជា ឬប្រសិនបើឪពុក ឬម្ដាយបានទទួលសញ្ជាតិខ្មែរ ។ ក្រសួងមហាផ្ទៃបានរៀបចំប្រព័ន្ធចុះសំបុត្រកំណើតបែបទំនើបមួយ ប៉ុន្តែការចុះសំបុត្រកំណើតមិនបានធ្វើឡើងភ្លាមៗបានទាំងអស់ទេ មូលហេតុសំខាន់គឺដោយសារតែភាពឃើតយ៉ាវរបស់ឪពុកម្ដាយ ។ ប្រព័ន្ធនេះមិនមានរហូតដល់មូលដ្ឋាន ជាពិសេសទៅកាន់សហគមន៍ជនជាតិភាគតិចឡើយ ។ ជាងនេះទៅទៀត កុមារដែលកើតពីពាក់កណ្ដាលទសវត្ស ឆ្នាំ១៩៧០ ដល់ពាក់កណ្ដាលទសវត្សឆ្នាំ១៩៨០ ច្រើនតែមិនបានចុះសំបុត្រកំណើតទេ ដោយសាររបបខ្មែរ ក្រហម/ការកាន់កាប់របស់ប្រទេសវៀតណាម/សង្គ្រាមស៊ីវិល ។ អ្នកដែលគ្មានសំបុត្រកំណើតជាច្រើនទាំងនេះ ដែលក្រោយមកមានក្រុមគ្រួសាររបស់ខ្លួនផ្ទាល់ មិនបានមើលឃើញអំពីភាពចាំបាច់នៃការធ្វើសំបុត្រកំណើតឡើយ ។ ជាទូទៅ យុវជនមិនបានចុះសំបុត្រកំណើតឡើយលុះត្រាតែមានការចាំបាច់ ។ ការខកខានមិនបានចុះសំបុត្រ កំណើតទាំងអស់គ្នានាំអោយមានការរើសអើង ដូចជាការបដិសេធមិនអោយទទួលសេវាសាធារណៈ ជាដើម ។ ការសិក្សាមួយធ្វើឡើងដោយអង្គការ UNHCR អំពីភាពគ្មានប្រទេសនៅកម្ពុជា បានបញ្ជាក់ថា ដំណើការចុះសំបុត្រកំណើត ជាញឹកញាប់ មិនបានរាប់បញ្ចូលកុមារជនជាតិភាគតិច និងជនគ្មានប្រទេសឡើយ ។ អង្គការមិនមែនរដ្ឋាភិបាលនានា ដែលផ្ដល់សេវាទៅដល់សហគមន៍ដែលត្រូវដកហូតសិទ្ធិបោះឆ្នោត ឬសិទ្ធិតំណាង បាន និយាយថា កុមារដែលគ្មានសំបុត្រកំណើតនិងសៀវភៅគ្រួសារជាញឹកញាប់ ពុំត្រូវបានផ្ដល់លទ្ធភាពទទួលបាន ការអប់រំ និងការថែទាំសុខភាពឡើយ ។ អង្គការទាំងនោះបញ្ជាក់ថា នៅក្នុងនាពេលអនាគត បុគ្គលទាំងនេះ នឹងមិនមានលទ្ធភាពទទួលបានការងារមានកម្មសិទ្ធិលើទ្រព្យសម្បត្តិ/ដីធ្លី បោះឆ្នោត ឬប្រើប្រាស់ប្រព័ន្ធច្បាប់ឡើយ ។

ប្រព័ន្ធអប់រំមានលក្ខណៈមិនគ្រប់គ្រាន់ទេសំរាប់កុមារ ។ ការអប់រំត្រូវបានផ្ដល់ដោយឥតបង់ថ្លៃ ប៉ុន្តែក៏មិនមែនជាកាតព្វកិច្ចឡើយ រហូតដល់ថ្នាក់ទី៩ ។ កុមារជាច្រើនបានបោះបង់ការសិក្សា ដើម្បីជួយក្រុមគ្រួសាររបស់ខ្លួនក្នុងការងារកសិកម្មដើម្បីចិញ្ចឹមជីវិត ធ្វើការនៅក្នុងសកម្មភាពដទៃទៀត ចាប់ផ្ដើមចូលរៀនហួសអាយុ ឬមិនបានចូលរៀនទាល់តែសោះ ។ រដ្ឋាភិបាលមិនបានបដិសេធកុមារីពីការមានលទ្ធភាពស្មើគ្នាក្នុងការទទួលការអប់រំឡើយ ប៉ុន្តែក្រុមគ្រួសារដែលមានកម្រិតធនធានទាប ជាញឹកញាប់ ផ្ដល់អាទិភាពទៅដល់កុមារា ។ យោងតាមរបាយការណ៍របស់អង្គការអន្តរជាតិ ការចុះឈ្មោះចូលរៀនបានធ្លាក់ចុះយ៉ាងគំហុកចំពោះកុមារី ក្រោយពីបញ្ចប់បឋមសិក្សា ។ សាលារៀននៅតំបន់ជាច្រើន ស្ថិតនៅដាច់ស្រយាលហើយការធ្វើដំណើរគឺជាបញ្ហា ។ ការនេះប៉ះពាល់ជាពិសេសលើកុមារី ដោយសារការបារម្ភពីសុវត្ថិភាពក្នុងការធ្វើដំណើរទៅមកពីផ្ទះទៅសាលារៀន ។

គេមានជំនឿថាការរំលោភបំពានកុមារកើតមានឡើងច្រើន ទោះបីពុំមានស្ថិតិបង្ហាញក៏ដោយ ។ ការរំលោភ សេពសន្ថវៈលើកុមារនៅតែជាបញ្ហាដ៏ធ្ងន់ធ្ងរមួយ ។ អង្គការមិនមែនរដ្ឋាភិបាលបានរាយការណ៍អំពីករណីរំលោភ សេពសន្ថវៈ និងប៉ុនប៉ងរំលោភសេពសន្ថវៈក្នុងឆ្នាំចំនួន ៣៥៧ ករណី ដែលត្រូវបានប្រព្រឹត្តទៅលើកុមារអាយុក្រោមអាយុ ១៨ ឆ្នាំ ។ មាន ៣៣ ករណីទាក់ទងនឹងកុមារដែលមានអាយុក្រោម ៥ឆ្នាំ និង ៧៦ ករណីទាក់ទងនឹងកុមារដែលមានអាយុពី ៥ឆ្នាំដល់១០ឆ្នាំ និង ២៤៨ ករណីទាក់ទងនឹងកុមារអាយុពី១០ ដល់១៨ ឆ្នាំ ។ ការរួមភេទជាមួយកុមារអាយុក្រោម ១៥ឆ្នាំគឺជាអំពើខុសច្បាប់ ទោះជាយ៉ាងណាក៏ដោយ ពេស្យាចារ និងការជួញដូរកុមារបានកើតមានឡើង ។ក្រសួងមហាផ្ទៃបានរាយការណ៍អំពីការចាប់ខ្លួនជនរំលោភផ្លូវភេទកុមារជាជនជាតិបរទេសចំនួន១៩ នាក់ ។ កុមារមួយចំនួនបានចូលប្រឡូកនៅក្នុងពេស្យាចារ ដើម្បីចិញ្ចឹមជីវិតដោយគ្មានការពាក់ព័ន្ធពីភាគីទីបីឡើយ ។

នៅខែមេសា តុលាការក្រុងភ្នំពេញបានដាក់ទោសមន្ត្រីជាន់ខ្ពស់ក្រសួងយុត្តិធម៌ម្នាក់អោយជាប់ពន្ធនាគារ ៨ ឆ្នាំ ពីបទទទួលសំណូកដ៏ច្រើន ដើម្បីប្តូរនឹងការរៀបចំអោយមានការដោះលែងជនប្រព្រឹត្តអាណាចារ លើកុមារជនជាតិរុស្ស៊ី ឈ្មោះ Alexander Trofimov ដោយយកលេសថា ត្រូវចាប់បញ្ជូនត្រឡប់ទៅប្រទេសរុស្ស៊ីវិញ។ តាមព័ត៌មានមកថា មន្ត្រីនោះបានក្លែងឯកសារបញ្ជូនត្រឡប់វិញ ហើយបានក្លែងហត្ថលេខារបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងនាយករដ្ឋមន្ត្រី។

រដ្ឋាភិបាលបានផ្តល់សេវាមានកម្រិត និងមិនគ្រប់គ្រាន់ដល់កុមាររស់នៅតាមចិញ្ចើមថ្នល់ នៅឯមជ្ឈមណ្ឌលស្តារនីតិសម្បទាមួយ ។ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយបានប៉ាន់ប្រមាណថា មានកុមារតាមចិញ្ចើមថ្នល់ប្រមាណជា ១.៥០០នាក់ នៅទីក្រុងភ្នំពេញ ដែលគ្មានទំនាក់ទំនងជាមួយគ្រួសារ និងប្រមាណជា ១០.០០០នាក់ ទៅ ២០.០០០ នាក់ធ្វើការនៅតាមចិញ្ចើមថ្នល់ ប៉ុន្តែត្រឡប់ទៅគ្រួសាររបស់ខ្លួនវិញនៅពេលយប់ ។ មានកុមារប្រមាណពី ៥០០ ទៅ ២.០០០ នាក់ដែលរស់នៅជាមួយគ្រួសាររបស់ខ្លួន នៅតាមដងវិថី នានានៅទីក្រុងភ្នំពេញ ។

ក្រសួងមហាផ្ទៃបានរាយការណ៍ថា យ៉ាងហោចមានកុមារចំនួន៥២ នាក់ អាយុក្រោម៦ឆ្នាំ កំពុងរស់នៅជាមួយ ម្តាយនៅក្នុងពន្ធនាគារ ។ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយបានរាយការណ៍ថាមានកុមារប្រភេទនេះចំនួន ៤៧ នៅតាមពន្ធនាគារចំនួន ១៩ ហើយបានអះអាងថា កុមារទាំងនេះទទួលរងការប្រព្រឹត្តមិនគប្បីពីសំណាក់ឆ្មាំពន្ធនាគារ និងប្រឈមមុខនឹងគ្រោះថ្នាក់លើរាងកាយពីឧក្រិដ្ឋជនពេញ វ័យរួមបន្ទប់របស់ខ្លួន ។ ជាទូទៅកុមារទាំងនេះខ្វះអាហារូបត្ថម្ភ និងការអប់រំបានត្រឹមត្រូវ ។

ប្រទេសកម្ពុជាមិនមែនជាភាគីមួយនៃអនុសញ្ញាក្រុងឡាអេឆ្នាំ ១៩៨០ ស្តីពីផ្នែកស៊ីវិលនៃការពង្រាត់កុមារជាអន្តរជាតិទេ។ ចំពោះព័ត៌មានស្តីពីការពង្រាត់កុមារជាអន្តរជាតិ សូមមើលរបាយការណ៍ប្រចាំឆ្នាំរបស់ក្រសួងការបរទេសអាមេរិក ស្តីពីការគោរពតាម ដែលមានអាស័យដ្ឋាន
http://travel.state.gov/abduction/resources/congressreport/congressreport_4308.html

## ការប្រឆាំងនឹងក្រុមជីហ្វ

គ្មានសហគមន៍ជីហ្វនៅប្រទេសកម្ពុជាទេ ហើយគ្មានរបាយការណ៍ទាក់ទងនឹងអំពើប្រឆាំងនឹងជនជាតិជីហ្វឡើយ។

## ជនពិការ

ច្បាប់ឆ្នាំ ២០០៩ ស្តីពីកិច្ចការពារ និងលើកស្ទួយសិទ្ធិជនពិការហាមប្រាមការរើសអើង ការព្រងើយកន្តើយ ការកេងប្រវ័ញ្ច ឬការបោះបង់ជនពិការ ។ តាមច្បាប់នេះ ជនពិការរាប់ទាំងជនមានជំងឺផ្នែកសតិបញ្ញា ហើយតម្រូវអោយអគារ និងសេវារដ្ឋាភិបាល រួមទាំងការសិក្សាអប់រំផង អាចប្រើប្រាស់និងទទួលបានដោយជនពិការ ។ ក្រសួងសង្គមកិច្ចជាអ្នកទទួលខុសត្រូវរួមក្នុងការការពារសិទ្ធិរបស់ជនពិការ ថ្វីបើច្បាប់កំណត់ដាក់ភារកិច្ចដោយឡែកជាក់លាក់សំរាប់ក្រសួងដទៃទៀត ដែលរួមមានក្រសួងសុខាភិបាល អប់រំ សាធារណការ និងដឹកជញ្ជូននិងក្រសួងការពារជាតិ។ រដ្ឋាភិបាលសុំអោយគ្រប់ស្ថានីយ៍ទូរទស្សន៍ទាំងអស់មានកម្មវិធីបកប្រែជាភាសាសញ្ញាអមកម្មវិធីផ្សាយរបស់គេ។ មកដល់ដំណាច់ឆ្នាំ មានស្ថានីយ៍ទូរទស្សន៍ធំៗពីរមានការបកប្រែភាសាជាភាសាសញ្ញា ហើយក្រសួងព័ត៌មានកំពុងតែធ្វើការជាមួយនឹងស្ថានីយ៍ដទៃទៀតដើម្បីបណ្តុះសមត្ថភាពនេះ។ រដ្ឋាភិបាលបានបន្តការខិតខំដើម្បីអនុវត្តច្បាប់នេះ ថ្វីបើរយៈពេលពេញលេញដែលទុកសំរាប់អោយគេអនុវត្តតាមក្នុងករណីខ្លះ មានរហូតដល់ ឆ្នាំ ២០១៥ ក្តី។ នៅដំណាច់ឆ្នាំ ក្រុមប្រឹក្សារដ្ឋមន្ត្រីបាន អនុម័តលើអនុក្រឹត្យ ៣ ក្នុងចំណោមអនុក្រឹត្យចំនួន ៤ ដែលគាំទ្រច្បាប់នេះ ហើយកំពុងតែពិនិត្យមើលអនុក្រឹត្យទី៤។

កម្មវិធីរបស់អង្គការមិនមែនរដ្ឋាភិបាលផ្សេងៗបាននាំមកនូវការកែលម្អជាច្រើននៅក្នុងការប្រព្រឹត្តនិងការស្តារនីតិសម្បទាលើជនពិការ ប៉ុន្តែជនពិការជួបប្រទះការរើសអើងជាច្រើនពីសង្គម ជាពិសេសក្នុងការទទួលការងារជំនាញ ។

ពុំមានការកម្រិតតាមច្បាប់ណាមួយចំពោះសិទ្ធិជនពិការក្នុងការបោះឆ្នោត ឬចូលរួមក្នុងកិច្ចការនានារបស់ពលរដ្ឋឡើយ ប៉ុន្តែរដ្ឋាភិបាលមិនបានចូលរួមខិតខំប្រឹងប្រែង ដើម្បីជួយដល់ជនពិការអោយចូលរួមកាន់តែច្រើនក្នុងនាមជាពលរដ្ឋឡើយ ។ ក្រសួងសង្គមកិច្ចជាអ្នកទទួលខុសត្រូវក្នុងការធ្វើគោលនយោបាយដើម្បីការពារសិទ្ធិរបស់ជនពិការ និងដើម្បីស្តារនិតិសម្បទារ ហើយនិងបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ សំរាប់ជនពិការ។

## **សញ្ជាតិ/ពូជសាសន៍/ជាតិពន្ធុភាគតិច**

សិទ្ធិរបស់ជនជាតិភាគតិច តាមច្បាប់សញ្ជាតិ មិនមានចែងច្បាស់លាស់នោះទេ ។ការការពារតាមរដ្ឋធម្មនុញ្ញមានផ្តល់តែចំពោះ "ពលរដ្ឋខ្មែរ" តែប៉ុណ្ណោះ ។ ពលរដ្ឋជាជនជាតិដើមកំណើតចិន និងវៀតណាមមានចំនួនច្រើនជាងគេ នៅក្នុងជាតិពន្ធុភាគតិច ។ ប្រជាពលរដ្ឋដើមកំណើតចិនត្រូវបានទទួលយកនៅក្នុងសង្គម ប៉ុន្តែការស្អប់ខ្ពើមនៅតែមានជាបន្តចំពោះជនជាតិដើមកំណើតវៀតណាម ដែលត្រូវបានគេមើលឃើញថា ជាការគម្រាមកំហែងចំពោះប្រទេសជាតិ និងវប្បធម៌ ។ ក្រុមមួយចំនួន រួមទាំងក្រុមនយោបាយផងដែរ នៅតែបន្តធ្វើសេចក្តីថ្លែងការណ៍ខ្លាំងៗ ប្រឆាំងនឹងជនជាតិវៀតណាម ។ ពួកអ្នកទាំងនោះបានតវ៉ាអំពីការគ្រប់គ្រងនយោបាយទៅលើគណបក្សប្រជាជនកម្ពុជា ដោយរដ្ឋាភិបាលវៀតណាម ការទន្ទ្រានព្រំដែន និងបញ្ហាដទៃទៀត ដែលគេចាត់ទុកថា អាណិកវៀតណាម យ៉ាងហោចក៏ទទួលខុសត្រូវមួយចំណែកផងដែរ ។

## **ជនជាតិដើម**

ជារឿយៗ រដ្ឋាភិបាលព្រងើយកន្តើយចំពោះកិច្ចខិតខំប្រឹងប្រែងដោយសហគមន៍ជនជាតិដើម ដើម្បីការពារដីធ្លីពីដូនតា និងធនធានធម្មជាតិរបស់ខ្លួន ។ ទោះបីជាច្បាប់ភូមិបាលឆ្នាំ២០០១ តម្រូវអោយមានការចុះបញ្ជីដីធ្លីរួម របស់ជនជាតិដើមក៏ដោយ ក៏មានការអនុវត្តតិចតួចតែប៉ុណ្ណោះក្នុងការចុះកម្មសិទ្ធិដីធ្លីរួម ។ អង្គការមិនមែនរដ្ឋាភិបាលជាច្រើនបានអំពាវនាវអោយផ្អាកការលក់ដី និងការធ្វើសម្បទានដី ដែលប៉ះពាល់សហគមន៍ជនជាតិដើម ។ អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ និងក្នុងស្រុក នានាមានភាពសកម្មក្នុងការអប់រំសហគមន៍ជនជាតិដើមអំពីដំណើរការចុះបញ្ជីដីធ្លី និងផ្តល់តំណាងផ្នែកច្បាប់នៅក្នុងវិវាទផ្សេងៗ ។ អង្គការមិនមែនរដ្ឋាភិបាលបានរាយការណ៍អំពីការបាត់បង់ដីកសិកម្ម និងរបរចិញ្ចឹមជីវិត ដោយសារកំណើននៃការផ្តល់ដីសម្បទានសេដ្ឋកិច្ចនៅលើដីរបស់ជនជាតិដើម ។ សមាជិកសកម្មផ្នែកសិទ្ធិជនជាតិដើមរបស់អង្គការ

មិនមែនរដ្ឋាភិបាលបានរាយការណ៍ថា ខ្លួនបានសំគាល់ឃើញមានវិវាទដីធ្លីដែលកំពុងមានចំនួន១៤ ទាក់ទងនឹងក្រុមជនជាតិភាគតិច ។

ក្រុមហ៊ុន ខូវ ជូលីគ្រុប បានបន្តកាប់ឆ្ការដីនៅស្រុកពេជ្រដា ខេត្តមណ្ឌលគិរី ដើម្បីធ្វើចំការកៅស៊ូ ទោះបីជាមានជំលោះជាមួយក្រុមជនជាតិភ្នងក្នុងមូលដ្ឋានក្តី។ មានប្រជាជនប្រមាណ ៨០០ គ្រួសារនៅឃុំប៊ូស្រាបានិយាយថា គេរងការប៉ះពាល់ដោយការធ្វើចំការកៅស៊ូនោះ។

ពុំមានការវិវឌ្ឍនៅក្នុងករណីវិវាទដីធ្លីនៅឆ្នាំ២០០៨ ដែលប៉ះពាល់សមាជិកសហគមន៍ជនជាតិដើម នៅភូមិកក់ ឃុំតាលាវ ស្រុកអណ្តូងមាស ខេត្តរតនៈគិរីឡើយ ។ អង្គការមិនមែនរដ្ឋាភិបាលនានា បានថ្លែងថា ភាគច្រើននៃដីសម្បទានសេដ្ឋកិច្ចទំហំ ១៧.០០០អេឃើ សំរាប់ធ្វើជាចំការកៅស៊ូ អាចចុះបញ្ជីជាដីសហគមន៍ ជនជាតិដើមស្របតាមច្បាប់ ។

គ្មានការវិវឌ្ឍក្នុងករណីឆ្នាំ២០០៨ ក្នុងខេត្តរតនៈគិរី ដែលក្នុងនោះ ក្រុមហ៊ុនវិនិយោគ BVB និង សមាជិកនៃសហគមន៍រងគ្រោះមួយ គឺឃុំយក្សឡោម បានព្រមព្រៀងគ្នាលើការប្រើប្រាស់ដី។ តែសហគមន៍ ដទៃទៀតក្នុងតំបន់នោះនៅតែសំដែងកង្វល់លើការអភិវឌ្ឍដីនោះដោយគ្មានការពិគ្រោះយោបល់ជាមួយម្ចាស់ដី ពីដើមមក។

## ការរំលោភបំពានពីសង្គម ការរើសអើង និងអំពើហិង្សាដោយផ្អែកលើប្រភេទនៃចំណង់ផ្លូវភេទ និងអត្តសញ្ញាណយេនឌ័រ

គ្មានច្បាប់ដែលដាក់ទោសចំពោះការរួមភេទដូចគ្នាទេ ហើយក៏គ្មានការរើសអើងជាផ្លូវការចំពោះ ក្រុមស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស បុគ្គលស្រឡាញ់ទាំងពីរភេទ និងបុគ្គលប្តូរភេទ (LGBT) ទេ ទោះបីជាការរើសអើង និងការពេបជ្រាយនៅតែមាន ជាពិសេសនៅតំបន់ជនបទ។ កាលពីខែឧសភា មានក្រុមហ៊ុន និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនបានរៀបចំពិធីបុណ្យមោទនភាពទីក្រុងភ្នំពេញប្រចាំឆ្នាំ លើកទី ៦ ។ វាជាជាពិធី ដែលមានរយៈពេលមួយសប្តាហ៍ ហើយបង្ហាញអំពីក្រុម LGBT ។

ពុំមានរបាយការណ៍អំពីការរើសអើងដោយរដ្ឋាភិបាលដោយសារប្រភេទនៃចំណង់ផ្លូវភេទនៅក្នុង ការងារ ដោយសារភាពគ្មានប្រទេស ឬលទ្ធភាពទទួលការអប់រំ ឬតំហែទាំសុខភាពឡើយ ។ ទោះជាយ៉ាង ណាក៏ដោយ អំពើរួមភេទដូចគ្នាជាទូទៅត្រូវបានគេខ្លាច និងសង្ស័យ ហើយមានក្រុមគាំទ្រមួយចំនួនតូច ប៉ុណ្ណោះ ដែលគេអាចនិយាយប្រាប់ពីករណីទាំងនេះ ។

មានរបាយការណ៍មួយចំនួនតូច ដែលបុគ្គលម្នាក់ៗបដិសេធមិនព្រមផ្តល់ការងារ ជួលអចលនទ្រព្យទៅអោយបុគ្គលដោយសារបញ្ហាប្រភេទចំណង់ផ្លូវភេទ ឬអត្តសញ្ញាណយេនឌ័រ ។

**អំពើហិង្សា ឬការរើសអើងដទៃទៀតនៅក្នុងសង្គម**

គ្មានការរើសអើងជាផ្លូវការចំពោះអ្នកដែលមានមេរោគអេដស៍/ជំងឺអេដស៍នោះឡើយ ។ ការរើសអើងក្នុងសង្គមចំពោះអ្នកមានមេរោគអេដស៍/ជំងឺអេដស៍ នៅតែជាបញ្ហានៅឡើយនៅតំបន់ជនបទ ប៉ុន្តែការរើសអើងត្រូវបានកាត់បន្ថយ ដោយសារមានកម្មវិធីលើកកម្ពស់ការយល់ដឹងអំពីមេរោគអេដស៍/ជំងឺអេដស៍ ។

**ផ្នែកទី៧ ៖ សិទ្ធិកម្មករ**

**ក. សិទ្ធិបង្កើតអង្គការ/សមាគម**

ច្បាប់អនុញ្ញាតអោយអ្នកធ្វើការផ្នែកឯកជនបង្កើត និងចូលរួមសហជីពតាមការជ្រើសរើសរបស់ខ្លួនគេផ្ទាល់ ដោយពុំចាំបាច់មានការអនុញ្ញាតជាមុនឡើយ ។ ទោះបីមានភាពប្រសើរឡើងខ្លះៗក៏ដោយ ក៏ការអនុវត្តច្បាប់នៅមានលក្ខណៈទន់ខ្សោយនៅឡើយ ។ សមាជិកភាពនៅក្នុងសហជីពកម្មករ ឬសមាគមនិយោជិកមិនមែនជាកាតព្វកិច្ចឡើយ ហើយគេអាចដកខ្លួនចេញពីសមាជិកភាពបាន ទោះបីមានសហជីពមួយចំនួនតូចប៉ុនប៉ងបំភិតបំភ័យកម្មករដែលចង់ដកខ្លួនក៏ដោយ។ សហជីពអាចចងសម្ព័ន្ធភាពដោយសេរី ប៉ុន្តែច្បាប់មិនបាននិយាយច្បាស់លាស់អំពីការចងសម្ព័ន្ធជាលក្ខណៈអន្តរជាតិឡើយ ។ មានសហព័ន្ធ និងសហភាពក្នុងស្រុកមួយចំនួន ដូចជា សមាគមគ្រូបង្រៀនឯករាជ្យកម្ពុជា (CITA) សហព័ន្ធសហជីពវាយនភណ្ឌជាតិកម្ពុជាឯករាជ្យ ជាដើម។ ក្រុមទាំងនេះមានចងសម្ព័ន្ធជាមួយសហជីពអន្តរជាតិ ដូចជាសហជីព International Textile, Garment and Leather Workers Fedderation, និង the International Trade Union Confederation ។ល។ ថ្វីត្បិតតែច្បាប់ត្រូវបានអនុវត្តចំពោះកម្មករនិយោជិកបរទេសក្តី តែវាមិនត្រូវបានអនុវត្តចំពោះមន្ត្រីរាជការ ដែលរួមមានដូចជាគ្រូបង្រៀន ចៅក្រមបុគ្គលិកយោធា ឬ អ្នក បំរើតាមផ្ទះទេ។

កម្លាំងពលកម្មប្រហែល ៥ ភាគរយនៃកំលាំងពលកម្មសរុប ចំនួនប្រហែល ៨,៨ លាននាក់ បានចូលសហជីព ។ សហជីពផ្តុំនៅក្នុងឧស្សាហកម្មសម្លៀកបំពាក់ និងទ្រនាប់ជើង ដែលមានប្រមាណជា ៦០

ភាគរយនៃកម្មករចំនួនប្រហែល ៣៦៣ ២០០ នាក់ជាសមាជិកសហជីព ។ សហជីពកម្មករទេសចរណ៍ និង សេវាកម្មកម្ពុជា បានរាយការណ៍ថា ខ្លួនតំណាងអោយអ្នកបម្រើការតាមសណ្ឋាគារ កាស៊ីណូ និង អាកាសយានដ្ឋាន ប្រមាណជា ៣.៧៥០ នាក់ ។ មានសហជីពលំដាប់រោងចក្រដែលបានចុះបញ្ជីជាង ១៩៤៤ ហើយសហព័ន្ធសហជីពនិងសមាគមចំនួន ៤៨៤ និងសហភាពសហជីពចំនួន ៨ ដែលភាគច្រើន កាន់ខាងរដ្ឋាភិបាល ហើយចំនួន ៩ ទៀតឯករាជ្យ ។

កម្មករបំរើការក្នុងផ្នែកកសិកម្មមិនច្រើនទេដែលបានចូលជាសមាជិកសហជីព។ សមាគមកសិករ ដើម្បីសន្តិភាព និងលទ្ធិប្រជាធិបតេយ្យមានសមាជិកចំនួន ១០០០ នាក់ ហើយសហព័ន្ធសហជីពឯករាជ្យ កម្ពុជា ដែលចងក្រងកម្មករចំការកៅស៊ូ បន្ថែមលើកម្មករកាត់ដេរសំលៀកបំពាក់ និងកម្មករស្បែកជើង មានចំនួនកម្មករចំការកៅស៊ូដែលគេមិនដឹង។

សមាគមគ្រូបង្រៀនឯករាជ្យកម្ពុជា (CITA) ដែលបានចុះបញ្ជីជា "សមាគម" ដោយសារមានការ ហាមប្រាមមិនអោយមានសហជីពក្នុងផ្នែកសាធារណៈនោះ តំណាងអោយគ្រូបង្រៀនចំនួន ៩៣០០ នាក ក្នុងចំណោមគ្រូបង្រៀនក្នុងប្រទេសចំនួន ១០៤ ៦១០ នាក់ ។ សំណើសុំដង្ហែរក្បួន (បាតុកម្ម) និងការតវ៉ាដទៃ ទៀតរបស់ CITA ជាញឹកញាប់ត្រូវបានបដិសេធ។ តែសហជីពនេះបានរាយការណ៍ថា គ្មានការជ្រៀតជ្រែក ដោយផ្ទាល់របស់រដ្ឋាភិបាលនៅក្នុងសកម្មភាពប្រចាំថ្ងៃទេ ។ សមាជិកខ្លះមានការភ័យខ្លាចថា ការចូលជា សមាជិកក្នុងសមាគមគ្រូបង្រៀននេះអាចមានការប៉ះពាល់ដល់ឱកាសបានឡើងឋានៈក្នុងអាជីព របស់គេ។

សមាគមផ្នែកសាធារណៈមួយទៀត គឺសមាគមរាជការស៊ីវិលឯករាជ្យ កម្ពុជា (CICA) តំណាង អោយមន្ត្រីរាជការចំនួន១.៦០០ នាក់ ក្នុងចំណោមមន្ត្រីរាជការស៊ីវិលចំនួនប្រមាណជា ១៧៧ ០០០ នាក់ នៅ ទូទាំងប្រទេស។ មេដឹកនាំរបស់ CICA បានចោទថា ការភ័យខ្លាចចំពោះការបៀតបៀន ការរើសអើង ឬការ បញ្ចុះមុខតំណែងបានរាំងមន្ត្រីរាជការស៊ីវិលមិនអោយចូលរួមក្នុងសមាគម ។

កំលាំងរបស់សហជីពមានការថយចុះក្នុងឆ្នាំនៃរបាយការណ៍នេះ ហើយសហជីពជាច្រើនមិនអាច ធ្វើការក្នុងនាមតំណាងអោយផលប្រយោជន៍នៃសមាជិកខ្លួនទេ ដោយកង្វះថវិកា ការបណ្តុះបណ្តាល និងបទ ពិសោធន៍។ លើសពីនេះទៀត អំពើពុករលួយមាននៅក្នុងជួរសហជីព និយោជក និងមន្ត្រីរដ្ឋាភិបាល ដែលជា ការអោយមានការរាំងស្ទះដល់ទំនាក់ទំនងវិជ្ជាជីវៈ (Industrial relations) ។ អំពើហឹង្សា ការបៀតបៀន និងការគំរាមរវាងសហជីពដែលមិនត្រូវគ្នា កើតមានច្រើន។ មេដឹកនាំសហជីពដែលមាននិន្នាការនយោបាយ ផ្សេងៗបានត្អូញត្អែថា សហព័ន្ធសហជីពយុវជនខ្មែរ ដែលគាំទ្ររដ្ឋាភិបាល តែងតែគំរាម និងរំខានដល់កម្មករ មកពីសហជីពដទៃៗទៀត។

នៅថ្ងៃទី ២ ខែវិច្ឆិកា តុលាការកំពូលបានបញ្ជាអោយមានការស៊ើបអង្កេតឡើងវិញក្នុងករណីធ្វើ ឃាតមេដឹកនាំសហជីព ឈ្មោះ ហុី វុទ្ធី កាលពីឆ្នាំ ២០០៧ ហើយបានបង្វិលករណីនោះទៅតុលាការជាន់

ទាបវិញ។ តាមសេចក្តីរាយការណ៍មកគឺថា មានបុរស ២ នាក់ជិះម៉ូតូមួយបានបាញ់ឈ្មោះវុទ្ធី ដែលជាប្រធានសហជីពសេរីកម្មករក្នុងរោងចក្រកាត់ដេរ Suntex ក្នុងព្រះរាជាណាចក្រកម្ពុជា នៅពេលគាត់កំពុងពីរោងចក្រវិញនៅពេលចប់វេនការងារ។ នគរបាលមិនបានធ្វើការចាប់ខ្លួនមនុស្សណាម្នាក់ទេ ហើយតុលាការជាន់ក្រោមបានបញ្ជាមិនអោយមានការចាត់ការអ្វីតទៅទៀតលើករណីនោះ។

នៅខែកុម្ភៈ ឆ្នាំ ២០០៩ តុលាការឧទ្ធរណ៍ បានតម្កល់សាលក្រម ឆ្នាំ ២០០៥ ដែលកាត់ទោសលើឈ្មោះ ថាច់ សារេត ចំពោះការធ្វើឃាតមេដឹកនាំសហជីព ឈ្មោះ រស់ សុវណ្ណារេត នៅឆ្នាំ ២០០៤ ។ លោក ថាច់ សារេត បានប្តឹងឧទ្ធរណ៍ទៅកាន់តុលាការកំពូល (សូមមើលផ្នែក ១.ង) ។

នៅខែសីហា ឆ្នាំ ២០០៩ សាលាឧទ្ធរណ៍បានសម្រេចអោយធ្វើការស៊ើបអង្កេតឡើងវិញចំពោះរឿងក្តីធ្វើឃាតកាលពី ឆ្នាំ២០០៤ លើមេដឹកនាំសហជីពឈ្មោះ ជា វិជ្ជា ។ ឆ្នាំ២០០៨ តុលាការកំពូល បានដោះលែងបណ្តោះ អាសន្ន ជនសង្ស័យទាំងពីរនាក់ ដែលត្រូវបានកាត់ទោសពីបទព្រហ្មទណ្ឌនេះ (សូមមើលផ្នែក ១.ង) ។

ថ្វីត្បិតតែច្បាប់មានចែងអំពីសិទ្ធិធ្វើកូដកម្ម និងការពារកូដករពីការសងសឹកក្តី តែលក្ខខ័ណ្ឌទាមទារសំរាប់ការធ្វើកូដកម្មស្របច្បាប់គឺមិនស្រួលទេ ។ ច្បាប់ចែងថា កូដកម្មអាចប្រព្រឹត្ត ទៅបានតែក្នុងករណីក្រោយពីបានបំពេញលក្ខខ័ណ្ឌតម្រូវមួយចំនួនតែប៉ុណ្ណោះ ដូចការដែលវិធីសាស្ត្រដោះស្រាយ វិវាទដទៃទៀតមិនបានទទួលជោគជ័យ (ដូចជាការចរចារ ការផ្សះផ្សា ឬការដោះស្រាយដោយអាជ្ញាកណ្តាល ជាដើម) ការបោះឆ្នោតដោយសម្ងាត់របស់សមាជិកសហជីព និងការជូនដំណឹងជាមុនរយៈពេលប្រាំពីរថ្ងៃទៅកាន់និយោជក និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (MOLVT) ។ ពុំមានច្បាប់ដែលហាមឃាត់ការធ្វើកូដកម្មដោយមន្ត្រីរាជការស៊ីវិល អ្នកបម្រើការនៅផ្នែកសាធារណៈ ឬអ្នកធ្វើការក្នុងផ្នែកសេវាសំខាន់ៗឡើយ ។

MOLVT បានរាយការណ៍ថាមានកូដកម្មចំនួន ១៣ បានកើតមានឡើងនៅតំបន់ក្រុងភ្នំពេញ នៅអំឡុងពេល ៧ ខែដំបូងនៃឆ្នាំនេះ ។ សមាគមរោងចក្រកាត់ដេរកម្ពុជា បានរាយការណ៍ថាមានកូដកម្មចំនួន ៣០ នៅទូទាំងប្រទេស ក្នុងអំឡុងពេលនោះ ។ អ្នកសង្កេតការណ៍អន្តរជាតិ និយោជក និងមេដឹកនាំសហជីពជាច្រើនបានយល់ស្របគ្នាថាស្ទើរគ្រប់កូដកម្មទាំងអស់ មិនបានបំពេញលក្ខខ័ណ្ឌច្បាប់មុនពេលធ្វើកូដកម្មឡើយ ។ ទោះបីមានសហជីពខ្លះបានត្អូញត្អែរចំពោះការខ្វះការចូលរួមរបស់ MOLVT ក៏ MOLVT បានដោះស្រាយវិវាទចំនួនប្រមាណជា ៥០ ភាគរយកន្លងមកដែរ ។

រដ្ឋាភិបាលបានអនុញ្ញាតអោយមានកូដកម្មភាគច្រើននៅតាមរោងចក្រ ប៉ុន្តែបដិសេធសំណើរបស់កម្មករសុំដើរជាក្បួនតវ៉ានៅក្រៅតំបន់រោងចក្រ ។ អន្តរាគមន៍របស់នគរបាលនៅក្នុងកូដកម្មមានតិចតួចបំផុត ហើយប្រកបដោយការទប់ចិត្ត ទោះបីជាក្នុងករណីមានការខូចខាតទ្រព្យសម្បត្តិកើតមានឡើងក៏ដោយ។

នៅថ្ងៃទី ១៥ ខែមករា មានកម្មកររោងចក្រកាត់ដេរ ៤ នាក់ ដែលតវ៉ាចំពោះការបណ្តេញមេដឹកនាំសហជីពរបស់គេ ៣ នាក់ពីរោងចក្រ Tage បានរងរបួសក្នុងពេលមានការវាយតប់ជាមួយនគរបាលបង្ក្រាបកុប្បកម្ម តែមិនធ្ងន់ធ្ងរទេ។ ក្នុងឆ្នាំនេះ មានកម្មករប្រមាណ ៩០០ នាក់បានតវ៉ាប្រឆាំងនឹងការបណ្តេញមេដឹកនាំសហជីពកាលពីថ្ងៃទី ៨ ខែមករា។

នៅថ្ងៃទី ២១ ខែមិថុនា មានកម្មករប្រមាណ ២ ០០០ នាក់នៅរោងចក្រកាត់ដេរ Ocean បានធ្វើការតវ៉ានៅមុខរោងចក្រ ដោយទាមទារអោយតំណាងសហជីពចំនួន ៧ នាក់បានចូលធ្វើការវិញ។ អ្នកទាំង ៧ នាក់នោះត្រូវបានបណ្តេញចេញពីការងារ បន្ទាប់ពីពួកគេបានប្រឆាំងនឹងការអោយធ្វើការថែមម៉ោង។ ម៉ាន់ សេងហាក់ អគ្គលេខាធិការនៃសហជីពកម្មករនៃព្រះរាជាណាចក្រកម្ពុជា បានអះអាងថា ថៅកែរោងចក្របានរំលោភច្បាប់ដោយបានព្យួរការងារដល់តំណាងសហជីព មុនពេលសុំការយល់ព្រមចំពោះទង្វើនេះ ដល់ក្រសួងសង្គមកិច្ច។

នៅថ្ងៃទី ២៧ ខែកក្កដា កម្មការនីរោងចក្រកាត់ដេរ ២ នាក់បានរងរបួស បន្ទាប់ពីនគរបាលប្រមាណ ៥០ នាក់បានព្យាយាមបង្ខំអោយកម្មករធ្វើកូដកម្មប្រមាណ ៣ ០០០ នាក់ បញ្ឈប់កូដកម្មរយៈពេលមួយសប្តាហ៍របស់គេនៅរោងចក្រកាត់ដេរ PCCS ។ មេនគរបាលក្នុងមូលដ្ឋានម្នាក់បានបដិសេធការចោទប្រកាន់ថា នគរបាលបានប្រើកំលាំងជ្រុល ដើម្បីបំបែកកូដកម្ម ដោយបាននិយាយបន្ថែមថា នគរបាលគ្រាន់តែរុញកម្មករអោយចូលទៅក្នុងបរិវេណរោងចក្រវិញតែប៉ុណ្ណោះ។

ទោះបីជាមានបទប្បញ្ញត្តិច្បាប់ការពារកូដករពីការសងសឹកក៏ដោយ ក៏មានរបាយការណ៍គួរអោយជឿទុកចិត្តថា កម្មករត្រូវបានបណ្តេញពីការងារ ដោយមូលហេតុមិនត្រឹមត្រូវក្រោយពីបានរៀបចំ ឬចូលរួមកូដកម្ម ។ ទោះបីជាកូដកម្មភាគច្រើនខុសច្បាប់ក៏ដោយ ក៏ការចូលរួមនៅក្នុងកូដកម្មខុសច្បាប់មិនអាចជាហេតុផល ដែលអាចទទួលយកបានដោយស្របច្បាប់សម្រាប់ការបណ្តេញកម្មករពីការងារឡើយ ។ ក្នុងករណីមួយចំនួន និយោជកបានគាបសង្កត់អោយកូដករទទួលយកសំណង ហើយលាលែងពីការងាររបស់ខ្លួន ។ មានវិធីសាស្ត្រដោះស្រាយ បញ្ហាមួយចំនួនដែលអាចយកមកប្រើបានចំពោះការបណ្តេញពីការងារ តែទោះបីជាយ៉ាងណាក៏ដោយ គ្មានវិធីសាស្ត្រណាមួយមានប្រសិទ្ធិភាពគួរអោយកត់សំគាល់ឡើយ ។ MOLVT អាចចេញបញ្ជាអោយមានការទទួលកម្មករអោយចូលបម្រើការងារឡើងវិញ ប៉ុន្តែជារឿយៗ បទបញ្ជាទាំងនោះញុះញង់ អោយថៅកែរោងចក្រគាបសង្កត់កម្មករអោយលាលែងពីការងារជាថ្នូរនឹងដំណោះស្រាយមួយ ។ វិវាទរួម ដូចជា ក្នុងករណីមាននិយោជិតច្រើនត្រូវបានបណ្តោញពីការងារ អាចត្រូវបានបញ្ជូនទៅកាន់ក្រុម

ប្រឹក្សាអាជ្ញាកណ្ដាលដើម្បីសម្រេច ។ ភាគីទាំងឡាយអាចជ្រើសរើសថា តើសេចក្ដីសម្រេចរបស់អាជ្ញាកណ្ដាលជាកាតព្វកិច្ច ឬមិនមែនជាកាតព្វកិច្ច (ដែលត្រូវធ្វើតាម) ។ ប្រសិនបើគ្មានភាគីណាមួយជំទាស់ចំពោះការសម្រេច របស់អាជ្ញាកណ្ដាលនៅក្នុងរយៈពេលប្រាំបីថ្ងៃ នៃការចេញសេចក្ដីសម្រេចរបស់អាជ្ញាកណ្ដាលទេនោះ សេចក្ដីសម្រេចគឺជាកាតព្វកិច្ចជាស្វ័យប្រវត្តិ ។ វិវាទបុគ្គលអាចត្រូវនាំយកទៅកាន់តុលាការទោះបីជាប្រព័ន្ធតុលាការលម្អៀង ឬគ្មានតម្លាភាពក៏ដោយ ។ សហជីពមួយចំនួនបានសុំអោយរដ្ឋាភិបាលធ្វើការពង្រីកតួនាទីរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល ដើម្បីបញ្ចូលវិវាទលើប្រយោជន៍បុគ្គល និងផលប្រយោជន៍រួម ព្រមទាំងជំរុញអោយសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាលមាន លក្ខណៈជាកាតព្វកិច្ច (ដែលត្រូវធ្វើតាម) ។

នៅថ្ងៃទី ១ ខែឧសភា អាត់ ធន់ ប្រធានសហភាពកម្មករកម្ពុជា និងសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា បានដឹកនាំកម្មកររាប់ពាន់នាក់ធ្វើបាតុកម្មគាំទ្រអោយមានការធ្វើសម្បទានអោយបានច្រើនដោយរោងចក្រនិងរដ្ឋាភិបាល ដោយរួមទាំងការដំឡើងប្រាក់បៀវត្សរ៍អប្បរមារបស់កម្មករកាត់ដេរ ហើយនិងការអនុវត្តប្រព័ន្ធប្រាក់ចូលនិវត្តន៍ និងថែទាំសុខភាព សំរាប់កម្មករកាត់ដេរ។ បាតុកម្មនោះប្រកបដោយសន្តិភាព ដោយគ្មានការប្រឈមមុខជាមួយនគរបាលទេ។ ក្នុងព្រឹត្តិការណ៍ដោយឡែកមួយទៀតអ្នកចូលរួមក្នុងក្បួនដង្ហែរដែលមានគ្នាចំនួន ៣០០ នាក់ ដឹកនាំដោយលោក រ៉ុង ឈុន ប្រធានសហភាពសហជីព និង សមាគមគ្រូបង្រៀនឯករាជ្យ មានការប្រវាប្រតប់គ្នាជាមួយនគរបាលដ៏ខ្លីមួយ ដោយសារការមិនយល់ស្របគ្នាលើផ្លូវត្រូវដើរក្បួន។ នៅល្ងាចដដែលនោះ នគរបាលបានរាំងមិនអោយលោក រ៉ុង ឈុន និងសហការីបញ្ចាំងភាពយន្តឯកសារនៅតាមសួនសារធារណៈ ស្ដីពីការធ្វើឃាតអ្នកដឹកនាំកម្មករឈ្មោះ ជា វិជ្ជា។ ភាពយន្តនោះមិនត្រូវបានអនុញ្ញាតដោយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈទេ ហើយមន្ត្រីសាលាក្រុងមិនផ្ដល់ការអនុញ្ញាតអោយបញ្ចាំងទេ។ នគរបាលបានរើចេញនូវផ្ទាំងសំពត់សដែលលោក រ៉ុង ឈុន និងអ្នកគាំទ្ររបស់លោកបានដំឡើងនៅលើសួនសាធារណៈ ហើយរាំងមិនអោយដំឡើងឡើងវិញទេ។

នៅថ្ងៃទី ៣ ខែកញ្ញា កម្មករកាត់ដេរបានចាប់ផ្ដើមធ្វើកូដកម្មរយៈពេល ៥ ថ្ងៃ ដើម្បីតវ៉ាពីរឿងការដំឡើងប្រាក់ខែអប្បរមា ដែលត្រូវបានអនុម័តនៅខែកក្កដា (សូមមើលផ្នែក ៧.ង) ហើយដែលមេដឹកនាំសហជីពខ្លះបាននិយាយថា មិនគ្រប់គ្រាន់សំរាប់ទប់ទល់នឹងការចំណាយដែលមានកាន់តែច្រើនឡើងនៅក្នុងការរស់នៅ នៅក្នុងនិងជុំវិញក្រុងភ្នំពេញ។ អាជ្ញាធរបានអនុញ្ញាតអោយកូដកម្មធ្វើជាបន្តជាសាធារណៈ។ មានរបាយការណ៍តិចតួចពីហឹង្សាទៅលើមនុស្សម្នាក់ៗ បង្ករដោយនគរបាល និងកម្មករ។ យ៉ាងណាក្តី និយោជកបានធ្វើបណ្ដឹងរដ្ឋប្បវេណីច្រើនប្រឆាំងនឹងមេដឹកនាំសហជីពកម្មករ ដែលនាំដល់ការចេញសាលក្រមរបស់តុលាការ និងការផ្អាកការងារ។ នៅថ្ងៃទី ១៦ ខែកញ្ញា សហជីពដែលមានការពាក់ព័ន្ធបាន

ផ្អាក ការធ្វើកូដកម្ម បន្ទាប់ពីរដ្ឋាភិបាលបានចូលខ្លួនធ្វើជាអាជ្ញាកណ្តាលដោះស្រាយជំលោះមួយរវាងកម្មករ និងថៅកែ។ កម្មករភាគច្រើនត្រឡប់ទៅធ្វើការវិញ តែថៅកែ មិនចង់ចចារដោះស្រាយបញ្ហាដែលនៅសល់ រួមទាំងការអោយត្រឡប់មកធ្វើការវិញនូវកម្មករចំនួន ៣៧៩ នាក់ ដែលកំពុងស្ថិតនៅក្នុងការព្យួរការងារ នៅឡើយ។

## ខ. សិទ្ធិរៀបចំចងក្រុង និងចចារអនុសញ្ញារួម

(The right to organize and bargain collectively)

ច្បាប់មានចែងអំពីសិទ្ធិរៀបចំចងក្រុង និងចចារអនុសញ្ញារួម ប៉ុន្តែការពង្រឹង ការអនុវត្តសិទ្ធិទាំងនេះ របស់រដ្ឋាភិបាលមិនមានភាពជាប់លាប់ឡើយ ។ អនុសញ្ញារួមមាននៅក្នុងឧស្សាហកម្មកាត់ដេរនិងសណ្ឋាគារ ជាមួយកម្មករជាប់កិច្ចសន្យានៅអាកាសយានដ្ឋានអន្តរជាតិទាំងពីរ ។

មានអនុសញ្ញារួមចំនួន ៥៥ ត្រូវបានចុះបញ្ជីនៅក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅអំឡុង ឆ្នាំ ។ ទោះជាយ៉ាងនេះក្តី អនុសញ្ញារួមទាំងនេះមិនមែនជាកិច្ចព្រមព្រៀងដែលមានលក្ខណៈទូលំទូលាយឡើយ ប៉ុន្តែគ្រាន់តែជាកិច្ចព្រមព្រៀងសាមញ្ញដែលលើកឡើងត្រឹមតែពីរបីចំណុច អំពីបញ្ហាពាក់ព័ន្ធនឹងប្រាក់ឈ្នួលតែ ប៉ុណ្ណោះ ។

មានបទប្បញ្ញត្តិមួយចែងអំពីនីតិវិធីដើម្បីអនុញ្ញាតអោយសហជីពបង្ហាញថា ខ្លួនជាតំណាងកម្មករ ដើម្បីចចារ អនុសញ្ញារួម ។ បទប្បបញ្ញត្តិនេះ ក៏មានកំណត់ផងដែរ អំពីលក្ខខណ្ឌតម្រូវចំពោះនិយោជក និង សហជីពពាក់ព័ន្ធ នឹងអនុសញ្ញារួម និងផ្តល់កិច្ចការពារបន្ថែមចំពោះមេដឹកនាំសហជីពពីការបណ្តេញ ចេញ ពីការងារ ។ ច្បាប់ការងារ តម្រូវអោយសហជីពកម្មករ និងអង្គការនិយោជក រៀបចំលក្ខន្តិកៈ និងបញ្ជី ឈ្មោះមន្ត្រីតំកល់ទុកនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។ ទីស្នាក់ការទំនាក់ទំនងការងារទទួល ខុសត្រូវ សម្របសម្រួលដំណើរការចុះបញ្ជី និងផ្តល់វិញ្ញាបនប័ត្រដល់សហជីពដែលមាន “ភាពជាតំណាង ខ្ពស់បំផុត” (Most representative status) ដែលផ្តល់សិទ្ធិអោយ សហជីពមួយធ្វើជាតំណាងកម្មករ ភាគ ច្រើនបំផុតនៅក្នុងសហគ្រាសមួយ ដើម្បីតំណាងអោយកម្មករទាំងអស់នៅ ក្នុងគ្រឹះស្ថាននោះ ។

ការពង្រឹងសិទ្ធិបង្កើតអង្គការសមាគម និងសេរីភាពរួចផុតពីការរើសអើងប្រឆាំងនឹងសហជីព មិនមាន លក្ខណៈជាប់លាប់ឡើយ ។ អំពើរើសអើងប្រឆាំងនឹងសហជីព ដោយនិយោជកជារឿយៗ ប្រព្រឹត្ត ទៅដោយ គ្មានការផ្តន្ទាទោស ។ ការអនុវត្តសិទ្ធិ ដោយរដ្ឋាភិបាល ត្រូវរំខានដោយកង្វះឆន្ទៈនយោបាយ

និងដោយទំនាក់ ទំនងហិរញ្ញវត្ថុនិងនយោបាយដ៏ច្របូកច្របល់ក្នុងចំណោមនិយោជក និងមេដឹកនាំសហជីព ។ រដ្ឋាភិបាលក៏ នៅខ្វះធនធាន រួមទាំងអធិការការងារដែលមានជំនាញនិងបទពិសោធន៍ ម្យ៉ាងដោយសារ រដ្ឋាភិបាលមិនបាន ផ្តល់ប្រាក់បៀវត្សរ៍គ្រប់គ្រាន់ដល់មន្ត្រី ។ ជារឿយៗ ក្រសួងការងារ និងបណ្តុះបណ្តាល វិជ្ជាជីវៈបានធ្វើការ សម្រេចដោយគាំទ្រនិយោជិក ប៉ុន្តែកម្រប្រើប្រាស់អំណាចស្របច្បាប់របស់ខ្លួន ដើម្បីដាក់ ទណ្ឌកម្មដល់ និយោជកដែលរំលោភបញ្ញារបស់ខ្លួនណាស់ ។ ផ្ទុយទៅវិញ បែរជាបញ្ជូនករណីជាច្រើនទៅ អោយក្រុមប្រឹក្សាអាជ្ញាកណ្តាលទៅវិញ ។

មានរបាយការណ៍ដែលអាចជឿទុកចិត្តបាន អំពីការបៀតបៀនសហជីពដោយពួកថៅកែ ដូចជាការ បណ្តេញមេដឹកនាំសហជីពពីការងារនៅតាមរោងចក្រកាត់ដេរ និងសហគ្រាសដទៃទៀត ។ នៅអំឡុងឆ្នាំ មានមេដឹកនាំសហជីព ប្រមាណជា ៤០ នាក់ ត្រូវបានបណ្តេញ ឬព្យួរការងារ ដោយគ្មានមូលហេតុ ។ នៅ តាមរោងចក្រខ្លះ អ្នកដែលមានតំណែងជាមេការហាក់បានបង្កើតសហជីពរបស់គេផ្ទាល់ គាំទ្រសហជីពដែល គាំទ្រខាងថៅកែ ឬធ្វើអោយខូចដល់មេដឹកនាំសហជីព តាមរយៈការខិតខំធ្វើអោយអន្តរាយដល់ការងាររបស់ គេ។

មេដឹកនាំសហជីពឯករាជ្យសំខាន់ៗ ត្រូវបានរាយការណ៍ថាបានទទួលការគម្រាម កំហែង ដោយ ហឹង្សាលាក់មុខ ។ មេដឹកនាំសហជីព ៤ នាក់ដែលឈរខាងសហជីពសេរីកម្មករនៃព្រះរាជណាចក្រកម្ពុជា បានទទួលរងរបួស ដោយសារឆ្មាំសន្តិសុខរោងចក្រដែលជួលដោយថៅកែរោងចក្រ ហើយម្នាក់ទៀតត្រូវបាន មេការចិនវាយ។ ទាំងមេដឹកនាំសហជីពឯករាជ្យ និងទាំងមេដឹកនាំសហជីពគាំទ្ររដ្ឋាភិបាលបានរងរបួស ដោយជនដៃដល់ដែលគេមិនស្គាល់អត្តសញ្ញាណ ។ នៅក្នុងករណីចំនួនពីរ មេដឹកនាំសហជីពចំនួន ៩ នាក់ បានទទួលរងការគម្រាមកំហែងដោយការប្តឹងផ្តល់ ឬត្រូវបានប្តឹងពីបទបរិហារកេរ្តិ៍ ការភូតកុហកតុលាការ ការញុះញង់ អោយកម្មករធ្វើកូដកម្ម បំផ្លិចបំផ្លាញទ្រព្យសម្បត្តិឯកជន និងប៉ុនប៉ងញុះញង់អោយកម្មករធ្វើ ការវាយប្រហារ ។ ជាច្រើនដង មេដឹកនាំសហជីពដែលត្រូវបានបណ្តេញពីការងារបានទទួលយកការដោះ ស្រាយជាប្រាក់ បន្ទាប់ពីបានតវ៉ាដោយមិនបានជោគជ័យទៅរដ្ឋាភិបាលអោយពង្រឹង ច្បាប់តម្រូវអោយផ្តល់ ការងារអោយខ្លួនវិញ ។

នៅអំឡុងឆ្នាំនៃរបាយការណ៍នេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានព្រមានជាផ្លូវការ ចំពោះក្រុមហ៊ុនចំនួន ៤០៤ អំពីការរំលោភច្បាប់ ។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានបញ្ជូនវិវាទ ការងារដែលមិនទាន់បានដោះស្រាយចំនួន៨៦ ករណីទៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ។ ក្រុមប្រឹក្សាអាជ្ញា

កណ្តាលបានទទួលបណ្តឹងចំនួន១៤៥ ករណី មកពីទូទាំងប្រទេស ដោយមានប្រមាណជា ៧០ ភាគរយ ត្រូវបានដោះស្រាយដោយជោគជ័យ ។ ករណីចំនួន ១៤៥ ត្រូវបានបញ្ចប់ ដោយមាន ១០៤ ករណីត្រូវបាន សំរុះសំរួលដោយក្រុមប្រឹក្សាអាជ្ញាកណ្តាល មានការព្រមព្រៀងគ្នាចំនួន ៣០ រវាងភាគី ក្នុងដំណើរការ ដោះស្រាយនោះ ហើយករណីចំនួន ១១ នៅមិនទាន់បានដោះស្រាយ។ ក្នុងចំណោមករណីដែលជួយ សំរុះសំរួល ទាំង ១០៤ នោះ មាន៥៨ ត្រូវបានជំទាស់ដោយភាគម្ខាង ដោយ ៤៥ ជំទាស់ដោយនិយោជក និង ១៣ ជំទាស់ដោយកម្មករ។

ពុំមានច្បាប់ពិសេស ឬការលើកលែងពីច្បាប់ការងារធម្មតា នៅក្នុងតំបន់ដំណើរការការនាំចេញ (ដែលហៅថា តំបន់សេដ្ឋកិច្ចពិសេស) ឡើយ ។

## គ. ការហាមឃាត់ការងារដោយបង្ខំ ឬដោយការតំរូវ

ច្បាប់ហាមប្រាមចំពោះការងារដោយបង្ខំ ឬដោយការតំរូវ ប៉ុន្តែមានរបាយការណ៍ថាមានការអនុវត្ត របៀប នេះនៅតាមផ្ទះនិងកន្លែងដទៃទៀត ស្ទើរតែក្នុងវិស័យក្រៅផ្លូវការទាំងមូល ។ សូមមើលរបាយការណ៍ ប្រចាំឆ្នាំរបស់ក្រសួងការបរទេសសហរដ្ឋអាមេរិកដែលមានចំណងជើងថា *របាយការណ៍ស្តីពីការជួញ ដូរមនុស្ស* ដែលមានអាស័យដ្ឋាន www.state.gov/g/tip ។

## ឃ. ការហាមឃាត់ពលកម្មកុមារ និងអាយុអប្បបរមាសម្រាប់បំពេញការងារ

ច្បាប់ការពារកុមារពីការកេងប្រវ័ញ្ចនៅកន្លែងធ្វើការ ប៉ុន្តែជាញឹកញាប់ការអនុវត្តនៅមានភាពទន់ ខ្សោយនៅឡើយ ។ ច្បាប់បានកំណត់ថា អាយុ១៥ឆ្នាំ គឺជាអាយុអប្បបរមាសម្រាប់បំពេញការងារ និង អាយុ១៨ ឆ្នាំជាអាយុ អប្បបរមាសម្រាប់បំពេញការងារដែលមានគ្រោះថ្នាក់ ។ ច្បាប់អនុញ្ញាតអោយកុមារ អាយុចន្លោះពី១២ ទៅ១៥ឆ្នាំ ចូលរួមក្នុង “ការងារស្រាល” ដែលមិនមានគ្រោះថ្នាក់ដល់សុខភាព និងមិនប៉ះ ពាល់ដល់ការសិក្សារបស់គេ ។

ពលកម្មកុមារមានច្រើននៅក្នុងការងារកសិកម្ម សិប្បកម្មឡឥដ្ឋ កន្លែងធ្វើអំបិល និងកែច្នៃបង្គារ ការនេសាទ ការបម្រើតាមផ្ទះ និងនៅតាមចំការកៅស៊ូ ។ ពលកម្មកុមារក៏ត្រូវបានរាយការណ៍ថាមាន នៅក្នុង វិស័យផ្លូវការផងដែរ ប៉ុន្តែមានកម្រិតតិចជាង ។ យោងតាមការសិក្សាមួយនៅឆ្នាំ២០០៦ ធ្វើឡើងដោយ

ធនាគារពិភពលោក និងអង្គការដទៃទៀត បានរកឃើញថា មានកុមារកំពុងធ្វើការចំនួនជាង ៧៥០.០០០នាក់ មានអាយុ១២ ឆ្នាំដែលជាអាយុក្រោមអប្បរមាដាច់ខាតសំរាប់បំពេញការងារ។ មានកុមារបន្ថែមចំនួន ៥០០.០០០ នាក់ទៀត (អាយុចន្លោះពី១២ ទៅ១៤ឆ្នាំ) កំពុងធ្វើការដែលមិនមែនជាការងារស្រាល ។ នេះគឺជាអាយុក្រោមអាយុអប្បបរមាដែលបានកំណត់សម្រាប់ការងារប្រភេទនេះ ។ យោងតាមរបាយការណ៍នេះ មានកុមារចំនួនជាង ២៥០.០០០នាក់ អាយុពី១៥ទៅ១៧ឆ្នាំ បានធ្វើការលើសពី ៤៣ម៉ោងក្នុងមួយសប្តាហ៍ ឬនៅក្នុងផ្នែកដែលមានគ្រោះថ្នាក់ ។ អ្នកជំនាញម្នាក់មកពីកម្មវិធីអន្តរជាតិលុបបំបាត់ពលកម្មកុមារនៃអង្គការពលកម្មអន្តរជាតិ បានថ្លែងថាចំនួនកុមារដែលធ្វើការនៅក្នុងលក្ខខណ្ឌការងារមានគ្រោះថ្នាក់បានកើនឡើងដល់ប្រមាណជា ៣០០.០០០ នាក់ ។ ចំនួនបីភាគបួននៃកុមារដែលកំពុងធ្វើការគឺនៅក្នុងវិស័យកសិកម្ម ១៥ ភាគរយនៅក្នុងវិស័យពាណិជ្ជកម្ម ៥ ភាគរយនៅក្នុងផ្នែកផលិតកម្មខ្នាតតូច និង២ ភាគរយនៅក្នុងផ្នែកផ្តល់សេវាកម្ម ។

យោងតាមរបាយការណ៍មួយនៅឆ្នាំ២០០៧ បានរកឃើញថា មានកុមារបម្រើតាមផ្ទះសរុបចំនួន ២១.២៦៦នាក់ នៅក្នុងទីក្រុងភ្នំពេញ និងខេត្តចំនួនបី គឺខេត្តបាត់ដំបង កំពង់ចាម និងសៀមរាប ។ ជាធម្មតាកុមារទាំងនេះមិនបានចូលរៀន ធ្វើការជាច្រើនម៉ោងដោយពុំទទួលបានអត្ថប្រយោជន៍ផ្នែកសុខភាព និងទទួលបានប្រាក់ឈ្នួល បន្តិចបន្តួច ឬមិនបានទទួលប្រាក់ឈ្នួលឡើយ ។ នៅថ្ងៃទី ១៩ ខែកុម្ភៈ តុលាការក្រុងភ្នំពេញបានកាត់ទោសគ្រូបង្រៀន ឈ្មោះ មាស ណារី អោយជាប់ពន្ធនាគារចំនួន ២០ ឆ្នាំ ដែលជាទោសកំរិតអតិប្បរមាក្រោមច្បាប់ស្តីពីការជួញដូរមនុស្ស ដែលបានចាប់ឃុំ និងធ្វើបាបកុមារអាយុ ១១ ឆ្នាំ ក្រោមការគ្រប់គ្រងរបស់ខ្លួន។ បងប្អូនរបស់កុមារនេះ ឈ្មោះ ធឿន រ៉េត ដែលបានលក់កុមារនេះទៅអោយប្តីប្រពន្ធនោះ ក៏ត្រូវបានកាត់ទោសអោយជាប់ពន្ធនាគារចំនួន ៥ ឆ្នាំផងដែរ ក្រោមការចោទប្រកាន់ពីបទជួញដូរមនុស្ស។

នៅថ្ងៃទី ១១ ខែមិថុនា នគរបាលបានចាប់ខ្លួនស្ត្រីនៅកោះកុងម្នាក់ដែលបានបង្ខំអោយកូនប្រុសចុងអាយុ ១២ ឆ្នាំ ដើររើសរបស់អេតចាយយកលុយ ហើយបានវាយកូននោះ បើវារកលុយមិនបានគ្រប់។ ការវាយដំលើរាងកាយដោយចេតនាអាចនាំអោយជាប់ពន្ធនាគារពី ២ ខែដល់ ៥ ឆ្នាំ។ រហូតដល់ដំណាច់ឆ្នាំករណីនោះនៅទើនៅតុលាការនៅឡើយ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈទទួលខុសត្រូវចំពោះអធិការកិច្ចលើបញ្ហាពលកម្មកុមារទាំង នៅក្នុងវិស័យផ្លូវការ និងវិស័យក្រៅផ្លូវការនៃសេដ្ឋកិច្ច ប៉ុន្តែក្រុមអធិការកិច្ចការងាររបស់ក្រសួង

មិនបានបំពេញតួនាទីនៅក្នុងវិស័យក្រៅផ្លូវការ ឬក្នុងការពង្រឹងការអនុវត្តច្បាប់នៅក្នុងឧស្សាហកម្មខុសច្បាប់ ដូចជារោងចក្រកាត់ដេរដែលមិនបានចុះបញ្ជី ហើយដំណើរការដោយគ្មានអាជ្ញាប័ណ្ណពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងពាណិជ្ជកម្ម ។ នៅក្នុងវិស័យផ្លូវការក្រុមអធិការកិច្ចការងារបាន ធ្វើការត្រួតពិនិត្យជាប្រចាំទៅលើឧស្សាហកម្មមួយចំនួន ដូចជាផ្នែកផលិតសម្លៀកបំពាក់ (ដែលឧប្បត្តិហេតុ នៃពលកម្មកុមារត្រូវបានព្រងើយកន្តើយ) ប៉ុន្តែនៅ ក្នុងឧស្សាហកម្មខ្លះដែលច្រើនប្រើពលកម្មកុមារ អធិការកិច្ចត្រូវបានធ្វើតែទៅតាមពាក្យបណ្តឹងតែប៉ុណ្ណោះ ។

រដ្ឋធម្មនុញ្ញហាមឃាត់ពលកម្មកុមារដោយបង្ខំ ឬពលកម្មកុមារបែបជាប់បំណុល ប៉ុន្តែពលកម្មកុមារដោយបង្ខំគឺជាបញ្ហាដ៏ធ្ងន់ធ្ងរមួយ។ អំពើពុករលួយដ៏រីករាលដាល កង្វះតម្លាភាព ធនធានមិនគ្រប់គ្រាន់ និងកង្វះបុគ្គលិក នៅតែជាឧបសគ្គដែលត្រូវប្រឈមបំផុត ។ ចំពោះព័ត៌មានបន្ថែមស្តីពីពលកម្មកុមារដោយបង្ខំសូមមើលរបាយការណ៍ប្រចាំឆ្នាំរបស់ក្រសួងការបរទេសសហរដ្ឋអាមេរិក ដែលមានចំណងជើងថា *របាយការណ៍ស្តីពីការជួញដូរមនុស្ស* ដែលមានអាស័យដ្ឋាន www.state.gov/g/tip ។

## ខ. លក្ខខណ្ឌការងារដែលអាចទទួលយកបាន

ច្បាប់តម្រូវអោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់វិស័យកាត់ដេរ ផ្អែកតាមអនុសាសន៍ពីគណៈកម្មាធិការប្រឹក្សាការងារ ។ នៅថ្ងៃទី ៨ ខែកក្កដា គណកម្មាធិការបានយល់ព្រមបង្កើនបៀវត្សរ៍អប្បរមាសំរាប់កម្មកររោងចក្រកាត់ដេរ ដល់៦១ ដុល្លាក្នុងមួយខែ ពី ៥០ ដុល្លាក្នុងមួយខែ សំរាប់កម្មករធម្មតា និងកើនដល់ ៥៦ ដុល្លាក្នុងមួយខែ ពី ៤៥ ដុល្លាក្នុងមួយខែ សំរាប់កម្មករដែលកំពុងស្ថិតក្នុងរយៈពេលសាកល្បងការងារ។ ប្រាក់ខែអប្បរមាថ្មីបូករួមជាមួយនឹងប្រាក់ឧបត្ថម្ភក្នុងការរស់ ដែលកំពុងមានចំនួន ៦ ដុល្លារ ដែលកម្មករបានចាប់ផ្តើមទទួលនៅឆ្នាំ ២០០៨។ ប្រាក់ខែថ្មីបានចូលជាធរមាននៅថ្ងៃទី ១ ខែតុលា ហើយកំណត់ត្រូវនៅជាធរមានរហូតដល់ឆ្នាំ ២០១៤។ កម្មករនិងមេដឹកនាំសហជីពបានអះអាងថា ប្រាក់ខែសព្វថ្ងៃក្នុងវិស័យកាត់ដេរ និងការងារដទៃជាច្រើនទៀត គឺមិនគ្រប់គ្រាន់សំរាប់ធ្វើអោយកម្មករ និងគ្រួសារមានកំរិតជីវភាពសមរម្យទេ ថ្វីបើប្រាក់ខែក្នុងវិស័យកាត់ដេរជាទូទៅ ខ្ពស់ជាងប្រាក់ខែក្នុងផ្នែកក្រៅផ្លូវការនៃសេដ្ឋកិច្ចក្តី។

និយោជកភាគច្រើននៅតាមរោងចក្រកាត់ដេរផ្តល់ប្រាក់ឈ្នួលអប្បរមាកំណត់ដល់កម្មករអចិន្ត្រៃយ៍ ប៉ុន្តែកម្មករបណ្តោះអាសន្ន និងកម្មករប្រភេទដូចនេះដទៃទៀត ជាញឹកញាប់ទទួលបានប្រាក់បៀវត្សរ៍តិច

ជាងនេះទេ។ ច្បាប់មិនបង្ខំអោយផ្តល់ប្រាក់ខែអប្បរមាកំណត់ដល់អ្នកធ្វើការក្នុងឧស្សាហកម្មដទៃណាមួយឡើយ។

ច្បាប់មានចែងអំពីរយៈពេលធ្វើការប្រចាំសប្តាហ៍តាមបទដ្ឋានស្របច្បាប់ចំនួន ៤៨ម៉ោង មិន អោយលើសពី ៨ ម៉ោងក្នុងមួយថ្ងៃឡើយ ។ ច្បាប់កំណត់អត្រា ១៣០ ភាគរយនៃប្រាក់ឈ្នួលធ្វើការនៅពេលថ្ងៃ សម្រាប់វេនការងារនៅពេលយប់ និង ១៥០ ភាគរយសម្រាប់ការងារបន្ថែមម៉ោង ដែលត្រូវកើនឡើង ២០០ ភាគរយ ប្រសិន បើការងារលើសម៉ោងនោះកើតមានឡើងនៅពេលយប់ នៅថ្ងៃអាទិត្យ ឬនៅថ្ងៃ ឈប់សម្រាក ។ និយោជិកត្រូវបានអនុញ្ញាតអោយធ្វើការលើសម៉ោងយ៉ាងច្រើន ២ ម៉ោងក្នុងមួយថ្ងៃ។ ទោះជាយ៉ាងនេះក្តី រដ្ឋាភិបាលមិនបានពង្រឹងការអនុវត្តបទដ្ឋាននេះប្រកបដោយប្រសិទ្ធភាពឡើយ ។ កម្មករបានរាយការណ៍ថា ការងារលើសម៉ោងច្រើនហួសកម្រិត ហើយជួនកាលគេតំរូវអោយធ្វើជាចាំបាច់ទៀតផង ។ ស្រដៀងគ្នានេះដែរ នៅក្រៅឧស្សាហកម្មកាត់ដេរ បទប្បញ្ញត្តិអំពីម៉ោងធ្វើការកម្រត្រូវបានអនុវត្តណាស់ ។ ការងារបន្ថែមម៉ោង ដោយគ្មានការស្ម័គ្រចិត្ត នៅតែជាបញ្ហាមួយ ទោះបីជាការធ្វើដូច្នេះបានថយចុះ ក្នុងឆ្នាំរបាយការណ៍ក្តី។ និយោជកបង្ខំអោយនិយោជិតធ្វើការ ។ ជារឿយៗ កម្មករត្រូវប្រឈមនឹងការផាកពិន័យ ការបណ្តេញពីការងារ ឬការបាត់បង់ប្រាក់រង្វាន់ ប្រសិនបើកម្មករទាំងនោះបដិសេធមិនធ្វើការបន្ថែមម៉ោង ។

ច្បាប់ចែងថា កន្លែងធ្វើការត្រូវគោរពតាមបទដ្ឋានអនាម័យ និងសុវត្ថិភាពគ្រប់គ្រាន់ដើម្បីផ្តល់សុខមាលភាព ដល់កម្មករ ។ រដ្ឋាភិបាលបានអនុវត្តបទដ្ឋានដែលមានស្រាប់បានអស់ទេ ម្យ៉ាងដោយសារខ្វះខាតបុគ្គលិកដែលបានទទួលការបណ្តុះបណ្តាលត្រឹមត្រូវ និងបរិក្ខារ ។ នាយកដ្ឋានអធិការកិច្ចការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈគឺជាទីភ្នាក់ងារពង្រឹងច្បាប់ជាចម្បង ហើយនៅអំឡុងឆ្នាំនេះ នាយកដ្ឋានបានចេញសេចក្តីព្រមានចំនួន ៥០៤ អំពីការរំលោភច្បាប់ការងារដល់ក្រុមហ៊ុននានា ។ ទីភ្នាក់ងារនេះហាក់ដូចជាបានធ្វើអធិការកិច្ចបានសស្រាក់សស្រាំ ប៉ុន្តែអំពើពុករលួយដ៏រីករាលដាល បានរារាំងដល់ប្រសិទ្ធភាពនៃអធិការកិច្ចទាំងនោះ ។ របួសក្នុងពេលធ្វើការងារ និងបញ្ហាសុខភាពកើតមានឡើងជាញឹកញាប់ ។ រោងចក្រកាត់ដេរធំៗ ភាគច្រើនដែលផលិតសម្រាប់ទីផ្សារនៅប្រទេសអភិវឌ្ឍ បានបំពេញបានល្អគួរសមតាមបទដ្ឋានអនាម័យ និងសុវត្ថិភាពការងារ ដែលជាលក្ខខណ្ឌសម្រាប់ចុះកិច្ចសន្យាជាមួយអតិថិជនទិញផលិតផលរបស់ខ្លួន ។ ស្ថានភាពការងារនៅតាមរោងចក្រខ្នាតតូចមួយចំនួន និងឧស្សាហកម្មតូចៗ មានលក្ខណៈទន់ខ្សោយ ហើយជារឿយៗ មិនបានបំពេញតាមបទដ្ឋានអន្តរជាតិទេ ។ ទណ្ឌកម្មមានចែងច្បាស់ ក្នុងច្បាប់ប៉ុន្តែគ្មានបទប្បញ្ញត្តិជាក់លាក់ណាមួយដើម្បីការពារកម្មករដែលតវ៉ាអំពីស្ថានភាពការងារដែលគ្មាន សុវត្ថិភាព ឬគ្មាន

អនាម័យឡើយ ។ កម្មករមានសិទ្ធិដកខ្លួនចេញពីស្ថានភាពដែលមានគ្រោះថ្នាក់ដល់សុខភាព និងសុវត្ថិភាព ដោយមិនប៉ះពាល់ការងាររបស់ខ្លួន ប៉ុន្តែអ្នកដែលហ៊ានធ្វើដូច្នេះអាចនឹងបាត់បង់ការងារ។

បុគ្គលិកក្នុងឧស្សាហកម្មដឹកជញ្ជូនតាមយន្តហោះ និងនាវាគ្មានសិទ្ធិទទួលបានការការពារបានពេញលេញរបស់ច្បាប់ទេ។ មាត្រាទី ១ និងទី ២៨៣ និយាយពីករណីដោយឡែកៗទៅវិញនៃឧស្សាហកម្មទាំងនេះ តែអ្នកធ្វើការក្នុងឧស្សាហកម្មទាំងនេះអាចបង្កើតសហជីពបាន។

នៅថ្ងៃទី ២៩ ខែមេសា អង្គការពលកម្មអន្តរជាតិបានចេញរបាយការណ៍មួយដែលប៉ាន់ប្រមាណថា កម្មករជាង ១ ៥០០ នាក់បានស្លាប់ក្នុងមួយឆ្នាំៗ ដោយសារគ្រោះថ្នាក់ក្នុងការងារ។ គ្រោះថ្នាក់ក្នុងការងារបានកើតឡើងជាញឹកញាប់ក្នុងផ្នែកសំណង់ ការធ្វើអិដ្ឋ នេសាទ ឧស្សាហកម្មកាត់ដេរ និងសហគ្រាសដែលមិនគោរពតាមបទដ្ឋានពលកម្ម ឬដែលមានការតំឡើងប្រព័ន្ធសុវត្ថិភាពមិនសមស្រប។ នៅថ្ងៃទី ៣០ ខែមេសា មន្ត្រីរដ្ឋាភិបាល និយោជក និងបុគ្គលិកកម្មករចំនួនជាង ៣៥០ នាក់បានធ្វើការអបអរទិវាពិភពលោកដើម្បីសុវត្ថិភាព និងសុខភាពក្នុងការងារ នៅខេត្តកំពង់ចាម។ ពិធីនោះមានបំណងស្វែងយល់ពីគ្រោះថ្នាក់ដែលអាចមានចំពោះសុខភាព និងសុវត្ថិភាពក្នុងការងារ ហើយនិងការការពារគ្រោះថ្នាក់ក្នុងការងារ។

នៅថ្ងៃទី ២ និងទី ៣ ខែមិថុនា កម្មករប្រមាណ ៥០ នាក់បានសន្លប់នៅក្នុងរោងចក្រធ្វើស្បែកជើង Tiger Wing ដែលមានថៅកែជាជនជាតិចិន ហើយមានទីតាំងនៅជាយក្រុងភ្នំពេញ។ នគរបាលបានអះអាងថារឿងនោះបណ្តាលមកពីកម្មករមានសុខភាពមិនល្អ ចំណែកឯមន្ត្រីថ្នាក់ស្រុកបាននិយាយថា ចំហាយជាតិគីមីចេញមកពីជ័របិទស្បែកជើងបានបណ្តាលអោយមានការសន្លប់ច្រើនគ្នាយ៉ាងដូច្នោះ។ មន្ត្រីមន្ទីរសុខាភិបាលបានសន្និដ្ឋានថា កម្មករបានដួលសន្លប់ដោយសារក្តៅហត់។

នៅថ្ងៃទី ៤ ខែកក្កដា អាជ្ញាធរបានបញ្ជាអោយបិទជាបណ្តោះអាសន្ននូវរោងចក្រកាត់ដេរឈ្មោះ Pine Great Cambodia នៅខ័ណ្ឌមានជ័យ បន្ទាប់ពីកម្មករចំនួន ៤៧ នាក់បានដួលសន្លប់ នៅពេលកំពុងធ្វើការ។ មេឃុំបាននិយាយថា មានកម្មករ ៥០ នាក់បន្ថែមទៀតបានឈឺក្បាល បន្ទាប់ពីវិលត្រឡប់ទៅផ្ទះវិញពីការងារតាមវេនរបស់គេ។ អនុប្រធាននាយកដ្ឋានទទួលបន្ទុកសុខភាពក្នុងការងារបានបដិសេធថា គ្មានជាតិគីមីបណ្តាលអោយមានរឿងបែបនោះទេ។